នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្ដារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០៣/០៧-០៩-២០០៩-អវតក/កសចស/អបជ(៣៥) |
| ដាក់ជូន | ៖ | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | ៖ | ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ |
| ភាគីអ្នកដាក់ | ៖ | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | ៖ | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Aug-2019, 15:58
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖ សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយរបស់ មាស មុត
ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង
ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266)**

---

**អ្នកដាក់ឯកសារ៖**
**សហព្រះរាជអាជ្ញាអន្តរជាតិ (បម្រុង)**
លោកស្រី Brenda J. HOLLIS

**ចម្លងជូន៖**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ីយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៣**

**សហមេធាវីការពារក្ដី មាស មុត**
លោក អាង ឧត្តម
លោក Michael KARNAVAS

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ដែលបានចោទប្រកាន់ មាស មុត ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងឱ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1]។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយមួយ ("ដីកាសម្រេចលើកលែងចោទប្រកាន់") ដែលបានលើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំង មាស មុត ដោយសំអាងថា គាត់មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ[2]។ សហព្រះរាជអាជ្ញាជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[3] ហើយ មាស មុត បានដាក់សំណើសុំឱ្យលើកលែងចោទប្រកាន់លើកលែងតែអង្គបុរេជំនុំជម្រះ ("អ.ប.ជ") តាមរយៈសម្តែងគាំទ្រភាគច្រើនលើសលប់ ច្រានចោលដីកាលើកលែងចោទប្រកាន់ និងតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[4] ដែលសហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានឆ្លើយតបនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩[5]។

2. ស.ព.អ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ដោយផ្អែកលើមូលដ្ឋានថា ដីកានេះសំអាងលើកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ដែលធ្វើឱ្យការសន្និដ្ឋានអំពីយុត្តា

[1] ឯកសារ **D267** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") ទំព័រ ២៥៦-២៦៤។

[2] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់") កថាខណ្ឌ ៤២៧-៤៣០។

[3] ឯកសារ **D267/3** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.ជ")។

[4] ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩។

[5] ឯកសារ **D267/10** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ចម្លើយតបរបស់ ស.ព.អ ទៅនឹង បណ្តឹងឧទ្ធរណ៍របស់ មាស មុត")។

ធិការបុគ្គលនៅក្នុងដីកានេះពុំមានសុពលភាព ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ")[6]។ ក្នុងការឆ្លើយតប[7] នាពេលនេះ មាស មុត ជំទាស់ថា (១) ដីកាសម្រេចលើកលែងចោទប្រកាន់តម្រូវឱ្យមានការធ្វើយុត្តិកម្មតិចជាងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (២) ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ត្រូវបានបញ្ចប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ហើយការបើកការស៊ើបអង្កេតឡើងវិញដោយ ស.ច.ស.អ បម្រុង ("ស.ច.ស.អ.ប") Kasper-Ansermet មិនបានធ្វើឱ្យសេចក្តីជូនដំណឹងពីការបញ្ចប់ការស៊ើបអង្កេតលែងមានសុពលភាពនោះទេ (៣) ស.ច.ស.ជ បានពិចារណា និងចេញដីកាសម្រេចមួយទៅលើអង្គហេតុទាំងអស់នៅក្នុងវិសាលភាពនៃសំណុំរឿង ០០៣ (៤) ដីកាសម្រេចលើកលែងចោទប្រកាន់គ្មានកំហុសទេក្នុងការសម្រេចទៅលើការបង្ខំ ការគាបសង្កត់ និងការបញ្ជាពីថ្នាក់លើ (៥) ស.ច.ស.ជ បានពិចារណាយ៉ាងត្រឹមត្រូវទៅលើការប្រព្រឹត្តិផ្ទាល់ និងការនៅក្បែរឧក្រិដ្ឋកម្ម (៦) សេចក្តីសន្និដ្ឋានលើអង្គហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ទាក់ទិននឹងតួនាទីរបស់ មាស មុត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មានភាពត្រឹមត្រូវ (៧) ការពិចារណារបស់ ស.ច.ស.ជ ចំពោះជនរងគ្រោះ ពុំមានកំហុសអង្គហេតុទេ និង (៨) ស.ច.ស.ជ មិនបានសម្រេចថា ឌុច ជាជន "ទទួលខុសត្រូវខ្ពស់បំផុត" តែម្នាក់គត់នោះទេ។ ចុងក្រោយ ចម្លើយតបនេះអះអាងថា ប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានច្រានចោលដោយសម្លេងគាំទ្រភាគច្រើនលើសលប់របស់ អ.ប.ជ ការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ពុំត្រូវបានប្រមើលមើលនៅកិច្ចព្រមព្រៀង អ.វ.ត.ក ទេ ហើយផ្ទុយទៅនឹងធម្មនុញ្ញ។

3. ស.ព.អ ផ្អែកទៅលើសារណានានានៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ និង ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ហើយឆ្លើយតបចំពោះកំហុសឆ្គង និងការលើកឡើងដោយមិនត្រឹមត្រូវជាក់លាក់នៅក្នុងចម្លើយរបស់ មាស មុត ដូចខាងក្រោម។

## II. ប្រវត្តិនីតិវិធី

[6] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ")។

[7] ឯកសារ **D266/5** ចម្លើយរបស់ មាស មុត ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ("ចម្លើយរបស់ មាស មុត")។

4. ស.ព.អ សូមយោងទៅប្រវត្តិនីតិវិធីដែលមាននៅក្នុងឧបសម្ព័ន្ធ I ដែលភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់[8] និងប្រវត្តិដែលលើកឡើងខាងលើ។ ច្បាប់ជាធរមានត្រូវបានលើក ឡើងនៅក្នុងវាក្យខណ្ឌពាក់ព័ន្ធខាងក្រោម។

5. នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ អ.ប.ជ បានសម្រេចបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ចម្លើយតបរបស់ភាគី និងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ ដោយបានណែនាំឱ្យភាគី ដាក់ការឆ្លើយតបរបស់ខ្លួនតែមួយភាសាសិន ក្នុងរយៈពេល ២៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីសំណៅបកប្រែនៃបណ្តឹងឧទ្ធរណ៍ដែលពួកគេត្រូវធ្វើការឆ្លើយតប[9]។ សំណៅបកប្រែជាភាសាខ្មែរនៃចម្លើយតបរបស់ មាស មុត ត្រូវបានជូនដំណឹងនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៩[10] ដែលធ្វើឱ្យការឆ្លើយតបនេះផុតកំណត់នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩។

## III. សារណា

### *កត្តានានានៃការបញ្ជូនរឿងក្តីទៅតុលាការ ICTY មានភាពពាក់ព័ន្ធក្នុងការវាយតម្លៃទៅលើយុត្តាធិការបុគ្គល*

6. មាស មុត អះអាងដោយមិនត្រឹមត្រូវថា ស.ព.អ បានសំអាងទៅលើកត្តាមិនសមស្របក្នុងការវាយតម្លៃទៅលើយុត្តាធិការបុគ្គល[11]។ ជាការពិត កត្តានានារបស់ ស.ច.ស សម្រាប់ "អ្នកទទួលខុសត្រូវបំផុត" គឺជាកត្តាទាំងឡាយដែលត្រូវបានលើកឡើងដោយ ស.ព.អ ហើយស្របទៅនឹងកត្តានានាដែលតុលាការ ICTY និងអង្គជំនុំជម្រះផ្សេងទៀតនៅ អ.វ.ត.ក បានយកមកសំអាង។

[8] ឯកសារ **D266/2.2** ឧបសម្ព័ន្ធ I៖ ប្រវត្តិនីតិវិធី ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩។

[9] ឯកសារ **D266/4** & ឯកសារ **D267/6** សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ចម្លើយតប និងការឆ្លើយតបនានា ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយសំណុំរឿង ០០៣ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ("សេចក្តីសម្រេចបន្ថែមពេលវេលា") ទំព័រ ៥។

[10] *សូមមើល* អ៊ីមែលស្តីពីការជូនដំណឹងពីមន្ត្រីគ្រប់គ្រងសំណុំរឿង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩ នៅម៉ោង ២.៣១ នាទីរសៀល។

[11] ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៧-១៤។

7. ដូចដែល ស.ព.អ បានកំណត់[12] ហើយបន្ទាប់មក បានយកមកប្រើប្រាស់នៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងមូល ហើយដូចដែល មាស មុត ខ្លួនឯង បានទទួលស្គាល់ដែរ[13] គឺថា ការកំណត់ថាតើ មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណា តម្រូវឱ្យវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលគាត់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងកម្រិតនៃការទទួលខុសត្រូវរបស់គាត់។ នេះជាបទដ្ឋានដែល ស.ច.ស ទាំងពីរ បានយកមកប្រើប្រាស់ ដោយឡែកពីគ្នា ឬជាមួយគ្នា នៅក្នុងសំណុំរឿង ០០៤/១[14] សំណុំរឿង ០០៤/២[15] និងសំណុំរឿង ០០៣[16] ហើយអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") និងអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ក៏បានប្រើប្រាស់នៅក្នុងសំណុំរឿង ០០១ ដែរ[17]។

8. តុលាការ ICTY ទទួលអាណត្តិការងារជាផ្នែកមួយនៃយុទ្ធសាស្ត្រក្នុងការបញ្ចប់របស់ខ្លួន ឱ្យផ្តោតទៅលើ "មេដឹកនាំជាន់ខ្ពស់បំផុតដែលជាប់សង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[18]។ នៅក្នុងការវាយតម្លៃទៅលើបុគ្គលទទួលខុសត្រូវខ្ពស់បំផុតទាំងនោះ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរបស់តុលាការ ICTY បានពិចារណាទៅលើ "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទ

[12] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩-១២។

[13] ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៨.ឃ។ បន្ទាប់មក មាស មុត យកកត្តាទាំងនេះមកប្រើប្រាស់នៅក្នុងចម្លើយរបស់ខ្លួនទាំងមូល៖ *សូមមើលឧទាហរណ៍* ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៤៨, ៥៥-៥៦, ៦៤-៦៥, ៦៧, ៧៧-៧៨, ៨៩-៩០, ៩២, ៩៧។

[14] ឯកសារ **D261** ដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ("ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១") កថាខណ្ឌ ៣៨-៣៩, ៣១៧។

[15] សំណុំរឿង ០០៤/២-ឯកសារ **D360** ដីកាដំណោះស្រាយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") កថាខណ្ឌ ៦៩៩ ប្រើប្រាស់នៅក្នុងកថាខណ្ឌ ៧០០-៧១២។ សំណុំរឿង ០០៤/២-ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់") កថាខណ្ឌ ៤២៤-៤២៥។

[16] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣, ៣៦៥-៣៦៧។ ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦០ ប្រើប្រាស់នៅក្នុងកថាខណ្ឌ ៤៦១-៤៦៩។ *សូមមើលផងដែរ* ឯកសារ **D48** ដីកាសម្រេចលើយុត្តាធិការបុគ្គល កថាខណ្ឌ ១៥។

[17] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើរឿងក្តី *ឌុច* កថាខណ្ឌ ៧១, ៨០។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ២២-២៤។

[18] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៥០៣ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ ឯកសារ អ.ស.ប លេខ S/Res/1503 បុព្វកថា ៧។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៥៣៤ (ឆ្នាំ២០០៤) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ ឯកសារ អ.ស.ប លេខ S/Res/1534 កថាខណ្ឌ ៥-៦។

ប្រកាន់” និង “កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ”[19]។ វាជាការសមស្របដែល ស.ច.ស សម្លឹងមើលទៅយុត្តិសាស្ត្រអន្តរជាតិ នៅពេលអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[20] រួមទាំងយុត្តិសាស្ត្ររបស់តុលាការ ICTY ផងដែរ ដើម្បីកំណត់អំពីកត្តានានាដែលពាក់ព័ន្ធនឹងការអនុវត្តបទដ្ឋាននេះ ដូចដែរ ស.ច.ស[21] អ.ជ.ស.ដ និង អ.ជ.ត.ក[22] បានអនុវត្តជាប្រចាំរួចមកហើយនោះ។

9. លើសពីនេះទៀត កត្តាទាំងនេះពុំមែនជា “កត្តានៃការបញ្ជូនរឿងក្តីនៅតុលាការ ICTY” តែមួយនោះទេ។ ដោយមិនបានយោងដល់កត្តាទាំងនេះ ស.ច.ស នៅក្នុងសំណុំរឿង ០០៤/១ បានយកកត្តាទាំងនេះមកប្រើប្រាស់រួមគ្នា[23] *ក្នុងចំណោមនោះ* រួមមាន ចំនួនជនរងគ្រោះ[24] សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម រួមទាំង ការចូលរួមរបស់គាត់នៅក្នុងការអនុវត្តគោលនយោបាយ និងឧក្រិដ្ឋកម្ម[25] ចំនួនប្រជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់[26] និងមុខ

[19] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY វិធាន ១១*ស្ទួន*(គ) យោងទៅសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ ១៥៣៤ ហើយលើកឡើងថា តុលាការ ICTY នឹងពិចារណាទៅលើ “ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់” និង “កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ” ក្នុងការសម្រេចថា តើគួរបញ្ជូនសំណុំរឿងនេះ ឬទេ។ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចនៃតុលាការ ICTY បានអនុម័តយកបទដ្ឋានទាំងនេះ៖ *សូមមើល* សេចក្តីសម្រេចបញ្ជូនរឿងក្តី *Milošević (Dragomir)* កថាខណ្ឌ ១-៣, ១៧-២៤។ សេចក្តីសម្រេចបញ្ជូនរឿងក្តី *Lukić & Lukić* កថាខណ្ឌ ២៦-២៨។

[20] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១២(១)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៣*ថ្មី*។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើរឿងក្តី *ឌុច* កថាខណ្ឌ ៥៩។

[21] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៦-៣៦៧។ សំណុំរឿង ០០៤/២-ឯកសារ **D359** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៥-៤២៦។ ឯកសារ **D48** ដីកាសម្រេចលើយុត្តាធិការបុគ្គល កថាខណ្ឌ ១៥-១៦, ២៤។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ៣២៧, ៣៣២ (ចៅក្រម Beauvallet និងចៅក្រម Baik)។ ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៣១ ដកស្រង់ពី ស.ច.ស.អ Blunk ដែលទទួលស្គាល់ថា គាត់ “បានបង្កើតកត្តា “ផ្អែកលើច្បាប់ស្តីពីការបង្កើត អ.វ.ត.ក *ព្រមទាំងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា*””។

[22] សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ២២។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើរឿងក្តី *ឌុច* កថាខណ្ឌ ៣៧៥។

[23] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១០-១២។

[24] ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ១២៥-១៣៥, ១៩៧, ១៩៩, ២១១-២២១, ២៣០, ២៧០, ២៧៦, ៣១៤, ៣១៧-៣២២។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ៣២៧-៣២៨, ៣៣០ (ចៅក្រម Beauvallet និងចៅក្រម Baik)។

[25] ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ១៧៣-១៧៥, ៣០៧-៣១១។ *សូមមើលផងដែរ*

តំណែងនៅក្នុងឋានានុក្រមរបស់គាត់[27]។ ដូចដែល មាស មុត ទទួលស្គាល់ ការអនុវត្តឆន្ទានុសិទ្ធិក្នុងការសម្រេចទៅលើយុត្តាធិការបុគ្គល ស្រដៀងនឹងការអនុវត្តឆន្ទានុសិទ្ធិក្នុងពេលផ្តន្ទាទោសដែរ[28] នៅពេលដែលអង្គជំនុំជម្រះមើលទៅលើភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តអំពើព្រហ្មទណ្ឌ រួមទាំង "ការពិចារណាអំពីកាលៈទេសៈពិសេសនៃរឿងក្តី" និង "ទម្រង់ និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មនោះ"[29] និងពិនិត្យលើកត្តាប្រហាក់ប្រហែលនានាផងដែរ[30]។

10. កត្តាទាំងនេះពិតជាមិនមែន "មិនពាក់ព័ន្ធ [ឬ] មិនអាចអនុវត្តបាន" នោះទេ[31]។ មាស មុត ដកស្រង់ ស.ច.ស មិនបានត្រឹមត្រូវទេត្រង់ចំណុចនេះ ដោយសហចៅក្រមទាំងពីររូបបានផ្តល់ការសង្កេតយ៉ាងត្រឹមត្រូវថា នៅពេលវាយតម្លៃពីភាពធ្ងន់ធ្ងរ ចំនួនជនរងគ្រោះដែលតុលាការ ICTY បានប្រើប្រាស់ មិនអាចយកមកប្រើដាច់ណាត់នៅក្នុងបរិបទ អ.វ.ត.ក បានទេ ដោយហេតុថា ចំនួនអ្នកស្លាប់សរុបក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យច្រើនជាងអតីតប្រទេសយូហ្គោស្លាវី[32]។

សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ៣៣២, ៣៣៤-៣៣៥។

26 ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ១៥៦។

27 ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ១៦១, ៣១៥។ *សូមមើលផងដែរ* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ៣៣២, ៣៣៥-៣៣៧។

28 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៥៥, ៦៥។ *សូមមើលផងដែរ* ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ៣៨។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៨។

29 *សូមមើលឧទាហរណ៍* សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ៥៨២។ សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមលើសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៦៨។

30 រួមមាន៖ (ក) ចំនួនជនរងគ្រោះ និងភាពងាយរងគ្រោះរបស់ជនរងគ្រោះ (ខ) ផលប៉ះពាល់នៃបទឧក្រិដ្ឋទៅលើជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ (គ) ទំហំ និងភាពឃោរឃៅនៃបទល្មើស (ឃ) តួនាទីរបស់ពិរុទ្ធជន និង (ង) វិសាលភាពភូមិសាស្ត្រ និងពេលវេលាការធ្វើឲ្យក្លាយជាជនរងគ្រោះ។ *សូមមើលឧទាហរណ៍* សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ១១១៨-១១២០។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកាលើរឿងក្តី *ឌុច* កថាខណ្ឌ ៣៧៥។

31 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ១៤ *ដកស្រង់ពី* ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ១៩។

32 ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ១៨-១៩។ *សូមមើលផងដែរ* ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៨.ក។

11. ចុងក្រោយ មាស មុត ទទួលស្គាល់ថា ប្រភេទនៃ "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលមាននៅក្នុងកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក[33] បើតាមអត្ថបទរបស់វា និងឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ("រ.រ.ក") និងអង្គការសហប្រជាជាតិ ("អ.ស.ប") គឺជាប្រភេទបើកចំហមួយ ដែលមានតែសហព្រះរាជអាជ្ញា និងចៅក្រមនៅ អ.វ.ត.ក ប៉ុណ្ណោះដែលអាចកំណត់អំពីសមាជិកភាពនៃប្រភេទបុគ្គលនេះ ផ្អែកលើភស្តុតាងសរុប[34]។ ផ្ទុយពីការអះអាងរបស់ មាស មុត[35] ស.ព.អ មិនបានមិនគិតអំពីប្រវត្តិនៃការចរចាទេ។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអត្ថបទកិច្ចព្រមព្រៀង អ.វ.ត.ក ដែលកំហិតយុត្តាធិការបុគ្គលចំពោះ បុគ្គល "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[36]។ ពុំមានចំណុចណាមួយនៅក្នុងការដកស្រង់របស់ មាស មុត ពី "ចេតនារបស់ភាគីនៃកិច្ចព្រមព្រៀង"[37] មកផ្លាស់ប្តូរចំណុចនេះ ឬបង្កើតជា "កត្តាសម្រាប់កំណត់អត្តសញ្ញាណបុគ្គលទទួលខុសត្រូវខ្ពស់បំផុត"[38] ដែលផ្តល់ការណែនាំច្បាស់លាស់ដល់ ស.ច.ស ក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ។

### *ក. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយមិនបានផ្តល់សំអាងហេតុ និងសំអាងច្បាប់ដែលចាំបាច់*

12. មាស មុត ពុំមានសំអាងហេតុគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា ដីកាសម្រេចលើកលែងចោទប្រកាន់ពុំមែនជាលក្ខខណ្ឌតម្រូវសម្រាប់ការកំណត់តាមផ្លូវច្បាប់ចំពោះសំអាង

33 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ១១។

34 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៩, ១១។ *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍ ស.ព.អ កថាខណ្ឌ ១១៥, ១៧៣-១៨៧។

35 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ១៥។

36 អត្ថបទនៃកិច្ចព្រមព្រៀង អ.វ.ត.ក ត្រូវបានសន្មតថាជាការបង្ហាញពិតប្រាកដពីចេតនារបស់ភាគីទាំងពីរ។ *សូមមើល* អនុសញ្ញាទីក្រុងវីយែន មាត្រា ៣១(១)។ *សូមមើលផងដែរ* ឯកសារ **D266/2.1.45** វិវាទទឹកដី (*Libyan Arab Jamahiriya v. Chad*) កថាខណ្ឌ ៤១។ ឯកសារ **D266/2.1.44** នីត្យានុកូលភាពនៃការប្រើប្រាស់កម្លាំង (*Serbia and Montenegro v. Belgium*) អញ្ញត្រកម្ម កថាខណ្ឌ ១០០។ ឯកសារ **D266/2.1.43** ការបកប្រែអំពីសន្ធិសញ្ញាសន្តិភាព (ដំណាក់កាលទី២) មតិយោបល់ទីប្រឹក្សា ទំព័រ ២២៩។ សេចក្តីព្រាងរបស់ ILC នៃច្បាប់សន្ធិសញ្ញា ជាមួយសេចក្តីអធិប្បាយ ទំព័រ ២២០ កថាខណ្ឌ ១១។ *សូមមើលផងដែរ* សាលដីកាលើរឿងក្តី *Čelebići* កថាខណ្ឌ ៦៨។ សំណុំរឿង ០០២-ឯកសារ **E350/8** សេចក្តីសម្រេចលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ២៧។

37 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៨.ក, ៩-១១។

38 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៨-៩។

ហេតុរបស់ខ្លួនទេ ហើយបានលើកឡើងដោយមិនត្រឹមត្រូវពីផលប៉ះពាល់នៃកំហុសឆ្គងនេះ ទៅលើការសន្និដ្ឋានអំពីយុត្តាធិការបុគ្គលរបស់ដីកាសម្រេចលើកលែងចោទប្រកាន់។ មាស មុត ក៏បានបកស្រាយដោយមិនត្រឹមត្រូវថែមទៀត ពីការដែលដីកាសម្រេចលើកលែងចោទប្រកាន់មិនបានមានសំអាងហេតុដែលចាំបាច់ត្រូវមាន ដោយ (១) មើលរំលងវិសាលភាពពេញលេញនៃសំណុំរឿង ០០៣ (២) ការយល់ឃើញដោយមិនត្រឹមត្រូវថា ការដកស្រង់ភស្តុតាងដូចគ្នានឹងសំអាងហេតុដែរ និង (៣) ការប្រៀបធៀបដោយគ្មានមូលដ្ឋាន និងនាំឱ្យមានការយល់ច្រឡំ ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ។

13. ផ្ទុយពីការអះអាងរបស់ មាស មុត[39] ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានកំណត់ឱ្យមានសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងការកំណត់ប្រភេទបទល្មើស និងទម្រង់នៃការទទួលខុសត្រូវ។ ផ្ទុយទៅវិញ ដីកានេះបានសន្និដ្ឋានថា មាស មុត មិនមែនជាជន "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ដោយពុំបានពិចារណាថាតើ (១) មានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬទេ ឬ (២) មាស មុត ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងនោះឬទេ[40]។ កំហុសឆ្គងនោះគឺជាភស្តុតាងស្រាប់ ទាំងលើបញ្ហាអង្គច្បាប់[41] និងសុភវិនិច្ឆ័យទូទៅ គឺថា បើគ្មានសំអាងច្បាប់ យុត្តាធិការរបស់តុលាការព្រហ្មទណ្ឌត្រូវបានកំណត់ដោយមិនយោងទៅដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ។

14. ទោះបីដីកាសម្រេចលើកលែងចោទប្រកាន់ដកស្រង់យ៉ាងត្រឹមត្រូវពីលក្ខខណ្ឌតម្រូវផ្លូវច្បាប់ដែលថា ឋានៈជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានវាយតម្លៃដោយផ្អែកលើ "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម" និង "កម្រិតនៃការទទួលខុសត្រូវ"[42] ក៏ដោយ តែក្នុងការអនុវត្ត ដីកានេះបានប្រកាន់យកលក្ខខណ្ឌថ្មីមួយ ដែល (១) កម្រិតបែបសិប្បនិម្មិតទៅលើវិសាលភាពនៃការវាយតម្លៃ ដោយយក "ចំនួនជនរងគ្រោះ" មកជំនួស "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម" នៃ "អំពើផ្ទាល់របស់ មាស មុត"[43] និង

[39] ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៤៥-៤៨, ៥៣-៥៤, ៨៩-៩០, ៩២។

[40] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣។

[41] *សូមមើល* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ២៦ (ជាឯកច្ឆ័ន្ទ)។

[42] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៥។ *សូមមើលផងដែរ* សំណុំរឿង ០០១-ឯកសារ **E188** សាលក្រមលើរឿងក្តី *ឌុច* កថាខណ្ឌ ២២។

[43] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។ *សូមមើលផងដែរ* កថាខណ្ឌ ៣៦៨, ៣៩៧,

(២) ដកចេញការពិចារណាទៅលើការទទួលខុសត្រូវ*ព្រហ្មទណ្ឌ* របស់ មាស មុត ចំពោះឧក្រិដ្ឋកម្ម ចេញពីការវាយតម្លៃទៅលើ "កម្រិត" នៃការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មទាំងនោះ[44]។

15. ការការពារជាសំខាន់របស់ មាស មុត ចំពោះកំហុសឆ្គងទាំងនេះ មិនត្រឹមត្រូវទេ ដោយ កំហុសឆ្គងទាំងនេះពុំមែនជា "កត្តាកំណត់ជាមូលដ្ឋាន" នៃការវាយតម្លៃលើយុត្តាធិការបុគ្គលទេ ដោយសារ ក្នុងករណីណាក៏ដោយ ដីកាសម្រេចលើកលែងចោទប្រកាន់កម្រិត "ការវិភាគពីភាពធ្ងន់ធ្ងរ" របស់ខ្លួនទៅលើជនរងគ្រោះនៃអ្វីដែលហៅថា "អំពើផ្ទាល់" របស់ មាស មុត[45]។ ចំណុចនេះមិនគិតដល់ចំណុចថា ការកម្រិតបែបនេះគឺជាកំហុសអង្គច្បាប់[46]។ ដូចគ្នាដែរ ទឡ្ហីករណ៍ផ្សេងទៀតរបស់គាត់ក៏មិនត្រឹមត្រូវដែរ។ ទោះបីគាត់អះអាងថា ដីកាសម្រេចលើកលែងចោទប្រកាន់បានធ្វើ "សេចក្តីសម្រេចដែលតម្រូវឲ្យមាន"[47] ក៏ដោយ ក៏គាត់មិនបានបង្ហាញសេចក្តីសន្និដ្ឋានណាមួយអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែល មាស មុត ទទួលខុសត្រូវនោះទេ ឧទាហរណ៍ ដោយសារនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ពុំមានសេចក្តីសន្និដ្ឋានបែបនេះទេ[48]។ ផ្ទុយពីការអះអាងរបស់គាត់[49] អ.ប.ជ បានចាត់ទុកសេចក្តីសន្និដ្ឋានពីអត្ថិភាពនៃឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវព្រហ្មទណ្ឌ ថាជាចំណុចមិនអាចខ្វះបានដើម្បីឲ្យដីកាសម្រេចលើកលែងចោទប្រកាន់មួយជាការ

៤០៥, ៤២៦។

44 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣, ៣៦៨។ *សូមមើលផងដែរ* កថាខណ្ឌ ៣៦៩, ៣៧៣, ៣៩៧, ៤០៥, ៤២៨។ ដីកាសម្រេចលើកលែងចោទប្រកាន់ហាក់ដូចជាប្រកាន់យកដោយមិនត្រឹមត្រូវដែលចារីជាក់ស្តែង ឬភាពប្រហាក់ប្រហែលបំផុតទៅនឹង "ការចូលរួម" ប៉ុណ្ណោះ។

45 *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៤៥ (*កត់សម្គាល់យោងទៅ* កថាខណ្ឌ ៨៩-៩២) ៤៨, ៥៤។

46 ទោះបីដីកាសម្រេចលើកលែងចោទប្រកាន់មិនបានបញ្ជាក់ពីអ្វីដែលហៅថា "អំពើផ្ទាល់" ឬ "ជនរងគ្រោះផ្ទាល់" ក៏ដោយ តែវាហាក់ដូចជាការកម្រិតពីភាពធ្ងន់ធ្ងរត្រឹមតែចំពោះឧក្រិដ្ឋកម្មដែលជនជាប់ចោទជាចារីផ្ទាល់ ឬនៅក្បែរនោះ។ ចំណុចនេះផ្ទុយពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយក៏មានន័យថា សមាជិកនៃថ្នាក់ដឹកនាំនៅក្នុងសហឧក្រិដ្ឋកម្មរួមស្ទើរតែមិនត្រូវបានកំណត់ថាជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។ *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍ ស.ព.អ កថាខណ្ឌ ១១២-១២០។ *ខាងក្រោម* កថាខណ្ឌ ៤៤-៤៩។

47 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៤៥, ៥៤។

48 សំអាងហេតុតិចតួចនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ពុំបង្កើតជាសំអាងច្បាប់ទេ ហើយមិនគ្រប់គ្រាន់ដើម្បីបង្កើតជាមតិយោបល់ដែលមានសំអាងហេតុនោះទេ។ *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៥១។

49 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤៦-៤៧, ៥៤។

សន្និដ្ឋានត្រឹមត្រូវ[50]។ ហេតុនេះ ការសំអាងរបស់គាត់ទៅលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ នាំឱ្យមានការភាន់ច្រឡំ ដោយហេតុថា ស.ច.ស ទាំងពីរ បានផ្ដល់សំអាងច្បាប់ (ទោះបីមិនគ្រប់គ្រាន់ក្ដី) ទៅលើឧក្រិដ្ឋកម្មផង និងទម្រង់នៃការទទួលខុសត្រូវផង និងបានយកចំណុចទាំងពីរនេះមកពិចារណាយ៉ាងច្បាស់លាស់ក្នុងការវាយតម្លៃរបស់ខ្លួនទៅលើយុត្តាធិការបុគ្គល[51]។

16. មាស មុត មានការភាន់ច្រឡំចំពោះទស្សនទានខុសគ្នាចំនួនពីរ នៅពេលគាត់អះអាងថា ឧក្រិដ្ឋកម្មជាក់លាក់ដែលបានប្រព្រឹត្ត ពុំមានឥទ្ធិពលទៅលើការវាយតម្លៃអំពី "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម" ទេ ដោយសារគ្មាន "ឋានានុក្រមជាប់មកជាមួយ" ក្នុងចំណោមឧក្រិដ្ឋកម្មទេ[52]។ ទោះបីអាចថាមិនមាន "ឋានានុក្រមជាប់មកជាមួយ" ជាទូទៅ[53] ក៏ដោយ ក៏ឧក្រិដ្ឋកម្មជាក់លាក់ដែលកំពុងពិភាក្សា គឺជាកត្តាមួយដែលពាក់ព័ន្ធនឹងរាល់ការវាយតម្លៃអំពីភាពធ្ងន់ធ្ងរ ដូចបានបង្ហាញនៅក្នុងសំណុំរឿងទាំងអស់ដែល មាស មុត យកមកសំអាង[54]។ លើសពីនេះទៀត ឧក្រិដ្ឋកម្មជាក់លាក់ដែលកំពុង

[50] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយក្នុងរឿងក្ដី អ៊ឹម ចែម កថាខណ្ឌ ២៦ (ជាឯកច្ឆ័ន្ទ)។ ផ្ទុយពីការព្យាយាមធ្វើឱ្យមានពាក្យពេចន៍ដាច់ស្រឡះពីគ្នារបស់ មាស មុត សេចក្ដីសន្និដ្ឋានទៅលើ "អត្ថិភាពនៃឧក្រិដ្ឋកម្ម" និង "ការទទួលខុសត្រូវព្រហ្មទណ្ឌ" *គឺជា* កំណត់ប្រភេទបទល្មើសតាមផ្លូវច្បាប់ ដែលតម្រូវឱ្យមានការកំណត់អត្តសញ្ញាណឧក្រិដ្ឋកម្មជាក់លាក់ និងទម្រង់នៃការទទួលខុសត្រូវជាក់លាក់ ដើម្បីកំណត់ថា តើធាតុផ្សំជាមូលដ្ឋានត្រូវបានបំពេញឬទេ។

[51] ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៤៨ *ដកស្រង់ពី* ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១។ ទោះបី ស.ច.ស បានពិចារណាដោយប្រើអំណាចឆន្ទានុសិទ្ធិទៅលើកត្តាបន្ថែមនានាដែលពាក់ព័ន្ធនឹង "កម្រិតនៃការទទួលខុសត្រូវ" ក៏ដោយ ក៏សហចៅក្រមទាំងពីររូបមិនបាន*ដកចេញ* ការទទួលខុសត្រូវព្រហ្មទណ្ឌពីការវិភាគនោះទេ។ ពុំមានឆន្ទានុសិទ្ធិក្នុងការធ្វើមិនដឹងមិនឮអំពីការទទួលខុសត្រូវតាមផ្លូវច្បាប់របស់ជនត្រូវចោទចំ ពោះបទឧក្រិដ្ឋនានាទេ នៅពេលសម្រេចថា តើគាត់ជាជន "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មទាំងនោះ។

[52] *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៤៨។ *សូមមើលផងដែរ* កថាខណ្ឌ ៩២។

[53] សាលដីកាលើ *រឿងក្ដី* *Stakić* កថាខណ្ឌ ៣៧៥។

[54] *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយរបស់ មាស មុត ជើងទំព័រ ៤០៤-៤០៥ (*សូមមើលឧទាហរណ៍* សាលដីកាលើ *រឿងក្ដី* *Rutaganda* កថាខណ្ឌ ៥៩០-៥៩១។ សាលដីកាលើ *រឿងក្ដី* *Kayishema and Ruzindana* កថាខណ្ឌ ៣៦៧។ សាលដីកាលើ *រឿងក្ដី* *Stakić* កថាខណ្ឌ ៣៧៥)។ ផ្ទុយពីការបកស្រាយដោយមិនត្រឹមត្រូវរបស់ មាស មុត នៅឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៩២ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចនៃតុលាការ ICTY នៅក្នុង*រឿងក្ដី* *Trbić* បានពិចារណាទៅលើឧក្រិដ្ឋកម្មជាក់លាក់ដែលកំពុងពិភាក្សា ព្រមទាំងការប្រព្រឹត្តិជាមូលដ្ឋាន និងកាលៈទេសៈជុំវិញ និងបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មទាំងនោះពុំមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ទេ។ ថ្វីត្បិតតែយ៉ាងនេះក្ដី ក្រុមប្រឹក្សានេះបានបញ្ជូនសំណុំរឿងដោយសារកម្រិតនៃការទទួលខុសត្រូវទាបរបស់ជនជាប់ចោទ។ កង្វះ "ឋានានុក្រមជាប់មកជាមួយ" ជាទូទៅ ក្នុង

ពិភាក្សាអាចមានឥទ្ធិពលទៅលើជ្រុង *ទាំងពីរ* នៃការវាយតម្លៃអំពី "ជនទទួលខុសត្រូវខ្ពស់បំផុត"។ ជាឧទាហរណ៍ ការសន្និដ្ឋានដែលថា ជនជាប់ចោទទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការសម្លាប់រង្គាល នឹងពាក់ព័ន្ធទាំងចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មផង (ការសម្លាប់ជាទ្រង់ទ្រាយធំ) និងកម្រិតនៃការទទួលខុសត្រូវផង (ចេតនាក្នុងការសម្លាប់ជាទ្រង់ទ្រាយធំ)[55]។

17. ពុំមានលក្ខខណ្ឌតម្រូវជាថា បុគ្គលម្នាក់ត្រូវទទួលការចោទប្រកាន់ មុនពេលអង្គហេតុនានាត្រូវបានកំណត់ប្រភេទបទល្មើសតាមផ្លូវច្បាប់នោះទេ[56]។ ចំណុចនេះមិនត្រឹមតែមិនមានសុភវិនិច្ឆ័យទូទៅទេ តែមិនគិតដល់ ឧទាហរណ៍ ចំណុចដែលថា សហព្រះរាជអាជ្ញាត្រូវបានតម្រូវឱ្យធ្វើការកំណត់ប្រភេទបទល្មើសនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន ដើម្បីឱ្យ ស.ច.ស យកទៅពិនិត្យពីដំបូង[57]។ យ៉ាងណាក៏ដោយ មាស មុត ត្រូវបានចោទប្រកាន់ដោយ ស.ច.ស.អ Harmon និង ស.ច.ស.អ Bohlander មុនពេលចេញដីកាសម្រេចលើកលែងចោទប្រកាន់[58] ហេតុនេះគាត់ជា "ជនត្រូវចោទ" ទៅតាមអត្ថន័យនៅក្នុងវិធាន ៦៧ នៃវិធានផ្ទៃក្នុង។

18. ចុងក្រោយ មាស មុត បកស្រាយមិនត្រឹមត្រូវពីការពិភាក្សាអំពីមន្ទីរសន្តិសុខឥន្ទញាណនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់[59] ដែលមានភាគច្រើនជាសម្រង់អត្ថបទពីភ័ស្តុតាងដែលត្រូវបាន

ចំណោមឧក្រិដ្ឋកម្ម ពុំពាក់ព័ន្ធនឹងសេចក្តីសម្រេចបញ្ជូនសំណុំរឿងទេ។ *សូមមើល* សេចក្តីសម្រេចបញ្ជូនរឿងក្តី *Trbić* កថាខណ្ឌ ១៨-២០, ២២-២៣។

55 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍ ស.ព.អ កថាខណ្ឌ ២៤។

56 *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៥៣។

57 វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង ["ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកើតមានពិត។ [...] ដីកានេះ ត្រូវមានព័ត៌មានដូចខាងក្រោម៖ [...] បទប្បញ្ញត្តិច្បាប់ដែលមានកំណត់ និងបង្ក្រាបបទឧក្រិដ្ឋនេះ"]។

58 ឯកសារ **D128** ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។ ឯកសារ **D128.1** ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥។ ឯកសារ **D174** កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។ នៅក្នុងសំណុំរឿង ០០៤/១ ស.ច.ស.ជ បានចូលរួមក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ រួមទាំងការកំណត់ប្រភេទបទល្មើសតាមផ្លូវច្បាប់ចំពោះអង្គហេតុនានា ទោះបីគាត់មិនបានចូលរួមក្នុងការចោទប្រកាន់ អ៊ឹម ចែម និងផ្តល់សំអាងច្បាប់ទៅលើឧក្រិដ្ឋកម្មនានាដែល អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់ដោយ ស.ច.ស ណាម្នាក់ក៏ដោយ។ *សូមមើល* ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ២៨១-៣០៥។

59 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៤៩-៥០។ ស.ព.អ បានលើកចំណុចនេះមកធ្វើជាឧទាហរណ៍មួយ

ជ្រើសរើសដោយចង្អៀត ដែលពុំមែនជាសេចក្តីសន្និដ្ឋានទេ[60]។ វិធីសាស្ត្រនេះធ្វើឱ្យភាគីមិនអាចប្តឹងឧទ្ធរណ៍បាន និងរារាំង អ.ប.ជ មិនឱ្យបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការពិនិត្យទៅលើសេចក្តីសន្និដ្ឋាននានាដែលនាំឱ្យមានការសម្រេចទៅលើយុត្តាធិការបុគ្គលនោះ[61]។ ការពិភាក្សាទៅលើភស្តុតាងអំពីវត្តឥន្ទ្រីញាណដែលមានចំនួន ២ ទំព័រ នៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ខុសស្រឡះពីពាក្យដែលថា "ស្ទើរតែដូចគ្នាបេះបិទ"[62] ទៅនឹងសំអាងហេតុ និងសំអាងច្បាប់ ដែលមានចំនួន ១៤ ទំព័ររបស់ ស.ច.ស.អ[63] ដែលមានសេចក្តីសន្និដ្ឋានយ៉ាងច្បាស់ថា មាស មុត ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការសម្លាប់រង្គាល អំពើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខនោះ ក្រោមទម្រង់ជាការទទួលខុសត្រូវចំនួន ៤ ខុសៗគ្នា ព្រមទាំងចំពោះអំពើមនុស្សឃាតដោយចេតនាគិតទុកជាមុន[64]។ ផ្ទុយពីការបកស្រាយដោយមិនត្រឹមត្រូវរបស់ មាស មុត[65] ស.ច.ស.អ ពុំដែលលើកឡើងថា ភស្តុតាងពីការត្រួតត្រាទៅលើវត្តឥន្ទ្រីញាណរបស់ មាស មុត "មិនត្រូវបានសន្និដ្ឋាន" នោះទេ។ ផ្ទុយទៅវិញ ស.ច.ស.អ បានសន្និដ្ឋានថា អង្គភាពដែលនៅក្រោមបញ្ជារបស់ មាស មុត ស្ថិតក្រោមការត្រួតត្រារបស់គាត់ក្នុងអំឡុងពេលនោះទាំងមូល ហេតុនេះ ស.ច.ស.អ បានសន្និដ្ឋានថា មាស មុត ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅទីនោះ[66]។

ដែលដីកាសម្រេចលើកលែងចោទប្រកាន់ពុំបានផ្តល់សំអាងហេតុជាមូលដ្ឋានបាន។ ចំណុចផ្សេងទៀតរួមមានការពុំផ្តល់សេចក្តីសន្និដ្ឋាន*នានា*ទៅលើទីតាំងឧក្រិដ្ឋកម្មជាច្រើន និងអំពើឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៣ ទេ។ *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍ ស.ព.អ កថាខណ្ឌ ៦៣-៨២។ *ខាងក្រោម* កថាខណ្ឌ ៣១-៣៦។

60 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៨៨-២៩៧។

61 *សូមមើល* សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** សេចក្តីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម កថាខណ្ឌ ២៦ (ជាឯកច្ឆ័ន្ទ)។ ពុំមានភាពច្បាស់លាស់ថាតើគេអាចប្តឹងឧទ្ធរណ៍ទៅនឹងការលើកឡើងនៃសក្ខីកម្មរបស់សាក្សីដែលថា អ្នកទោសត្រូវបាន ឬមិនត្រូវបានដាក់ឱ្យស្ថិតក្នុងស្ថានភាពអមនុស្សនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដោយរបៀបណាទេ ដោយសារពុំមានការសន្និដ្ឋានពីលទ្ធផលនានា (ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៤-២៩៥)។

62 *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយរបស់ មាស មុត កថាខណ្ឌ ៥៩។

63 ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤២៦-៤៤៣, ៥៥២-៥៥៩, ៥៦២-៥៧១, ៥៧៦-៥៧៧, ៥៨១ ទំព័រ ៤២៨-៤២៩, ៤៣០-៤៣១។

64 ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទំព័រ ៤២៨-៤២៩, ៤៣០-៤៣១។

65 ឯកសារ **D266/5** ចម្លើយរបស់ មាស មុត ជើងទំព័រ ២៣០។

66 ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥៥, ៤២៩, ៤៥៩, ៥៦៤។

## ខ. ដីកាលើកលែងការចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយសារខកខាន មិនបានពិចារណាលើភស្តុតាងដែលប្រមូលបានក្រោយថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១

19. មាស មុត អះអាងដោយមិនត្រឹមត្រូវថា ស.ព.អ បានបកស្រាយមិនត្រឹមត្រូវអំពីភារកិច្ចស៊ើបអង្កេតរបស់ ស.ចៅ.ស[67]។ ផ្ទុយមកវិញ ស.ព.អ ខ្លួនឯងដែលយល់ឃើញអំពីទស្សនាទាន និងលក្ខខណ្ឌនៃការស៊ើបអង្កេត "ទាំងអស់" ដោយមិនត្រឹមត្រូវ ហើយខកខានមិនបានគាំទ្រទឡ្ហីករណ៍របស់ខ្លួនដែលលើកឡើងថា សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៦៦ (១)[68] ដែល ស.ចៅ.ស.អ Blunk និង ស.ចៅ.ស.ជ ចេញ កាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១១ គឺជាសេចក្តីជូនដំណឹងចុងក្រោយ ហើយបានបិទកិច្ចស៊ើបសួរយ៉ាងត្រឹមត្រូវ។

20. ដីកាលើកលែងការចោទប្រកាន់យល់ខុសអំពីកាតព្វកិច្ចស៊ើបអង្កេតរបស់ ស.ចៅ.ស ហើយ មាស មុត ក៏យល់ខុសដែរ។ ទោះបីជា មាស មុត អះអាងថា "ដើម្បីបំពេញកិច្ចស៊ើបសួរដែលពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាព ស.ចៅ.ស មិនត្រឹមតែត្រូវកំណត់អង្គហេតុប៉ុណ្ណោះទេ ថែមទាំងត្រូវកំណត់អត្តសញ្ញាណ អ្នកដែលទទួលខុសត្រូវផងដែរ"[69] ក៏ដោយ ក៏ទឡ្ហីករណ៍របស់គាត់ផ្អែកលើការអះអាងខុសដែលថា "កិច្ចស៊ើបសួរ*ណាមួយ*"[70] ដែល ស.ចៅ.ស ចាត់ទុកដោយអត្តនោម័តថាចាំបាច់ពាក់ព័ន្ធនឹងអង្គហេតុដែលខ្លួនទទួលខុសត្រូវ មានភាពគ្រប់គ្រាន់នោះ។ មាស មុត លើកឡើងដោយមិនត្រឹមត្រូវថា ប្រសិនបើមានសម្ភារៈ *ខ្លះ* នៅក្នុងសំណុំរឿង ពាក់ព័ន្ធនឹងអង្គហេតុ ពុំមានបទដ្ឋានអប្បបរមាចំពោះការស៊ើបអង្កេត "ប្រកបដោយប្រសិទ្ធភាព" ឡើយ ដោយហេតុថា ស.ចៅ.ស មានឆន្ទានុសិទ្ធិទូលំទូលាយលើរបៀបដែលខ្លួនធ្វើការស៊ើបអង្កេត[71]។

21. ដូច ស.ព.អ ពន្យល់នៅក្នុងបណ្តឹងឧទ្ធរណ៍[72] ទោះបីជាចៅក្រមមានសិទ្ធិទូលំទូលាយក្នុងការសម្រេចអំពីរបៀបដែលគាត់ស៊ើបអង្កេតក៏ដោយ[73] ក៏ឆន្ទានុសិទ្ធិនេះពុំមែនថាគ្មានដែនកម្រិតនោះទេ

[67] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២១។

[68] ឯកសារ **D13** សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ("សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ")។

[69] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៣១។

[70] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២៧ (គូសបញ្ជាក់បន្ថែមលើឯកសារដើម)។

[71] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២៣-៤, ២៧។

[72] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៤៣-៨។

ហើយពុំអនុញ្ញាតឲ្យរួចផុតពីកាតព្វកិច្ចរបស់គាត់ក្នុងការអនុវត្តដោយយកចិត្តទុកដាក់ក្នុងស៊ើបអង្កេតពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាព ដើម្បីបញ្ជាក់ការពិត[74]។ ស.ព.អ ពុំដែលអះអាងថាករណីនេះបានបង្កើតជា "សិទ្ធិដាច់ខាត...ដើម្បីឈានដល់ការជំនុំជម្រះ ឬការផ្តន្ទាទោស"[75]។ លក្ខខណ្ឌនៃការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពគឺជាមធ្យោបាយមួយប៉ុណ្ណោះ ពុំមែនជាលទ្ធផលនោះទេ[76]។ ទោះបីជាយ៉ាងនេះក្តី ការស៊ើបអង្កេតមិនអាច "ត្រឹមតែជា ទម្រង់ដែលត្រូវបានចាត់ទុកថាគ្មានប្រសិទ្ធភាពនោះទេ"[77] ហើយ ស.ច.ស ត្រូវបានតម្រូវមិន "ឲ្យសំអាងលើសេចក្តីសន្និដ្ឋានតក់ក្រហល់ ឬគ្មានមូលដ្ឋាន ដើម្បីបិទកិច្ចស៊ើបសួររបស់ខ្លួន ឬដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការចេញសេចក្តីសម្រេចរបស់ខ្លួននោះទេ"[78]។

22. ការព្រមព្រៀងរបស់ ស.ច.ស លើវិធីស៊ើបអង្កេត[79] ពុំពាក់ព័ន្ធនោះទេ ប្រសិនបើវិធីទាំងនោះខកខានមិនបានផ្តល់ការស៊ើបអង្កេតមួយ "ហ្មត់ចត់ មិនលម្អៀង និងមានប្រសិទ្ធភាព"[80] ដែល "គ្រប់គ្រាន់"[81] ហើយ*អាច* "នាំទៅដល់ការកំណត់លើអង្គហេតុ...និងក្នុងករណីសមស្រប ធ្វើការ

[73] *ឧទាហរណ៍ សូមមើល* សំណុំរឿង ០០២ ឯកសារ **D164/3/6** សេចក្តីសម្រេចអំពីករណី SMD កថាខណ្ឌ ២១។ ឯកសារ **D134/1/6.1.4** សាលដីកាលើពាក្យសុំរបស់ជនត្រូវចោទសុំប្តឹងជំទាស់ចិត្តបណ្ឌិត Stephen Heder និង David Boyle ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ កថាខណ្ឌ ២០។

[74] *ឧទាហរណ៍ សូមមើល* សំណុំរឿង ០០២ ឯកសារ **D164/3/6** សេចក្តីសម្រេចអំពីករណី SMD កថាខណ្ឌ ៣៥។ សំណុំរឿង ០០២ ឯកសារ **D365/2/17** សាលដីកាលើសម្ភារភ័ស្តុតាង កថាខណ្ឌ ៦១។

[75] *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២២ *ដកស្រង់ រឿងក្តី Brecknell តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ៦៦។

[76] *ឧទាហរណ៍ សូមមើល រឿងក្តី Armani តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៣៣។ *រឿងក្តី Mustafa Tunç និង Fecire Tunç តទល់នឹង ប្រទេសតួកគី* កថាខណ្ឌ ១៧៣។

[77] *រឿងក្តី Velásquez-Rodriguez តទល់នឹង ប្រទេសហុងឌុយរ៉ាស់* កថាខណ្ឌ ១៧៧។ *រឿងក្តី Vereda La Esperanza តទល់នឹង ប្រទេសកូឡុំប៊ី* កថាខណ្ឌ ១៨៥ (បកប្រែក្រៅផ្លូវការ)។

[78] *រឿងក្តី El Masri តទល់នឹង ប្រទេសម៉ាសេដូនី* កថាខណ្ឌ ១៨៣។

[79] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២៤ *ដកស្រង់* ឯកសារ **D266** ដីកាសម្រេចលើកលែងការចោទប្រកាន់ កថាខណ្ឌ ៤១, ៤៨។

[80] *រឿងក្តី Vereda La Esperanza តទល់នឹង ប្រទេសកូឡុំប៊ី* កថាខណ្ឌ ១៨៥ (បកប្រែក្រៅផ្លូវការ)។

[81] *រឿងក្តី Ramsahai តទល់នឹង ប្រទេសហូឡង់* កថាខណ្ឌ ២៣៤។ *រឿងក្តី Mustafa Tunç និង Fecire Tunç តទល់នឹង ប្រទេសតួកគី* កថាខណ្ឌ ១៧២។ *រឿងក្តី Armani តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៣០, ២៣៣។

កំណត់អត្តសញ្ញាណ និងដាក់ទណ្ឌកម្មចំពោះអ្នកទទួលខុសត្រូវ"[82]។ ការស៊ើបអង្កេតបែបនេះត្រូវ *"ទូលំទូលាយ ជាប្រព័ន្ធ និងលម្អិត"*[83] ដែលមានន័យថា ស.ច.ស "ត្រូវចាត់*វិធានការសមហេតុផលណាមួយតាមលទ្ធភាព* ដើម្បីស្វែងរកភ័ស្តុតាង"[84] ពាក់ព័ន្ធនឹងអង្គហេតុដែលគាត់ទទួលវិនិច្ឆ័យ។ សេចក្តីសន្និដ្ឋានចេញការស៊ើបអង្កេតត្រូវតែផ្អែកលើការវិភាគដោយមិនលម្អៀង និងហ្មត់ចត់ លើ*ធាតុផ្សំទាំងអស់ដែលពាក់ព័ន្ធ*[85]។

23. ដូច្នេះ ការស៊ើបអង្កេត *មិន* ពេញលេញ ប្រសិនបើខកខានមិនបាន (i) ស៊ើបអង្កេតបញ្ហាស្នូលនៃរឿងក្តី[86] (ii) អនុវត្តតាមខ្សែសង្វាក់នៃការសាកសួរឱ្យបាច្បាស់លាស់[87] (iii) ស្វែងរក និងស្តាប់ចម្លើយសាក្សីសំខាន់ៗ[88] ឬ (iv) វាយតម្លៃគ្រប់គ្រាន់លើភាពអាចជឿជាក់បាននៃសេចក្តីថ្លែងខុសគ្នាដែលបានធ្វើឡើង[89]។ ផ្ទុយពីបទដ្ឋានទាំងនេះ[90] នៅក្នុងសំណុំរឿង ០០៣ ពុំមានការចុះ

[82] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២២ (ការគូសបញ្ជាក់បន្ថែម) *ដកស្រង់ រឿងក្តី* Armani Da Silva *តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៣៣។ *សូមមើលផងដែរ* កថាខណ្ឌ ២៤៣។ *សូមមើលបន្ថែម រឿងក្តី* Kolevi *តទល់នឹង ប្រទេសប៊ុលហ្គារី* កថាខណ្ឌ ១៩២។ *រឿងក្តី* Vereda La Esperanza *តទល់នឹង ប្រទេសកូឡុំប៊ី* កថាខណ្ឌ ១៨៥ (បកប្រែក្រៅផ្លូវការ) "ការស៊ើបអង្កេតទាំងមូលត្រូវបានផ្តោតសំខាន់លើគោលបំណងជាក់លាក់មួយពោលគឺ ការកំណត់ការពិត និងការស៊ើបអង្កេត សំអាងហេតុ ការចាប់ខ្លួន ការចោទប្រកាន់ និងប្រសិនបើពាក់ព័ន្ធការដាក់ទណ្ឌកម្មលើអ្នកដែលទទួលខុសត្រូវលើហេតុការណ៍។ [...] ការស៊ើបអង្កេតត្រូវធ្វើឡើងតាមមធ្យោបាយស្របច្បាប់គ្រប់បែបយ៉ាងដែលមាន"]។

[83] *រឿងក្តី* Vereda La Esperanza *តទល់នឹង ប្រទេសកូឡុំប៊ី* កថាខណ្ឌ ២៦៨ (បកប្រែក្រៅផ្លូវការ)។

[84] *រឿងក្តី* Armani *តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៣៣។ *រឿងក្តី* Isayeva *តទល់នឹង ប្រទេសរុស្ស៊ី* កថាខណ្ឌ ២១២។ *រឿងក្តី* Vereda La Esperanza *តទល់នឹង ប្រទេសកូឡុំប៊ី* កថាខណ្ឌ ១៨៥។

[85] *រឿងក្តី* Giuliani *និង* Gaggio *ទល់នឹង ប្រទេសអ៊ីតាលី* កថាខណ្ឌ ៣០២។ *រឿងក្តី* Kolevi *តទល់នឹង ប្រទេសប៊ុលហ្គារី* កថាខណ្ឌ ១៩២, ២០១។

[86] *រឿងក្តី* Hugh Jordan *តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ១០៧ [នៅក្នុងករណីពាក់ព័ន្ធនឹងការបំពានមាត្រា ២ (សិទ្ធិរស់រានមានជីវិត) "វិការៈនៅក្នុងការស៊ើបអង្កេតដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពបង្ហាញមូលហេតុមរណភាពរបស់បុគ្គលណាមួយ ឬបុគ្គលទាំងឡាយដែលទទួលខុសត្រូវ អាចមានកំហុសលើបទដ្ឋាននេះ"]។ *រឿងក្តី* Isayeva *តទល់នឹង ប្រទេសរុស្ស៊ី* កថាខណ្ឌ ២១២, ២១៨-២២៤។

[87] *រឿងក្តី* Armani *តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ២៣៤។ *រឿងក្តី* Giuliani *និង* Gaggio *ទល់នឹង ប្រទេសអ៊ីតាលី* កថាខណ្ឌ ៣០២។ *រឿងក្តី* Kolevi *តទល់នឹង ប្រទេសប៊ុលហ្គារី* កថាខណ្ឌ ២០១។

[88] *រឿងក្តី* Hugh Jordan *តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ១០៧។ *រឿងក្តី* Tanrukulu *តទល់នឹង ប្រទេសតួកគី* កថាខណ្ឌ ១០៩។ *រឿងក្តី* Isayeva *តទល់នឹង ប្រទេសរុស្ស៊ី* កថាខណ្ឌ ២១២។

[89] *រឿងក្តី* M.C. *តទល់នឹង ប្រទេសប៊ុលហ្គារី* កថាខណ្ឌ ១៧៨។

ស៊ើបអង្កេតឲ្យបានគ្រប់ជ្រុងជ្រោយនៅតាមទីតាំងផ្ទាល់ នៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ នោះឡើយ។ ផ្ទុយពីការអះអាងរបស់ មាស មុត[91] មានតែសាក្សី ១៤ នាក់ ដែលបានស្តាប់ចម្លើយដោយចៅក្រម Lemonde ហើយសាក្សី ០៣ នាក់ ត្រូវបានស្តាប់ចម្លើយដោយ ស.ច.ស Blunk និង យូ ប៊ុនឡេង[92] ក្រៅពីនោះ សាក្សីសំខាន់ៗនៅក្នុងសំណុំរឿង ០០៣ ពុំត្រូវបានស្តាប់ចម្លើយឡើយ[93] ក្រោយពេល ស.ច.ស ជ្រើសរើសដោយចេតនាក្នុងការបញ្ឈប់ការស្តាប់ចម្លើយសាក្សី ហើយបែរមកពិនិត្យមើលឯកសារវិញ[94]។ ពុំមានភាពពាក់ព័ន្ធខ្លាំងនោះទេថា[95] ទោះបីជារបាយការណ៍កំណត់អត្តសញ្ញាណទីតាំងទាំងពីរ គឺ មន្ទីរសន្តិសុខវត្តឥន្ទញាណ និងការដ្ឋានស្ទឹងហាវ ត្រូវបានកំណត់ថា "បឋម" ក៏ដោយ ក៏ទីតាំងទាំងនេះពុំត្រូវបានចុះពិនិត្យម្តងទៀតនៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[96] ឡើយ ហើយ ស.ច.ស ពុំបានស្នើសុំចម្លើយពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ពីមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ[97]។

24. ទោះបីជាអះអាងថា "ការប្រៀបធៀបស្ថិតិមិនមានភាពពាក់ព័ន្ធឡើយ" ក៏ដោយ[98] ក៏ មាស មុត គាំទ្រការអះអាងរបស់ខ្លួនថា ការស៊ើបអង្កេតបានបញ្ចប់ដោយយោងលើកំណត់ហេតុនៃការស្តាប់

90 ផ្ទុយពី ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២៧។

91 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២៧ ដែលសំអាងលើចម្លើយរបស់ ស.ច.ស.អ Blunk លើកឡើងថា "សាក្សីសំខាន់ៗត្រូវបានស្តាប់ចម្លើយ រួមទាំង ឌុច ផងដែរ"។

92 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ លេខយោងជើងទំព័រ ១៥៧ ក្នុងនោះ រួមមាន ឯកសារ **D8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ប៊ុនឡេង ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ត្រូវបានដីកាសម្រេចលើកលែងចាត់ប្រកាន់ចាត់ទុកថាពុំពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៣៖ ឯកសារ **D266** ដីកាសម្រេចលើកលែងការចោទប្រកាន់ លេខយោងជើងទំព័រ ៥។

93 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ៥១, ៥៦, លេខយោងជើងទំព័រ ១៩៣។

94 ឯកសារ **D2/1** របាយការណ៍បញ្ចប់ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ ERN 00657727-00657728។

95 ផ្ទុយពី ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២៧។

96 ឯកសារ **D2/22** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងវត្តឥន្ទញាណ EN 00662101-00662102។ ឯកសារ **D2/23** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងការដ្ឋានស្ទឹងហាវ EN 00714348-49, 00714360-00714362។

97 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ៥១, ៥៦, លេខយោងជើងទំព័រ ១៩៤។

98 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២៦។

ចម្លើយសាក្សី "ជាង ៤៣០"[99] ដែលមាននៅក្នុងសំណុំរឿង ០០៣ នៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ទោះបីជាយ៉ាងនេះក៏ដោយ ដូច ស.ព.អ បានយោងកន្លងមក[100] មានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួនតែ ២០ ប៉ុណ្ណោះ ដែលត្រូវបានបង្កើតឡើងនៅក្នុងសំណុំរឿង ០០៣ ក្នុងនោះមានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ១៨ ត្រូវបានដាក់ភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួចហើយ ដែលពុំត្រូវបានបង្កើតឡើងនៅក្នុងពេលស៊ើបសួរសំណុំរឿង ០០៣ ទេ[101]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាច្រើនដែលត្រូវបានផ្ទេរមកពីសំណុំរឿង ០០១ និង ០០២ ពាក់ព័ន្ធនឹងបញ្ហានានាដែលដូចគ្នារវាងសំណុំរឿង ០០១ សំណុំរឿង ០០២ និងសំណុំរឿង ០០៣ (នៅត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១)[102] ប៉ុន្តែ កំណត់ហេតុទាំងនេះពុំបានផ្តោតជាសំខាន់លើបញ្ហាជាក់លាក់នៅក្នុងសំណុំរឿង ០០៣ ដូចជា ឧទាហរណ៍ (i) បុគ្គលិកយោធា (ជាពិសេស មកពីកងពលធំលេខ ១៦៤ និងវៀតណាម ថៃ ហើយនឹងអ្នកទោសបរទេសផ្សេងទៀត ដែលចាប់បាននៅសមុទ្រ ហើយត្រូវបានបញ្ជូនទៅ ស-២១ និង (ii) តួនាទីរបស់ មាស មុត (និង ស៊ូ ម៉េត) នៅក្នុងឧក្រិដ្ឋកម្ម។ ផ្ទុយពីការអះអាងរបស់ មាស មុត[103] ការស៊ើបសួរ

99 ក.ស.ព. បានធ្វើការស្វែងរកនៅក្នុងប្រព័ន្ធ Zylab សាជាថ្មី ដែលរៀបរាប់លម្អិតនៅក្នុង ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត លេខយោងជើងទំព័រ ១៣៥ ហើយបានរកបានកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ៤៥៣ ជាមួយនឹងអក្សរនាំមុខ ឯកសារ D1 ឯកសារ D2 (ការស្តាប់ចម្លើយទាំង ១៧ ដែលបានធ្វើឡើងដោយ ស.ច.ស.អ Lemonde) ឯកសារ D4 ឯកសារ D10 ព្រមទាំងកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ៣ ឯកសារ D6 ឯកសារ D8 និងឯកសារ D12 ដែលធ្វើឡើងដោយ ស.ច.ស.អ Blunk និង ស.ច.ស.ជ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ២១ បន្ថែមទៀត ត្រូវបានរកឃើញដោយក្នុងនោះរួមមានអ្នកដែល (ជាមួយនឹងអក្សរនាំមុខ ឯកសារ D1 ឯកសារ D4 និង ឯកសារ D10 ដែលសំណៅបកប្រែជាភាសាអង់គ្លេសត្រូវបានបន្ថែមនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ ប៉ុន្តែ មានជាភាសាខ្មែរនៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។

100 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ៥០។

101 ឯកសារ **D1.3.32.17** ឯកសារ **D1.3.32.21** ឯកសារ **D1.3.32.36** ឯកសារ **D1.3.32.43** ឯកសារ **D1.3.32.44** ឯកសារ **D1.3.32.49** ឯកសារ **D1.3.32.9** ឯកសារ **D1.3.33.3** ឯកសារ **D1.3.33.4** ឯកសារ **D1.3.33.5** ឯកសារ **D1.3.33.6** ឯកសារ **D1.3.33.8** ឯកសារ **D1.3.33.9** ឯកសារ **D1.3.33.10** ឯកសារ **D1.3.33.11** ឯកសារ **D1.3.33.12** ឯកសារ **D1.3.33.13** ឯកសារ **D1.3.33.15**។

102 ដោយសារ ស-២១ ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំ និងមន្ទីរសន្តិសុខអូរកន្សែងត្រូវបានស៊ើបអង្កេតរួចហើយ ក្នុងគោលបំណងសម្រាប់សំណុំរឿង ០០១ និង ០០២ ស.ច.ស មានសិទ្ធិពិនិត្យសម្ភារៈអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅទីនោះ ដែលពួកគេបានផ្ទេរយ៉ាងត្រឹមត្រូវ។

103 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២៨។

ប្រកបដោយប្រសិទ្ធភាព តម្រូវឲ្យ ស.ច.ស ស្តាប់ចម្លើយឡើងវិញចំពោះសាក្សីជាច្រើននៅក្នុងចំណោមសាក្សីទាំងនោះ ដើម្បីយកភស្តុតាងដោយផ្ទាល់ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០៣។

25. កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ០៥ មានចំណុចពាក់ព័ន្ធទៅនឹងបញ្ហាសំខាន់នៅក្នុងសំណុំរឿង ០០៣[104]។ កំណត់ហេតុមួយចំនួនតូចប៉ុណ្ណោះពាក់ព័ន្ធនឹងបញ្ហាដែលមានលក្ខណៈប្រយោលទៅនឹងចំណុចស្នូលនៃសំណុំរឿង។ ឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីខ្លះបានលើកឡើងអំពីប្រតិបត្តិការបច្ចេកទេសនៅកំពង់សោម[105] កំពង់ផែកំពង់សោមក្រោមតាគ្រិន[106] ការជម្លៀសនៅកំពង់សោមនៅក្នុងខែមេសា ឆ្នាំ១៩៧៥[107] និងតួនាទីរបស់ មាស មុត នៅមុនឆ្នាំ១៩៧៥[108]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីផ្សេងទៀតលើកឡើងអំពីគោលនយោបាយពាក់ព័ន្ធនឹង ប.ក.ក *នៅក្រៅ* វិសាលភាពសិទ្ធិអំណាចរបស់ មាស មុត[109]។

26. ទោះបីជាយ៉ាងនេះក្តី កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាច្រើនពាក់ព័ន្ធនឹងបញ្ហាដែលនៅក្រៅវិសាលភាពនៃសំណុំរឿង ០០៣។ ដីកាសម្រេចលើកលែងការចោទប្រកាន់ខ្លួនឯងបានកំណត់ថា

[104] ឯកសារ **D4.1.408** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន។ ឯកសារ **D4.1.409** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រីន [កំណត់ហេតុទាំងពីរនេះ លើកឡើងអំពីតួនាទីរបស់ មាស មុត នៅក្នុងការចូលរួមចំណែកការធ្វើសេចក្តីសម្រេចបោសសម្អាតភូមិភាគបូព៌ា និងបញ្ជូនកងកម្លាំងទ័ពជើងទឹកពីកំពង់សោមទៅអនុវត្តផែនការ]។ ឯកសារ **D4.1.851** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស រឿន [មាស មុត គឺជាមេបញ្ជាការកងពលធំនៅកំពង់សោម ការពារកោះតាង កោះប៉ូឡូវ៉ៃ]។ ឯកសារ **D4.1.477** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សម្បត្តិ [អ្នកទោសត្រូវបានយកទៅមន្ទីរសន្តិសុខ ទឹក សាប]។ ឯកសារ **D4.1.810** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន [តួនាទីរបស់ មាស មុត នៅក្នុងការបោសសម្អាត និងការកាន់កាប់ខេត្តក្រចេះ]។

[105] ឯកសារ **D4.1.616** ឯកសារ **D10.1.57**។

[106] ឯកសារ **D4.1.431** ឯកសារ **D4.1.432** ឯកសារ **D4.1.434**។

[107] ឯកសារ **D4.1.466** ឯកសារ **D4.1.476** ឯកសារ **D4.1.795** ឯកសារ **D10.1.45**។

[108] **D4.1.786** ឯកសារ **D4.1.819** ឯកសារ **D4.1.846** ឯកសារ **D4.1.911**។

[109] *ឧទាហរណ៍ សូមមើល* ភស្តុតាងអំពីគោលនយោបាយប្រល័យពូជសាសន៍របស់ ប.ក.ក ប្រឆាំងនឹងវៀតណាម៖ ឯកសារ **D4.1.512** ឯកសារ **D4.1.528** ឯកសារ **D4.1.545** ឯកសារ **D4.1.550** ឯកសារ **D4.1.559** ឯកសារ **D4.1.564** ឯកសារ **D4.1.621** ឯកសារ **D4.1.927**។ ស.ព.អ កត់សម្គាល់ថា ទោះបីជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីខ្លះពេលនេះ មានចំណុចពាក់ព័ន្ធបង្ហាញគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំនៅទូទាំងប្រទេសក៏ដោយ ក៏វាពុំស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០៣ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ *សូមមើលផងដែរ* ឯកសារ **D4.1.426** ឯកសារ **D4.1.433** ឯកសារ **D4.1.453** ឯកសារ **D4.1.461** ឯកសារ **D4.1.565** ឯកសារ **D4.1.740** ឯកសារ **D4.1.806** ឯកសារ **D4.1.818** ឯកសារ **D4.1.926** ឯកសារ **D10.1.28** ឯកសារ **D10.1.40** ឯកសារ **D10.1.60**។

កំណត់ហេតុនៃការស្ដាប់ចម្លើយចំនួន ១២៣[110] ពុំពាក់ព័ន្ធទេ[111] ឧទាហរណ៍ កំណត់ហេតុពាក់ព័ន្ធនឹង (i) រយៈកាល ឌុច នៅ ម-១៣[112] (ii) ក្រសួងសង្គមកិច្ច និងមន្ទីរពេទ្យ[113] (iii) ក្រសួងការបរទេស[114] (iv) ការប្រព្រឹត្តិលើជនជាតិចាម[115] (v) សៀមរាប[116] (vi) ភូមិភាគកណ្ដាល[117] (vii) ភូមិភាគពាយ័ព្យ[118] (viii) ភូមិភាគបូព៌ា[119] (ix) ភូមិភាគនិរតី[120] រួមទាំង មន្ទីរសន្តិសុខក្រាំងតាចាន់[121] និង (x) ប្រតិបត្តិការ និងកម្មាភិបាលមជ្ឈិមបក្ស[122]។

110 ជាមួយនឹងលេខនាំមុខ ឯកសារ **D4** និងឯកសារ **D10**។ ឯកសារ ៨ ទៀតគឺ ឯកសារ **D1** ឬ ឯកសារ **D2**។

111 ឯកសារ **D266** ដីកាសម្រេចលើកលែងការចោទប្រកាន់ លេខយោងជើងទំព័រ ៥។

112 ឯកសារ **D4.1.367**។ ឯកសារ **D4.1.369**។

113 ឯកសារ **D4.1.538** ឯកសារ **D4.1.775** ឯកសារ **D4.1.778** ឯកសារ **D4.1.936** ឯកសារ **D4.1.940** ឯកសារ **D4.1.941** ឯកសារ **D4.1.1055** ឯកសារ **D4.1.1047** ឯកសារ **D4.1.938**។

114 ឯកសារ **D4.1.488** ឯកសារ **D4.1.838** ឯកសារ **D4.1.1131** ឯកសារ **D10.1.50**។

115 ឯកសារ **D4.1.410** ឯកសារ **D4.1.411** ឯកសារ **D4.1.412** ឯកសារ **D4.1.413** ឯកសារ **D4.1.417** ឯកសារ **D4.1.424** ឯកសារ **D4.1.482** ឯកសារ **D4.1.519**។

116 ឯកសារ **D4.1.456** ឯកសារ **D4.1.460** ឯកសារ **D4.1.470** ឯកសារ **D4.1.567** ឯកសារ **D4.1.568** ឯកសារ **D4.1.569**។

117 ឯកសារ **D4.1.514** ឯកសារ **D4.1.515** ឯកសារ **D4.1.516** ឯកសារ **D4.1.520** ឯកសារ **D4.1.521** ឯកសារ **D4.1.523** ឯកសារ **D4.1.539** ឯកសារ **D4.1.557** ឯកសារ **D4.1.560** ឯកសារ **D4.1.562** ឯកសារ **D4.1.792** ឯកសារ **D4.1.807** ឯកសារ **D4.1.825** ឯកសារ **D4.1.843** ឯកសារ **D4.1.844** ឯកសារ **D4.1.853** ឯកសារ **D10.1.56**។

118 ឯកសារ **D4.1.422** ឯកសារ **D4.1.423** ឯកសារ **D4.1.438** ឯកសារ **D4.1.440** ឯកសារ **D4.1.447** ឯកសារ **D4.1.448** ឯកសារ **D4.1.462** ឯកសារ **D4.1.464** ឯកសារ **D4.1.478** ឯកសារ **D4.1.551** ឯកសារ **D4.1.815** ឯកសារ **D4.1.1059** ឯកសារ **D4.1.421**។

119 ឯកសារ **D4.1.526** ឯកសារ **D4.1.534** ឯកសារ **D4.1.543** ឯកសារ **D4.1.544** ឯកសារ **D4.1.546** ឯកសារ **D4.1.890** ឯកសារ **D4.1.449**។

120 ឯកសារ **D4.1.536** ឯកសារ **D4.1.540** ឯកសារ **D4.1.812** ឯកសារ **D4.1.912** ឯកសារ **D4.1.1045**។

121 ឯកសារ **D4.1.427** ឯកសារ **D4.1.820** ឯកសារ **D4.1.816**។

122 ឯកសារ **D4.1.628** ឯកសារ **D4.1.769** ឯកសារ **D4.1.833** ឯកសារ **D4.1.850** ឯកសារ **D4.1.856** ឯកសារ **D4.1.924** ឯកសារ **D4.1.928** ឯកសារ **D4.1.1132** ឯកសារ **D4.1.1133** ឯកសារ **D4.1.1135** ឯកសារ **D4.1.1136** ឯកសារ **D4.1.1137** ឯកសារ **D4.1.1149** ឯកសារ **D4.1.1154**។

27. សំខាន់នោះគឺថា កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ ពុំបានលើកឡើងអំពីចំណុចសំខាន់បំផុតនៃសំណុំរឿងប្រឆាំងនឹង មាស មុត ឡើយ ដែលជា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ និងការដ្ឋាននានា និងនៅលើដែនទឹក និងកោះនានា នៅក្នុងខេត្តកំពង់សោមនៃរបបកម្ពុជាប្រជាធិបតេយ្យ និងនៅក្នុងអំឡុងពេលបោសសម្អាតកងពលធំលេខ ១៦៤ (ក្រៅពីជនរងគ្រោះដែលត្រូវបានបញ្ជូនទៅ ស-២១)។ ជាក់ស្ដែង កំណត់ហេតុទាំងនេះមិនពាក់ព័ន្ធនឹងការវិភាគរបស់ដីកាសម្រេចលើកលែងការចោទប្រកាន់ទៅលើផ្នែកនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានពិភាក្សានោះទេ[123]។ ប្រសិនបើការស៊ើបអង្កេតត្រូវបានធ្វើឡើងពេញលេញ ដីកាសម្រេចលើកលែងការចោទប្រកាន់អាចលុបបំបាត់ចំណុចផ្ទុយគ្នា និងសំអាងហេតុដែលខ្វះទៅហើយ ដូចជា សំអាងហេតុពាក់ព័ន្ធនឹងការប្រើប្រាស់វត្តឥន្ទញាណជាមន្ទីរសន្តិសុខ និងតួនាទីរបស់កងពលវរសេនាតូចលេខ ៤៥០ នៅទីនោះ[124]។ ភ័ស្តុតាងដែលរកបាននៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ មានតិចតួច និងមិនសមស្របទាល់តែសោះ ចំពោះការស្វែងយល់ត្រឹមត្រូវអំពីលក្ខណៈ និងមុខងារនៃមន្ទីរសន្តិសុខ[125]។ ផ្អែកលើភ័ស្តុតាងដែលបានដាក់នៅក្នុងសំណុំរឿង

[123] សូមមើល ឯកសារ **D266** ដីកាសម្រេចលើកលែងការចោទប្រកាន់ លេខយោងជើងទំព័រ ៨៨៨-៩១៣ (វត្តឥន្ទញាណ), លេខយោងជើងទំព័រ ៩១៥-៩៣៦ (ស្ទឹងហាវ) លេខយោងជើងទំព័រ ៥០០-៥, ៦៨៨, ៧០១, ៧១៥-១៦, ៨០៣, ៨១៧-៨, ៨២១, ៨២៣-៤, ៨៧១, ៨៨១, ៨៨២-៨៣ (ការបោសសម្អាតកងពលធំលេខ ១៦៤), លេខយោងជើងទំព័រ ៩៣៨-៧២ (ឧក្រិដ្ឋកម្មនៅសមុទ្រ)។ មានតែកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីនៅក្នុងសំណុំរឿង ០០១/០០២ ចំនួន ០៣ ប៉ុណ្ណោះ ត្រូវបានដកស្រង់នៅទីនេះ៖ ឯកសារ **D4.1.849** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យុន គីម។ ឯកសារ **D4.1.244** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ។ ឯកសារ **D4.1.1127** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុត និត្យា ក្នុងនោះ មានតែ ១ ប៉ុណ្ណោះ (ឯកសារ **D4.1.244** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ) ពាក់ព័ន្ធនឹងការចាប់ ឬ ជោគវាសនារបស់ជនបរទេសនៅសមុទ្រ ហើយនេះ គឺនៅ ស-២១។

[124] ឯកសារ **D266** ដីកាសម្រេចលើកលែងការចោទប្រកាន់ កថាខណ្ឌ ២៩១-៣, ២៩៧។ *សូមមើលបន្ថែម* ឯកសារ ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ២១, ១២២-៤។

[125] ឯកសារពាក់ព័ន្ធនៅមុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ រួមមាន៖ ការស្ដាប់ចម្លើយរបស់ ក.ស.ព ចំនួន ៥ ដែលបានដាក់ភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ [ឯកសារ **D1.3.13.1** ចម្លើយរបស់ ប៉ូច កុយ]។ ឯកសារ **D1.3.13.8** ចម្លើយក.ស.ព របស់ ប៉ែន សារិន។ ឯកសារ **D1.3.13.11** ចម្លើយក.ស.ព របស់ សៀង។ ឯកសារ **D1.3.13.12** ចម្លើយក.ស.ព របស់ សុខ ឡាង។ ឯកសារ **D1.3.13.13** ចម្លើយក.ស.ព របស់ តួច សឿលី]។ របាយការណ៍បណ្ដោះអាសន្នស្ដីពីការកំណត់អត្តសញ្ញាណទីតាំង [ឯកសារ **D2/22** របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីតាំង]។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីចំនួនពីរ អនុលោមតាមដីកាចាត់ឲ្យស៊ើបសួរជំនួស D2 ចេញដោយ ស.ច.ស.អ

ក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩[126] និងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងចំនួន ៤ ផ្សេងទៀត[127] យើងអាចយល់ច្បាស់ថា វត្តឥន្ទញាណគឺជាមន្ទីរសន្តិសុខដែលគ្រប់គ្រងដោយកងពលធំលេខ ១៦៤ (កងវរសេនាតូចលេខ ១៦៥/៤៥០) និងអង្គភាពកងកម្លាំងពិសេស ក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ មាស មុត[128] ដែលគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅទីនោះ។

28. ប្រសិនបើគ្មានព័ត៌មាននេះ ដែលមានសារៈសំខាន់ចំពោះការវាយតម្លៃទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត នោះ ការយល់ឃើញរបស់ ស.ច.ស នៅពេលចេញសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ថា មានភាព "សង្ស័យ" ថា មាស មុត ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[129] ត្រឹមតែអាចជាការសន្និដ្ឋាន "បឋម" តែ

Lemonde [ឯកសារ **D2/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ។ ឯកសារ **D2/15** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូច សឿលី]។ ឯកសារមួយត្រូវបានផ្ទេរមកពីក្នុងសំណុំរឿង ០០២ [ឯកសារ **D4.1.745** ចម្លើយរបស់បុរសមិនស្គាល់អត្តសញ្ញាណម្នាក់ ដែលជាឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួនក្នុងសង្គ្រាម ពាក់ព័ន្ធនឹងកងវរសេនាតូច ៣៨៦ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៨]។

126 ជាពិសេស កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ស៊ឹម នី, ប៉ាក សុខ, អែម សុន, ខិន ជុន, នួន យឹម, ហ៊ាង រ៉េត, ឯក នី, សំ ភីន, មូល ឈិន, នាក់ ខឿន៖ ឯកសារ **D54/30** ឯកសារ **D54/32** ឯកសារ **D54/37** ឯកសារ **D54/88** (ស៊ឹម នី) ឯកសារ **D54/25** ឯកសារ **D54/26** (ប៉ាក សុខ) ឯកសារ **D54/46** ឯកសារ **D54/48** (អែម សុន) ឯកសារ **D54/64** I ឯកសារ **D54/65** (ខិន ជុន) ឯកសារ **D54/66** នួន យឹម ឯកសារ **D54/102** ឯក នី ឯកសារ **D54/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ាង រ៉េត ឯកសារ **D54/111** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ឯកសារ **D114/31** ឯកសារ **D114/39** ឯកសារ **D114/40** (មូល ឈិន) ឯកសារ **D114/217** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ខឿន។

127 ឯកសារ **D114/30** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងវត្តឥន្ទញាណ ជាមួយសាក្សី ខិន ជុន និង នួន យឹម ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៤។ ឯកសារ **D114/46** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងកងពលធំកងទ័ពជើងទឹកលេខ ១៦៤ កំពង់សោម ជាមួយសាក្សី ស៊ឹម នី ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥។ ឯកសារ **D114/54** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងវត្តឥន្ទញាណ និងទីតាំងកងពលធំលេខ ១៦៤ ផ្សេងទៀត ជាមួយសាក្សី មូល ឈិន ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥។ ឯកសារ **D114/291** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងកងពលធំ ១៦៤ ផ្សេងទៀត ជាមួយសាក្សី ទូច សឿលី ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦។

128 *សូមមើល* ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ១៥៣, ១៥៥, ២៥២-៥, ៣៦៦, ៤៣២, ៤២៥, ៤៣២, ៤៤១-៤៨០។ ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១២២-១២៤, ១៦៧-១៦៨។

129 ឯកសារ **D266** ដីកាសម្រេចលើកលែងការចោទប្រកាន់ កថាខណ្ឌ ៥២-៣។ *សូមមើលផងដែរ* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៣២។

ប៉ុណ្ណោះ[130]។ ផ្ទុយពីការអះអាងរបស់ មាស មុត[131] រយៈពេល ២០ ខែដែលបានចំណាយលើការសន្និដ្ឋាននេះ និងពេលវេលាដែល ស.ច.ស.ជ បានចំណាយលើការស៊ើបអង្កេតលើ ឌុច និងជនត្រូវចោទនៅក្នុងសំណុំរឿង ០០២ ពុំមានភាពពាក់ព័ន្ធនោះទេ។ កត្តាដែលពាក់ព័ន្ធគឺកិច្ចស៊ើបសួរដែលបានធ្វើឡើង និងខ្លឹមសារនៃសំណុំរឿង ០០៣ ដែលទាំងពីរនេះពិតជាមិនគ្រប់គ្រាន់ដែលធ្វើឱ្យ ស.ច.ស ពុំមាន "សម្ភារឯកសារចាំបាច់ទាំងឡាយ ដែលអនុញ្ញាតឱ្យពួកគាត់អាចសម្រេចថាតើត្រូវចេញ ឬមិនចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[132]។

29. ពុំមានចំណុចណាមួយនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ មាស មុត[133] ដែលផ្ទុយពីជំហររបស់ ស.ព.អ ថា (i) ការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរអនុលោមតាមវិធាន ៦៦(១) គ្រាន់តែជាការជូនដំណឹងតាមនីតិវិធីមួយប៉ុណ្ណោះ ហើយពុំមែនជាការបិទបញ្ចប់កិច្ចស៊ើបសួរនោះទេ[134] (ii) កិច្ចស៊ើបសួរត្រូវបានបញ្ចប់តែតាមរយៈដីកាដំណោះស្រាយដែលបានធ្វើឡើងអនុលោមតាមវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ហើយរហូតដល់ពេលនោះ កិច្ចស៊ើបសួររបស់ ស.ច.ស នៅតែស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដដែល[135] និង (iii) ដោយហេតុថា ស.ច.ស.អ.ប Kasper-Ansermet និង ស.ច.ស.អ Harmon និង Bohlander បានបើកកិច្ចស៊ើបសួរឡើងវិញ ហើយបានបន្តការស៊ើប

[130] ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៤៦។

[131] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៣០-២។

[132] *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៣២។

[133] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៣៣-៥។

[134] *សូមមើល* ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៣៦។ *សូមមើលផងដែរ* Pradel *ក្រមនីតិវិធីព្រហ្មទណ្ឌ* បោះពុម្ពលើកទី១៤ ឆ្នាំ២០០៨-០៩ Ed. Cujas ("Pradel") ថាខណ្ឌ ៦៦៥ [(ការបកប្រែក្រៅផ្លូវការ)] "មាត្រា ១៧៥-១ នៃ [ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង] លើកឡើងថា "នៅពេលយល់ឃើញថាការស៊ើបអង្កេតពេញលេញ ចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿងទៅរដ្ឋអាជ្ញា ហើយជូនដំណឹងដល់ភាគី និងមេធាវីរបស់ភាគី" [...] សំណុំរឿងត្រូវបានបញ្ជូនទៅរដ្ឋអាជ្ញាតាមរយៈដីការបស់ចៅក្រម ដែលមានឈ្មោះថា "ដីកាបញ្ជូនរឿង"។ "ដីកាបញ្ជូនរឿងនេះ" ពុំធ្វើឱ្យចៅក្រមអស់សមត្ថកិច្ចនោះឡើយ"]។

[135] *សូមមើល* ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៣៧។ *សូមមើលផងដែរ* Pradel កថាខណ្ឌ ៦៩៩ [(ការបកប្រែក្រៅផ្លូវការ)] "ដីកាដំណោះស្រាយធ្វើឱ្យចៅក្រម *លែងមានសមត្ថកិច្ចទៀតហើយ* ដូច្នេះហើយវាធ្វើឱ្យបញ្ចប់កិច្ចស៊ើបសួរ"]។ សភាព្រហ្មទណ្ឌតុលាការកំពូល ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៦៩ លេខ ៦៩-៩១.៦១២ [(ការបកប្រែក្រៅផ្លូវការ)] "ដីកាដំណោះស្រាយនេះ ដែលបានសម្រេចថា ការស៊ើបអង្កេតបានបញ្ចប់បិទ ធ្វើឱ្យចៅក្រមស៊ើបអង្កេត *អស់សមត្ថកិច្ច* លើការស៊ើបអង្កេតទាំងមូល"]។

អង្កេតលើសំណុំរឿង ០០៣ នៅមុនពេលចេញដីកាដំណោះស្រាយ ដូច្នេះ ការជូនដំណឹងអនុលោមតាមវិធាន ៦៦(១) នាពេលមុន បានផុតកំណត់ហើយ[136]។

30. មាស មុត បានបង្កើតការបែងចែកសិប្បនិម្មិតមួយរវាង ស.ច.ស នៅពេលគាត់អះអាងថា សេចក្តីជូនដំណឹងអនុលោមតាមវិធាន ៦៦(១) ពុំបានផុតកំណត់សម្រាប់ ស.ច.ស.ជ ទេ។ ស.ច.ស ពុំខុសគ្នាចំពោះវិធីនេះឡើយ ដោយ អ្វីដែលជាបញ្ហានោះគឺដំណើរការនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ រួមទាំង ការដាក់ភ័ស្តុតាងនៅក្នុងសំណុំរឿង[137]។ ជាក់ស្តែង នៅក្នុងសំណុំរឿង ០០៤/១ និង ០០៤/២ ស.ច.ស.ជ បានចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ដោយផ្អែកលើភ័ស្តុតាងដែល ស.ច.ស ប្រមូលបាន។ ទោះយ៉ាងណាក៏ដោយ លក្ខខណ្ឌក្នុងកិច្ចស៊ើបសួរប្រកបដោយប្រសិទ្ធភាព គឺកាតព្វកិច្ចក្នុងការបើកកិច្ចស៊ើបសួរដែលពុំទាន់បានបញ្ចប់[138]។ នៅក្រោយថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១១ សំណើសុំបំពេញកិច្ចស៊ើបសួរ និងការបញ្ជាក់បំភ្លឺអំពីវិសាលភាពនៃសំណុំរឿង ០០៣[139] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ ស.ព.អ[140] និងភ័ស្តុតាងថ្មីៗ

136 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៣៨, ៤០។

137 ឯកសារ **D235/2** ដីកាសម្រេចលើសំណើសុំបង្កើតវិធានការនីតិវិធីជាក់លាក់ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៩៖ ["លើសពីនេះទៀត មិនមានភ័ស្តុតាងបន្ថែមណាមួយអាចត្រូវបានដាក់នៅក្នុងសំណុំរឿងឡើយ បន្ទាប់ពីមានការជូនដំណឹងក្រោមវិធាន ៦៦។ តាមពិត ទោះបីជាការជូនដំណឹងនៃវិធាន ៦៦ ត្រូវបានធ្វើឡើងហើយក៏ដោយ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចថា ខ្លួនចាំបាច់ត្រូវដាក់ភ័ស្តុតាងដាក់បន្ទុក ឬភ័ស្តុតាងដោះបន្ទុកបន្ថែមទៀតទៅក្នុងសំណុំរឿង ពួកគាត់នឹងត្រូវបានតម្រូវឲ្យជូនដំណឹងជាថ្មីម្តងទៀត ក្រោមវិធាន ៦៦ ដដែល"]។ សៀវភៅចំណងជើងថា Guéry & Chambon, *Droit et Pratique de l'Instruction préparatoire* (បោះពុម្ពលើកទី៧) ឆ្នាំ២០១០-ឆ្នាំ២០១១ ទំព័រ ៨៥៥ [(ការបកប្រែក្រៅផ្លូវការ)] "កិច្ចស៊ើបសួរថ្មីមួយដែលបានធ្វើឡើងក្រោយការចេញសេចក្តីជូនដំណឹងដំបូងអំពីការបិទកិច្ចស៊ើបសួរធ្វើឲ្យមានមោឃភាព"]។ សភាព្រហ្មទណ្ឌតុលាការកំពូល ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ លេខ ៩៥-៨២.៣២៥។

138 រឿងក្តី *Brecknell* តទល់នឹង ចក្រភពអង់គ្លេស កថាខណ្ឌ ៦៦-៧១។ *សូមមើលផងដែរ* វិធាន ៧០៖ ["ការបើកការស៊ើបសួរឡើងវិញ៖ នៅពេលមានបន្ទុកថ្មីលេចឡើង បន្ទាប់ពីដីកាលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតបានចូលជាស្ថាពរ ការស៊ើបសួរអាចនឹងត្រូវចាប់ផ្តើមឡើងវិញដោយសហចៅក្រមស៊ើបអង្កេត តាមការផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញា"]។

139 នៅពេលពិចារណាលើការស៊ើបអង្កេតដែលមិនពេញលេញយ៉ាងជាក់ស្តែងគិតត្រឹមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស.ព.អ បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរចំនួន ០៣ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១៖ ឯកសារ **D17** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ របស់ ស.ព.អ។ ឯកសារ **D18** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី២ របស់ ស.ព.អ។ ឯកសារ **D19** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៣ របស់ ស.ព.អ។ សំណើសុំទាំងនេះត្រូវបានច្រានចោលដោយសារ

មានភាពគ្រប់គ្រាន់សម្រាប់ការផ្តល់សេចក្តីជូនដំណឹងមួយដល់ ស.ច.ស.ជ ថា ការស៊ើបអង្កេតពុំទាន់ចប់សព្វគ្រប់ឡើយ។

### គ. ដីកាលើកលែងការចោទប្រកាន់មានកំហុសអង្គច្បាប់ដោយមិនបានពិចារណា និងចេញសេចក្តីសម្រេច ទៅលើគ្រប់អង្គហេតុដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០៣

31. មាស មុត បកស្រាយច្បាប់ដោយមិនត្រឹមត្រូវ និងលើកឡើងខុសអំពីសំអាងហេតុនៃដីកាសម្រេចលើកលែងចោទប្រកាន់ នៅក្នុងការព្យាយាមការពារការខកខានរបស់ខ្លួនក្នុងការចេញសេចក្តីសម្រេចមួយលើទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍មួយចំនួន[141]។ តាមការពិត ដីកាសម្រេចលើកលែងចោទប្រកាន់រំលោភលើកាតព្វកិច្ចរបស់ខ្លួន ក្នុងការចេញសំអាងហេតុ និងសំអាងច្បាប់[142] ពេញលេញលើអង្គហេតុទាំងអស់[143] ដែល ស.ច.ស.អ ទទួលវិនិច្ឆ័យនៅក្នុងដីកាបញ្ជូនរឿងឲ្យ

វិការៈនីតិវិធីនៅក្នុងឯកសារ **D20/3** ដីកាសម្រេចអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១។ សំណើសុំទាំងនេះត្រូវបាន ស.ព.អ ដាក់សាជាថ្មី ក្រោយពេលកែតម្រូវវិការៈនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១។ *សូមមើល* ឯកសារ **D22** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ របស់ ស.ព.អ។ ឯកសារ **D23** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី២ របស់ ស.ព.អ។ ឯកសារ **D24** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៣ របស់ ស.ព.អ។ សំណើសុំទាំងនេះក៏ត្រូវបាន ស.ច.ស ច្រានចោលផងដែរ។ *សូមមើល* ឯកសារ **D17** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ របស់ ស.ព.អ។ ឯកសារ **D26** ដីកាសម្រេចស្តីពីការដាក់សាជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១។ ឯកសារ **D102/1** ចម្លើយតប [របស់ ស.ព.អ] ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យពាក់ព័ន្ធនឹងគុកទឹកសាប ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤។ ឯកសារ **D47/1** ចម្លើយតប [របស់ ស.ព.អ] ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ៦។

140 ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤។

141 (i) មន្ទីរសន្តិសុខទឹកសាប (ii) ការរដ្ឋាន និងសហករណ៍តំបន់រាម (រួមទាំងបិតត្រាង កងកេង និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនានា (iii) ការបោសសម្អាតកងពល ១១៧ និងកម្មាភិបាលតំបន់ ៥០៥ នៅក្នុងខេត្តក្រចេះ (iv) ការបោសសម្អាតកងពលយោធាដទៃទៀត រួមទាំងអ្នកដែលត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ និង (v) ការរៀបការដោយបង្ខំ (ព្រមទាំងការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំផងដែរ)។

142 ទាក់ទងនឹងកាតព្វកិច្ចនៃដីកាលើកលែងចោទប្រកាន់ក្នុងការកំណត់សំអាងហេតុ *សូមមើល ខាងលើ* បន្ថែមទៀត កថាខណ្ឌ ១២-១៧។

143 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣-៤, ២០-៥, ៦៣ និងសេចក្តីដកស្រង់នៅក្នុងបណ្តឹងនោះ។

ស៊ើបសួរ និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[144] *ដែលរួមមាន* កន្លែងទាំងអស់ដែលអង្គហេតុទាំងនោះបានកើតឡើង និងជាប់ពាក់ព័ន្ធខ្លាំង[145]។

32. ផ្ទុយទៅនឹងជំហរពីមុនរបស់ខ្លួន[146] មាស មុត ឥឡូវ ទទួលស្គាល់ថា ទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍ទាំងនេះ លើកលែងតែការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទក្នុងតំបន់កំពង់សោម[147] គឺស្ថិតក្នុងអង្គហេតុដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ[148]។ មាស មុត ទទួលស្គាល់ទៀតថា ស.ច.ស.ជ ត្រូវបានកំណត់ឲ្យ "ពិចារណាលើ [ទីតាំងឧក្រិដ្ឋកម្មនីមួយៗដែលបង្កើតបានជាផ្នែកនៃអង្គហេតុ] ក្នុងការសម្រេចលើអង្គហេតុដែលចៅក្រមទទួលពិនិត្យ"[149]។ ប៉ុន្តែ មាស មុត ជំទាស់ថា ដីកាសម្រេចលើកលែងចោទប្រកាន់ បានបំពេញកាតព្វកិច្ចរបស់គាត់ក្នុងការចេញសេចក្តីសម្រេចលើ "អង្គហេតុ" ទាំងអស់ ពីព្រោះដីកានេះបង្កើតបញ្ជី និងបង្កើតសំអាងហេតុលើអង្គហេតុទាំងអស់ ដែល មាស មុត អះអាងថា ស.ច.ស.ជ

[144] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦៤ និងសេចក្តីដកស្រង់នៅក្នុងបណ្តឹងនោះ។

[145] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦៤។ តុលាការកំពូលបារាំង ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៧ សំណុំរឿងព្រហ្មទណ្ឌលេខ ៧៥-៩១.២២៤។ តុលាការកំពូលបារាំង ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ សំណុំរឿងព្រហ្មទណ្ឌលេខ ១២-៨០.៧៥០។ ឯកសារ **D134/1/10** សាលដីការបស់ អ.ប.ជ លើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ ១៤, ១៩ (ចៅក្រម Beauvallet និងចៅក្រម Bwana)។ ឯកសារ **D165/2/26** សាលដីការបស់ អ.ប.ជ លើសំណើចំនួនប្រាំបួនសុំឲ្យធ្វើមោឃភាពកិច្ចស៊ើបសួរ កថាខណ្ឌ ១៥២ (ចៅក្រម Beauvallet និងចៅក្រម Baik)។

[146] (1) ឯកសារ **D103/1.6** [ពាក់ព័ន្ធនឹងចម្ការធូរេននៅឃុំរាម និងការដ្ឋានបិតត្រាង] (2) ឯកសារ **D137** [ទាក់ទងនឹងការបោសសម្អាតនៅក្នុងខេត្តក្រចេះ (តំបន់ ៥០៥) នៅចុងឆ្នាំ ១៩៧៨] (3) ឯកសារ **D138** ឯកសារ [ទាក់ទងនឹងមន្ទីរសន្តិសុខទឹកសាប (4) ឯកសារ **D139** [ការដ្ឋានពលកម្មដោយបង្ខំ និង មន្ទីរអប់រំកែប្រែកងកេង] (5) ឯកសារ **D141** [ទាក់ទងនឹងរាម]។

[147] ស.ច.ស បានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម លើបទចោទស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈតាមរយៈ ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ កថាខណ្ឌ ២-៤។

[148] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៤១-២។

[149] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៤០-១, ៤៤។

ទទួលពិនិត្យ[150] ហើយ "មិនត្រូវបានតម្រូវឲ្យធ្វើការសម្រេចជាក់លាក់លើទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដែលបង្កើតបាន ជាផ្នែកនៃអង្គហេតុ [ទាំងនោះ] ទេ"[151]។

33. ទោះជាយ៉ាងណាក៏ដោយ បញ្ជីរបស់ដីកាសម្រេចលើកលែងចោទប្រកាន់មិនបានបញ្ចូលអង្គហេតុពាក់ព័ន្ធទាំងអស់ឡើយ ដោយលុបចោលអង្គហេតុទាំងឡាយទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទក្នុងតំបន់កំពង់សោម។ លើសពីនេះទៀត កាតព្វកិច្ចលើដីកាសម្រេចលើកលែងចោទប្រកាន់ក្នុងការមានសំអាងហេតុពេញលេញលើអង្គហេតុទាំងអស់ រួមទាំងកាតព្វកិច្ចក្នុងការបង្កើតសំអាងហេតុ និងសំអាងច្បាប់លើទីតាំងឧក្រិដ្ឋកម្មទាំងអស់ដែលស្ថិតនៅក្នុងអង្គហេតុទាំងនេះ[152]។ ការបង្កើតសំអាងហេតុមួយចំនួនលើផ្នែកផ្សេងៗ មិនគ្រប់គ្រាន់ឡើយ ពីព្រោះថាខកខានមិនបានគិតពេញលេញទៅលើភាពធ្ងន់ធ្ងរនៃសកម្មភាពឧក្រិដ្ឋ ឬកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត។ ការអះអាង របស់ មាស មុត ដែលថា "វាមិនអាចអនុវត្តបានឡើយក្នុងការឲ្យ ស.ច.ស ធ្វើការសម្រេចជាក់លាក់លើទីតាំងឧក្រិដ្ឋកម្មនីមួយៗ ដែលជាផ្នែកនៃអង្គហេតុ"[153] មើលរំលងកាតព្វកិច្ចច្បាស់លាស់របស់ ស.ច.ស.អ ក្នុងការអនុវត្តដូច្នេះ ក៏ដូចជាការបំភ្លឺនានារបស់ ស.ព.អ ពាក់ព័ន្ធនឹងវិសាលភាពនៃការស៊ើបអង្កេត[154]។ ភាពមិនពិតប្រាកដ

150 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៤២ *ដែលយោងទៅ* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៥៤ ជើងទំព័រយោងលេខ ៦៤ [សរសេររៀបរាប់ឈ្មោះ "១. មន្ទីរសន្តិសុខ ស-២១/ ២. មន្ទីរសន្តិសុខ ស-២២/ ៣. ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង/ ៤. សមន្ទីរសន្តិសុខវត្តឥន្ទញាណ/ ៥. ការដ្ឋានវាយថ្មស្ទឹងហាវ/ ៦. ឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ក្នុងដែនទឹក និងដែនកោះ/ ៧. ជម្លោះប្រដាប់អាវុធជាមួយវៀតណាម/ ៨. កងពល ៨០១ និងមន្ទីរឃុំឃាំង ៨១០/ ៩. មន្ទីរសន្តិសុខកងទ័ពបដិវត្តន៍កម្ពុជា និងទីតាំងសម្លាប់ផ្សេងទៀត/ ១០. ការបោសសម្អាតនៅកងពល ១៦៤"]។

151 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៤០។

152 *សូមមើល ខាងលើ* កថាខណ្ឌ ៣១។

153 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៤២។

154 *សូមមើល* ឯកសារ **D1/2/1** ចម្លើយតបរបស់ [ស.ព.អ] ទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ [បញ្ជាក់ថា ស.ច.ស ពុំបានទទួលដោះស្រាយទៅលើមន្ទីរសន្តិសុខដទៃទៀត ដែលចាត់ចែងដោយកងពលធំដទៃទៀតរបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលស្ថិតនៅក្រៅកងពលធំ ១៦៤ ទេ] លើកលែងត្រង់ថា ស.ច.ស បានឈានដល់ការបង្ហាញភស្តុតាងពីសហឧក្រិដ្ឋកម្មរួម ឬការកើតឡើងនៃឧក្រិដ្ឋកម្មដ៏ទូលំទូលាយ និងជាប្រព័ន្ធ]។ ឯកសារ **D102/1** ចម្លើយតប [របស់ ស.ព.អ] ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ទាក់ទងនឹងមន្ទីរសន្តិសុខទឹកសាប ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ [បញ្ជាក់ថា មន្ទីរសន្តិសុខទឹកសាបស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៣]។ ឯកសារ **D47/1** ចម្លើយតប [របស់ ស.ព.អ] ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ៦ [

ពាក់ព័ន្ធនឹងវិសាលភាពត្រូវបានលុបបំបាត់ នៅពេល ស.ព.អ ចេញសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[155]។

34. ទោះបីជា មាស មុត លើកទឡ្ហីករណ៍ផ្ទុយក៏ដោយ[156] ប៉ុន្តែមិនគ្រប់គ្រាន់ក្នុងការបំពេញតាមបទដ្ឋានស្តីពីទស្សនៈដែលមានសំអាងហេតុសម្រាប់ឲ្យ ស.ច.ស "ពិចារណា" ពីទីតាំងឧក្រិដ្ឋកម្មដែលខ្វះជាទូទៅ ដោយពុំបានចេញសំអាងហេតុជាលាយលក្ខណ៍អក្សរ ឬតាមរយៈការទទួលស្គាល់ជាក់លាក់លើភស្តុតាងពាក់ព័ន្ធ។ ចំពោះ មាស មុត "ការពិចារណាគ្រប់គ្រាន់" របស់ដីកាសម្រេចលើកលែងចោទប្រកាន់ ទៅលើភស្តុតាងពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្ម និងហេតុការណ៍ដែលខ្វះ មាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយទាំង ៧ កិច្ចសម្ភាស៍របស់ការិយាល័យសហព្រះរាជអាជ្ញា និងទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យចំនួនមួយ[157] ដែលមានភស្តុតាងទាក់ទិននឹងចម្ការធូរេន មន្ទីរសន្តិសុខទឹកសាប និងការដ្ឋានតំបន់រាម។ គាត់មិនបានយកលេសថា ដីកាសម្រេចលើកលែងចោទប្រកាន់បានពិចារណាទៅលើភស្តុតាងទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅកំពង់សោម ឬការបោសសម្អាតកងពលយោធាដទៃទៀត រួមទាំង ជនរងគ្រោះដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ផងទេ។

35. ការពិចារណាទៅលើភស្តុតាងតិចតួចបែបនេះ ដោយពុំមានសំអាងហេតុពាក់ព័ន្ធ មិនអាចបង្កើតបានជាទស្សនៈដែលមានសំអាងហេតុផល ឬផ្តល់ភស្តុតាងច្បាស់លាស់ និងមានសង្គតភាព អំពីឧក្រិដ្ឋកម្មទាំងអស់ដែលកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មជាច្រើនកន្លែងបែបនេះឡើយ។ ជាការពិតណាស់ គិតត្រឹមថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ សំណុំរឿងស្ទើរតែគ្មានភស្តុតាងដែលពាក់ព័ន្ធជាក់លាក់ឡើយ។ ពិសេស ដីកាសម្រេចលើកលែងចោទប្រកាន់ពឹងផ្អែកលើឯកសារទាំងនេះសម្រាប់បំពេញគោលបំណងផ្សេងទៀត មិនមែនសម្រាប់ទីតាំងឧក្រិដ្ឋកម្មដែលបាត់ទាំងនេះទេ។ [158]។ ការដែលដីកាសម្រេចលើកលែងចោទប្រកាន់ចាត់ទុកភស្តុតាង[159] អំពីអ្នកទោសថៃដែលត្រូវ

បញ្ជាក់ថា ការដ្ឋានបិតត្រាង និងព្រលានយន្តហោះកេងកង និងទីកន្លែងសម្លាប់មនុស្សផ្សេងទៀត ព្រមទាំងចម្ការធូរេនទី១ ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៣]។

155 ឯកសារ **D120** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤។

156 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៤០, ៤២។

157 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៤២ ជើងទំព័រយោងលេខ ២០៤។

158 ឧបសម្ព័ន្ធ ១៖ តារាងឈ្មោះឯកសារយោងនានានៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ ដែលត្រូវបានដកស្រង់ក្នុងឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត ជើងទំព័រយោងលេខ ២០៤។

បានសម្លាប់នៅចម្ការធូរនេខ១ថាមិនពាក់ព័ន្ធ[160] បង្ហាញថា ដីកាសម្រេចលើកលែងចោទប្រកាន់មិនបាន "ពិចារណា" ទៅលើភស្តុតាងទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះផង។

36. ស.ព.អ ទុកឲ្យ អ.ប.ជ[161] សម្រេចថាតើត្រូវពិនិត្យភស្តុតាងឡើងវិញ និងបញ្ចូលសំអាង ហេតុ និងសំអាងច្បាប់ដោយខ្លួនឯង ឬបញ្ជូនរឿងទៅ ស.ច.ស[162]។ នៅក្នុងករណីណាមួយក៏ដោយ ដីកាសន្និដ្ឋានស្ថាពររបស់ភាគី[163] និងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ[164] ផ្តល់ទិដ្ឋភាពទូលំទូលាយអំពីភស្តុតាងពាក់ព័ន្ធទៅនឹងទីតាំង និងហេតុការណ៍ដែលបានបាត់។

## *ឃ. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ និងអង្គហេតុ នៅក្នុងការចាត់ទុកបញ្ជាថ្នាក់លើ ការបង្ខំ និងការគាបសង្កត់ ថាជាកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត*

37. នៅក្នុងការប៉ុនប៉ងផ្តល់យុត្តិកម្មលើការពឹងផ្អែកយ៉ាងច្រើនទៅលើការគាបសង្កត់ ការបង្ខំ និងការបញ្ជាថ្នាក់លើរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ នៅក្នុងការវាយតម្លៃយុត្តាធិការបុគ្គលរបស់ខ្លួន[165] មាស មុត យល់ខុសអំពីច្បាប់ និងខកខានមិនបានបង្ហាញពីកាលៈទេសៈដែលកត្តា

[159] ឯកសារ **D2/17** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន សារឿន ឆ.៧, ១០, ១១, ៤៣។

[160] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រយោងលេខ ៥។

[161] *យោង*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៤៣, ៥២។

[162] មានការបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់អន្តរជាតិថា នៅពេលមានការបង្ហាញថា សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិផ្អែកទៅលើសំអាងហេតុតាមផ្លូវច្បាប់ ឬសេចក្តីសម្រេចលើអង្គហេតុមិនត្រឹមត្រូវ នោះអង្គជំនុំជម្រះតុលាការជាន់ខ្ពស់ត្រូវតែធ្វើមោឃភាពសេចក្តីសម្រេចនោះចោល ហើយត្រូវបញ្ជូនសេចក្តីសម្រេចនោះត្រឡប់ទៅតុលាការជាន់ទាបវិញ ដើម្បីឲ្យអនុវត្តបទដ្ឋានដែលត្រឹមត្រូវ ឬត្រូវដាក់ជំនួសដោយសាលដីការបស់ខ្លួនលើបញ្ហានេះ។ *សូមមើល*ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ជើងទំព័រយោងលេខ ៧ និងសេចក្តីយោងនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ។

[163] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពរ [របស់ ស.ព.អ] អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ("ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ")។ ឯកសារ **D256/11** ចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨។

[164] ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[165] *សូមមើល ឧទា.* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ ជំពូក ៦៖ "សំអាងហេតុ និងសេចក្តីសន្និដ្ឋាន" កថាខណ្ឌ ៤១៥, ៤១៨, ៤២០, ៤២៤, ៤២៨។ *សូមមើលផងដែរ* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ លេខជើងទំព័រយោង ៣៣០-៣៣២, ៣៥៤។ នៅក្នុងចម្លើយតបរបស់គាត់ទៅនឹងមូលដ្ឋានបណ្តឹងឧទ្ធរណ៍ចំណុច ឃ មាស មុត មិនជំទាស់តវ៉ាទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ដែលបានសំអាងលើសេចក្តីសន្និដ្ឋានរបស់ខ្លួនថា គាត់មិនមែនជាជនដែល "ទទួលខុសត្រូវខ្ពស់បំផុត" នៅត្រង់ចំណុចសំខាន់ស្តីពីការយល់ឃើញទាំងនេះទេ។

ទាំងនេះអាចកាត់បន្ថយកម្រិតនៃការទទួលខុសត្រូវរបស់ខ្លួន។ មាស មុត បង្ហាញខុសអំពីភស្តុតាងនៃឆន្ទៈរបស់ខ្លួនក្នុងការចូលរួមទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ក៏ដូចជា កម្រិតនៃស្វយ័ភាព និងការការពារ ដែលគាត់ទទួលបាននៅក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ។

38. ការបង្ខិតបង្ខំត្រូវឱ្យមានការបង្ហាញថា ជនជាប់ចោទ *នោះ* ប្រឈមនឹងការគំរាមកំហែងនៅចំពោះមុខ ដោយការគំរាមកំហែងនេះគឺជាហេតុផលនៃសកម្មភាពរបស់គាត់ និងថា ការគំរាមកំហែងនេះមិនមែនជាលទ្ធផលនៃគោលនយោបាយដែលជនជាប់ចោទខ្លួនឯង ចូលរួមជាមួយនឹងឆន្ទៈ និងដោយសកម្មឡើយ[166]។ ស្រដៀងគ្នានេះដែរ ពុំមានការសម្រាលការទទួលខុសត្រូវ នៅពេលដែលជនជាប់ចោទម្នាក់អនុវត្តបទបញ្ជាថ្នាក់លើដែលពិតជាខុសច្បាប់ ដូចគ្នាអំពើដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ដែលពុំមានការបង្ខំពិតប្រាកដ[167] និង/ឬឆន្ទៈចូលរួមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបទបញ្ជាមិនមានឥទ្ធិពល[168]។ ត្រឹមតែវត្តមាននៃបរិយាកាសគាបសង្កត់[169]ផ្តល់យុត្តិកម្មយ៉ាងច្រើនបំផុតដល់ស្ថានសម្រាលតិចបំផុត ហើយការផ្តល់ទម្ងន់ហួសហេតុគឺជាកំហុសអង្គច្បាប់ ដែលធ្វើឱ្យមោឃភាពសេចក្តីសម្រេច[170]។ ផ្ទុយទៅនឹងការយល់ខុសរបស់

166 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៨៩, ៩៣។ សំណុំរឿង ០០១ ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៥៣, ៥៥៧-៨។ សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៣៦៤។ *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៥-៦, ៥៨-៦៤។

167 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៨៥។ សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៣៦៥ *ដែលសំអាង*លើសាលក្រម *Mrđa* SJ កថាខណ្ឌ ៦៧ (“ការដែលគាត់បានគោរពតាមបញ្ជា ដែលផ្ទុយពីការធ្វើសកម្មភាពតាមការផ្តួចផ្តើមរបស់គាត់នោះ មិនអនុញ្ញាតឱ្យមានស្ថានសម្រាលលើការដាក់ទណ្ឌកម្ម” ដោយពុំមានភ័ស្តុតាងស្តីពីការបង្ខិតបង្ខំនោះឡើយ)។ សំណុំរឿង ០០១ ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៦០៧ (បញ្ជារបស់ថ្នាក់លើអាចសម្រាលដល់ការទទួលខុសត្រូវបាន តែក្នុងករណីដែលជនជាប់ចោទមិនបានត្រៀមខ្លួនអនុវត្តអំពើខុសច្បាប់ដោយបញ្ជាទាំងនោះ “ពិតជាអាចកាត់បន្ថយកម្រិតពិរុទ្ធភាពរបស់គាត់យ៉ាងមានប្រសិទ្ធភាព” ដែលសំអាងលើសាលក្រម *Erdemović* SJ កថាខណ្ឌ ៥៣។ *ផ្ទុយពី*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៥-៧, ៦១, ៦៤។

168 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩២។

169 *សូមមើល ឧទា.* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ ជំពូក ៦៖ “សំអាងហេតុ និងសេចក្តីសន្និដ្ឋាន” កថាខណ្ឌ ៤១៥, ៤២០។ *សូមមើលផងដែរ* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ជើងទំព័រយោងលេខ ៣៥៤។

170 សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៣៦៤, ៣៧១-៣។ *សូមមើល ផងដែរ ឧទា. សាលក្រម* *Tadić* SAJ កថាខណ្ឌ ៤៨ (ការផ្តល់ទម្ងន់មិនត្រឹមត្រូវដល់កត្តាពាក់ព័ន្ធនៅក្នុងការធ្វើសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ អាចជាកំហុសបាន)។ សាលដីកាសម្រេចលើករណីបញ្ជូនរឿងក្តីរបស់ *Mejakić* កថាខណ្ឌ ១០ (កំហុសចំពោះការផ្តល់ទម្ងន់

មាស មុត[171] គាត់មានកាតព្វកិច្ចបង្ហាញពីស្ថានសម្រាល មិនមែនជាកាតព្វកិច្ចរបស់ ស.ព.អ ក្នុងការបង្ហាញពីអវត្តមាននៃស្ថានសម្រាលឡើយ[172]។

39. ផ្ទុយទៅនឹងការអះអាងទាំងឡាយរបស់ខ្លួន[173] មាស មុត មិនបានប្រព្រឹត្តក្រោមការគាបសង្កត់ ឬបង្ខំឡើយ។ គាត់មិនមែនជាកូនទាហានដែលគ្មានភាពសកម្មរបស់របបនោះ ដោយគ្រាន់តែធ្វើតាមបទបញ្ជា និងអនុវត្តជាអប្បបរមាទៅតាមការចាំបាច់ ដើម្បីជៀសវាងការសងសឹកឡើយ។ មាស មុត ជាកម្មាភិបាល ដែលមានទំនាក់ទំនងយ៉ាងល្អ និងមានការការពារយ៉ាងមាំ ដែលបានអនុវត្តគោលនយោបាយ ប.ក.ក តាមមធ្យោបាយគ្រប់យ៉ាង ហើយភាពសកម្មរបស់គាត់ក្នុងការសម្លាប់ និងបោសសម្អាត ធ្វើឱ្យគាត់ទទួលបានការតម្លើងតួនាទីជាញឹកញាប់ និងសិទ្ធិសំខាន់ៗ[174]។ ដោយមិនត្រូវបានបង្ខំឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ដើម្បីបម្រើមេដឹកនាំ ប.ក.ក គាត់ថែមទាំងជាកម្មាភិបាលដែលមានឋានៈខ្ពស់បំផុត និងជាអ្នកដើរតាម និងការពារ ប.ក.ក ដ៏ស្មោះត្រង់បំផុត។ គាត់ប្រើប្រាស់ និងអនុវត្តគោលនយោបាយ ប.ក.ក ជាមួយកងទ័ពជាង ៨៥០០ នាក់ក្រោមការបញ្ជារបស់គាត់[175] ដោយប្រើប្រាស់ស្វ័យភាពដ៏ច្រើនក្នុងការជ្រើសរើសអ្នកដែលត្រូវសម្លាប់ និងទីកន្លែងដែលត្រូវសម្លាប់អ្នកដែលត្រូវបានបញ្ជូនទៅស-២១[176] អ្នកដែលត្រូវចាប់ស្លូរចម្លើយនៅមន្ទីរសន្តិសុខកំពង់សោម និងអ្នកដែលត្រូវធ្វើឱ្យទៅជា

មិនត្រឹមត្រូវដល់ការពិចារណាពាក់ព័ន្ធនានា)។ *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៥, ៥៨-៩, ៦១, ៦៤។

171 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦១។

172 សំណុំរឿង ០០២ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១០៧០។ សំណុំរឿង ០០២ ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៤៣៥២។ *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦១-៦២។

173 *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៥, ៥៨-៩, ៦១-២, ៦៤។

174 ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩០-១, ៩៤ (ជាពិសេស ជើងទំព័រយោងលេខ ៣៧៤), ៩៥-៧, ១០០-៧, ១០៩។ *សូមមើល* សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៣៦៤។

175 ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥៥។ ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៦៤, ១០៨២។

176 ផ្ទុយពីការអះអាងរបស់ មាស មុត នៅក្នុងឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៣ ស.ព.អ បានផ្ដល់ភស្តុតាងជាលម្អិតអំពីការចូលរួមរបស់ មាស មុត នៅក្នុងការកំណត់អត្តសញ្ញាណខ្មាំង និងការបញ្ជូនខ្មាំងទាំងនោះទៅមន្ទីរសន្តិសុខ ស-២១។ *សូមមើល* ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១០៤-៧។ ស.ចៅ.ស.អ បានរកឃើញយ៉ាងច្បាស់ថា មាស មុត "បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការចាប់ខ្លួន និងការ

ទាសករ នៅការដ្ឋានរបស់គាត់[177]។ គាត់ប្រើអំណាចរបស់ខ្លួនក្នុងការបោសសម្អាតផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព[178]។ មាស មុត មិនបានរត់ចោល ប.ក.ក ដូចជាអ្នកមានឋានៈខ្ពស់ដូចគាត់ជាច្រើន ឡើយ ប៉ុន្តែ ផ្ទុយទៅវិញ គាត់ជាមេបញ្ជាការខ្មែរក្រហមចុងក្រោយម្នាក់ដែលផ្តាច់ខ្លួនចុះចូលក្នុង ឆ្នាំ១៩៩៩[179]។

40. មាស មុត មិនអាចបង្ហាញភស្តុតាងណាមួយដែលគាត់អះអាងថាគាត់ស្ថិតនៅក្រោមការគាបសង្កត់ ឬមានការស្មោក់ស្មើរអំពីសកម្មភាពរបស់គាត់ឡើយ ឧទាហរណ៍ថា គាត់ត្រូវបានគម្រាមកំហែងដោយផ្ទាល់ ឬប៉ុនប៉ងលែងចូលរួមក្នុងអំពើឧក្រិដ្ឋ[180]។ ផ្ទុយទៅវិញ នៅឆ្នាំ២០០៨ គាត់សារភាពដោយឯករាជ្យថា ការសោកស្តាយរបស់គាត់មានតែមួយគត់គឺថា របបកម្ពុជាប្រជាធិបតេយ្យមិនទទួលបានជោគជ័យនៅទីបញ្ចប់[181]។ ក្នុងឆ្នាំ២០១៣ គាត់បន្តការពាររបបនោះ[182]។ ទាំងនេះគឺ

បញ្ជូនទៅមន្ទីរ ស-២១"។ ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៥៦៧។ ជនរងគ្រោះសរុបមានចំនួនតិចតួច ដោយសារតែ មាស មុត បានសម្រេចឲ្យគេសម្លាប់មនុស្សភាគច្រើនដោយផ្ទាល់តែម្តង។ *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩៦។

177 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៣០-១, ៩០, ៩៤, ៩៦, ១០០-២, ១០៤-៦, ១០៩, ១២១, ១២៥, ១២៩-៣០, ១៥៧-៨, ១៦៥។

178 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩៥-៦។

179 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩១, ៩៧។

180 *សូមមើល* សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៣៦៤។ ផ្ទុយពីការអះអាងរបស់ មាស មុត នៅក្នុងឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៨ ដីកាសម្រេចលើកលែងចោទប្រកាន់ *ពិតជា* បង្ហាញចម្លើយតែមួយគត់របស់គាត់ ដើម្បីគាំទ្រដល់ការអះអាងទាំងឡាយថា គាត់គ្រាន់តែអនុវត្តទៅតាមបញ្ជាប៉ុណ្ណោះ ទោះបីជាអាចគាំទ្រតិចតួចក៏ដោយ។ *សូមមើល* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៥៦ *ដែលសំអាងលើ* ឯកសារ **D1.3.33.16** ចម្លើយរបស់ មាស មុត កិច្ចសម្ភាសន៍ដោយ C. Chaumeau និង ប៊ូ សារឿន (កាសែតភ្នំពេញប៉ុស្តិ៍) ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ KH ERN 00283080 ទំព័រ ៣ (លើកឡើងថា "អ្នកមានឋានៈតូចតាចត្រូវតែគោរពបទបញ្ជា")។ មាស មុត ពុំបានយោងទៅឧទាហរណ៍ដទៃទៀត ក្រៅតែភស្តុតាងមិនច្បាស់លាស់អំពីការបង្ខិតបង្ខំប៉ុណ្ណោះ។

181 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ជើងទំព័រយោងលេខ ៣៩០ *ដែលសំអាងលើ* ឯកសារ **D1.3.7.8** ចម្លើយរបស់ មាស មុត *អ្វីដែលកន្លងផុតទៅហើយ ឲ្យវាផុតទៅចុះ* (កាសែតឌឺឃែមបូឌាដេលី) ចុះថ្ងៃទី១-២ ខែមីនា ឆ្នាំ២០០៨ EN ERN 00165821។

182 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ជើងទំព័រយោងលេខ ៣៩១ *ដែលសំអាងទៅលើ*ឯកសារ **D114/307.5** ចម្លើយរបស់ មាស មុត ប្រតិចារឹក ("បងធំទីមួយ") (ទូរទស្សន៍ Journeyman.tv) ឆ្នាំ២០១៣ KH ERN 01505960-01505963។

មិនមែនជាពាក្យ ឬសកម្មភាពរបស់មនុស្សដែលស្ថិតនៅក្រោមការគាបសង្កត់ ឬការបង្ខំឡើយ ហើយគ្មានអ្នកវិនិច្ឆ័យដែលមានហេតុផលណាដែលបានពិចារណាលើភស្តុតាងទាំងអស់ អាចសម្រេចខុសពីនេះទេ។ ភស្តុតាងដែលដីកាសម្រេចលើកលែងចោទប្រកាន់[183] និង មាស មុត[184] ផ្អែកលើ ពាក់ព័ន្ធនឹងបរិយាកាសគាបសង្កត់ មិនគ្រប់គ្រាន់ជាបញ្ហាអង្គច្បាប់ក្នុងការសម្រាលការទទួលខុសត្រូវឡើយ[185]។

41. ការកំណត់ដែលមានភាពផ្ទុយគ្នារបស់ដីកាសម្រេចលើកលែងចោទប្រកាន់ទៅលើ មាស មុត និង ឌុច[186] គ្រាន់តែបញ្ជាក់ពីកំហុសទាំងនេះតែប៉ុណ្ណោះ។ ដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់កម្រិតដែល ឌុច អនុវត្តការងាររបស់ខ្លួនក្រោមបញ្ជាថ្នាក់លើ[187] ហើយ តាមការពិត ឌុច ចាត់ចែងការងារតិចជាង មាស មុត ឆ្ងាយណាស់[188]។ មិនតែប៉ុណ្ណោះ មិនដូចនៅទីនោះទេ មានភស្តុតាងច្រើនក្នុងសំណុំរឿង០០១ ដែលថា ឌុច មានការភ័យខ្លាចបាត់បង់ជីវិតរបស់គាត់ និងគ្រួសារ ប្រសិនបើគាត់មិនគោរពបញ្ជាថ្នាក់លើ[189]។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក្តី ក្រោយពីពិចារណាលើភស្តុតាងទាំងអស់នេះ[190] ស.ច.ស ក្នុងសំណុំរឿង ០០១ នៅតែសម្រេចថា ឌុច គឺជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត"[191] ដោយ ពុំមានការកាត់បន្ថយកម្រិតនៃការទទួលខុសត្រូវរបស់គាត់ឡើយ។ ដោយពិចារណាលើភស្តុតាងដូចគ្នានេះ អ.ជ.ស.ដ សម្រេចថា ការអះអាងណាមួយអំពីស្ថានសម្រាលទោសដោយផ្អែកលើការគាបសង្កត់ ឬបញ្ជាថ្នាក់លើ ពុំមានភស្តុតាង

[183] *សូមមើល* ឧទា. ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៥, ៤២០, ៤២៤។

[184] *សូមមើល ឧទា.* ឯកសារ ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៥, ៥៨-៩, ៦១, ៦៤។

[185] *សូមមើល ខាងលើ* កថាខណ្ឌ ៣៨។

[186] *សូមមើល* ឧទា. ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៧១-៤, ៣៩៧, ៤២៧-៨។

[187] *សូមមើល* ឧទា. ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៦៨-៩, ២៧២។

[188] *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១០៨-៩។

[189] *សូមមើល ឧទា.* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១១០។ សំណុំរឿង ០០១ ឯកសារ **D99** *ដីកាបញ្ជូនរឿងទៅជំនុំជម្រះកាំង ហ្គេកអ៊ាវ ហៅ ឌុច* កថាខណ្ឌ ១៦៩-១៧០។ សំណុំរឿង ០០១ ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៥៥, ៥៥៧។ សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៣៦៤-៥។

[190] *សូមមើល ឧទា* សំណុំរឿង ០០១ ឯកសារ **D99** *ដីកាបញ្ជូនរឿងទៅជំនុំជម្រះកាំង ហ្គេកអ៊ាវ ហៅ ឌុច* កថាខណ្ឌ ៣៣, ៤៤, ៥១-៣, ៦៨, ៧០, ៨៥, ៩៩, ១០៧, ១១១, ១២២, ១៦៩-៧០។

[191] សំណុំរឿង ០០១ ឯកសារ **D99** *ដីកាបញ្ជូនរឿងទៅជំនុំជម្រះកាំង ហ្គេកអ៊ាវ ហៅ ឌុច* កថាខណ្ឌ ១២៩។ *សូមមើលផងដែរ* កថាខណ្ឌ ១៥៥។

គាំទ្រឡើយ[192]។ ទោះជាអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់ស្ថានសម្រាល "តិចតួច" ទៅបរិយាកាសគាបសង្កត់ទូទៅ[193] អ.ជ.ត.ក សន្និដ្ឋានថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ ដែលធ្វើដូច្នេះ ដោយហេតុថា ការសម្រាលណាមួយនេះអាចមានតែ "កម្រិតអប្បបរមា" ប៉ុណ្ណោះ[194]។

42. បើទោះបីជា មាស មុត មិនអាចប្រមូលផ្តុំការការពារក្តីតាមគោលការណ៍ចំពោះវិធីសាស្ត្ររបស់ដីកាសម្រេចលើកលែងចោទប្រកាន់ក៏ដោយ ដោយផ្ទុយទៅវិញ គាត់ព្យាយាមផ្តល់យុត្តិកម្ម ពីព្រោះ ឌុច ជា "មនុស្សមិនមានភាពសមហេតុផល" ដែល "សារភាពថា បានប្រព្រឹត្តឧក្រិដ្ឋកម្ម" និង "មិនបានបញ្ជូនរឿងទៅជំនុំជម្រះ" "មានការលើកជាសំណួរមួយចំនួន" ពីព្រោះថាគាត់ត្រូវបាន "ឃុំខ្លួន" រួចទៅហើយ ដូច្នេះគាត់ "ត្រៀមខ្លួនជាស្រេចសម្រាប់ការជំនុំជម្រះក្តី"[195]។ កត្តាទាំងនេះមិនពាក់ព័ន្ធ ហើយមិនអាចពន្យល់ អំពីភាពខុសគ្នាក្នុងការប្រព្រឹត្តិរវាង ឌុច និង មាស មុត ទេ។ ការព្យាយាមប្រៀបធៀបអំពីចំណុចខ្លាំងនៃសំអាងហេតុនៃដីកាសម្រេចលើកលែងចោទប្រកាន់ទៅនឹងសំអាងហេតុក្នុងសំណុំរឿង ០០១ អំពីឌុច[196] មើលរំលងថា (i) ដីកាសម្រេចលើកលែងចោទប្រកាន់បដិសេធមិនពិចារណាលើភស្តុតាងមួយចំនួនធំដែលមានភាពជាក់លាក់ អំពី មាស មុត និង មិនបញ្ចូលសំអាងហេតុលើភស្តុតាងយ៉ាងច្រើនដែលខ្លួនបានពិចារណា[197] និង (ii) ស.ច.ស.អ

[192] សំណុំរឿង ០០១ ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ១៧៦, ៥៥៥-៨, ៦០៧-៨។

[193] សំណុំរឿង ០០១ ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៥៥៨, ៦០៨។

[194] សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៣៦៤, ៣៧៣។

[195] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៧។

[196] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦០។

[197] *សូមមើល ខាងលើ* កថាខណ្ឌ ១២-៣៦។ ជាឧទាហរណ៍ ពុំមានអ្នកវិនិច្ឆ័យប្រកបដោយហេតុផលណាយល់ថា ភស្តុតាងទាំងអស់អាចសន្និដ្ឋានថា មាស មុត ពុំមានអំណាចដែលទទួលបាន ដើម្បីចាប់ខ្លួនខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ និងសម្រេចពីជោគវាសនារបស់ពួកគេនោះឡើយ។ *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១០០-៧។ *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦២-៣។ *ផ្ទុយពី* ការអះអាងរបស់ មាស មុត ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានធ្វើសេចក្តីសម្រេចមួយចំនួន ដែលបង្ហាញពីសិទ្ធិអំណាចរបស់គាត់ក្នុងការចាប់ខ្មាំង និង បញ្ជូនពួកគេទៅមន្ទីរសន្តិសុខ ស-២១។ *សូមមើលផងដែរ* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៨៦-៩, ២២១-៣, ២៥០, ២៨៣-៤, ៣១៦, ៣១៨-៩, ៣២១, ៣២៤-៧, ៥៥៥, ៥៦៧-៩, ៥៧១, ៥៧៣។ *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៣។

ដែលបានពិចារណាលើភស្តុតាងពាក់ព័ន្ធ បានបញ្ចូលសំអាងហេតុ ដែលបង្ហាញថា មាស មុត តាមពិត មានឆន្ទានុសិទ្ធិ និង អំណាច ជាង ឌុច[198]។

43. ការព្យាយាមរបស់ មាស មុត ក្នុងការប្រៀបធៀបរវាងដីកាសម្រេចលើកលែងចោទប្រកាន់ និង ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ[199] មិនអាចទប់ទល់នឹងការពិនិត្យពិច័យឡើយ។ មាស មុត លើកទឡ្ហីករណ៍ត្រង់ចំណុចដែលមិនមានវិវាទ និងផ្អែកលើសំអាងហេតុដែលមិនគ្រប់គ្រាន់ ក្នុងការបង្ហាញថា គាត់ប្រព្រឹត្តដោយផ្ទាល់ក្រោមការគាបសង្កត់[200] ហើយគាត់ធ្វើមិនដឹងមិនឮសំអាងហេតុរបស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានភាពផ្ទុយទៅនឹងការអះអាងរបស់គាត់ ដូចជាសំអាងហេតុដែលពាក់ទាក់ទិននឹងអំណាចសំខាន់របស់គាត់ ស្វយភាព និងឆន្ទានុសិទ្ធិ[201]។ មាស មុត លើកឡើងទៀតថា ដីកាសម្រេចចោទប្រកាន់មានសំអាងហេតុដែលដីកានោះមិនមាន[202] ដោយថ្លែងខុសថា "ស.ច.ស រកឃើញ" នៅពេលពឹងផ្អែកលើសំអាងហេតុពីសំណុំរឿង០០៤/០១

198 *សូមមើល ឧទា.* ឯកសារ **D267** មុត ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥០, ១៥៩, ១៨៦-៩, ២២១-៣, ២៥០, ២៨៣-៤, ៣១៦, ៣១៨-៩, ៣២១, ៣២៤-៧, ៤៦១, ៤៦៤-៥, ៤៦៧, ៤៦៩, ៥៥៥, ៥៦៥, ៥៦៧-៩, ៥៧១, ៥៧៣។ ជាឧទាហរណ៍ វាខុសពី ឌុច ត្រង់ថា ករណីភាគច្រើន មាស មុត មានសិទ្ធិអំណាចសម្រេច*ថាតើ*ត្រូវសម្លាប់កងទ័ព ឬ ជនស៊ីវិលណាម្នាក់នៅកំពង់សោម ឬជនបរទេសដែលចាប់បាននៅក្នុងដែនសមុទ្រដែរឬអត់ មិនមែនត្រឹមតែថាត្រូវសម្លាប់ចោល*នៅពេលណា*ប៉ុណ្ណោះទេ។ *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩០, ៩៤, ៩៦, ១០០-២, ១០៤-៦, ១០៩។*ផ្ទុយពី*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦០។

199 *សូមមើល* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៥, ៥៩, ៦១-៣។

200 *សូមមើល ឧទា.* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៥៥, ៥៩, ៦១។ ឧទាហរណ៍ ជាទូទៅ ពុំមានការជំទាស់តវ៉ាថា ថ្នាក់ក្រោមបានទទួលបញ្ជាពីថ្នាក់លើ ដូចជា នៅក្នុងឋានានុក្រមអង្គការទាំងអស់នោះទេ។ នៅក្នុងករណីណាក៏ដោយ បញ្ហាគឺថាតើ មាស មុត ដែលមិនមែនជាកម្មាភិបាលថ្នាក់ក្រោម បានបំពេញកាតព្វកិច្ចរបស់គាត់ក្នុងការបង្ហាញឲ្យឃើញថា គាត់ខ្លួនឯងផ្ទាល់ស្ថិតនៅក្រោមការគាបសង្កត់ដែរឬអត់។ ការគាបសង្កត់នេះគឺជាមូលហេតុសម្រាប់ឧក្រិដ្ឋកម្មរបស់គាត់ ហើយការគាបសង្កត់នេះមិនមែនកើតចេញមកពីប្រព័ន្ធមួយ ដែលគាត់បានបំពេញតួនាទីយ៉ាងស្ម័គ្រចិត្តនោះឡើយ។ *សូមមើល ខាងលើ* កថាខណ្ឌ ៣៨។

201 *សូមមើល ឧទា.* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥០, ១៥៦, ១៥៨-៩, ១៦១, ១៦៣, ១៦៨, ១៨៦-៩, ២២១-៣, ២៥០, ២៨៣-៤, ៣១៦, ៣១៨-៩, ៣២១, ៣២៤-៧, ៤៦១, ៤៦៤-៥, ៤៦៧, ៤៦៩, ៥៥៥, ៥៦៥, ៥៦៧-៩, ៥៧១, ៥៧៣។

202 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត លេខយោងជើងទំព័រ ២៤៤, ២៧៩-៨០ *ដែលសំអាងលើ*ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៣៩។

មិនមែនសំអាងហេតុជាក់លាក់អំពី មាស មុត ក្នុងសំណុំរឿង ០០៣[203] និងអះអាងថា ស.ច.ស.អ មិនបានរកឃើញថា សុន សេន បានធ្វើប្រតិភូកម្មអំណាចណាមួយទៅ មាស មុត មុនពេលឯកភាពពិតប្រាកដថា តាមការពិត គាត់បានធ្វើ[204]។

***ង. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយមិនគិតគូរដល់ភស្តុតាងអំពីការចូលរួមរបស់ មាស មុត ខណៈដែលផ្តល់ទម្ងន់ហួសហេតុទៅលើការប្រព្រឹត្តិផ្ទាល់ និងភាពក្បៀកកិតផ្ទាល់***

44. មាស មុត អះអាងដោយមិនត្រឹមត្រូវថា ដីកាសម្រេចលើកលែងចោទប្រកាន់បានវាយតម្លៃពេញលេញលើការចូលរួមរបស់គាត់នៅក្នុងឧក្រិដ្ឋកម្មក្នុងគោលបំណងសម្រេចលើយុត្តាធិការបុគ្គល។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានពិចារណាអ្វីមួយឡើយ ក្រៅពីការចូលរួមរបស់ មាស មុត នៅក្នុង "អំពើផ្ទាល់" និងមើលរំលងភស្តុតាងនៃការចូលរួម ដោយសកម្ម និងមានការប្តេជ្ញាចិត្ត នៅក្នុងការអនុវត្តគោលនយោបាយលើសត្រូវរបស់ ប.ក.ក ការធ្វើឱ្យទៅជាទាសករ និងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ដែលគាត់មានសិទ្ធិអំណាច។

45. ទោះជាដីកាសម្រេចលើកលែងចោទប្រកាន់មិនដែលបញ្ជាក់អំពីអ្វីទៅដែលហៅថា "អំពើដោយផ្ទាល់"[205] ភស្តុតាងច្បាស់លាស់ចេញពីការអានដីកាសម្រេចលើកលែងចោទប្រកាន់ទាំងមូលបង្ហាញថា ដីកានេះធ្វើការវាយតម្លៃយុត្តាធិការបុគ្គលដោយលពិចារណាអំពីការប្រព្រឹត្តិដោយផ្ទាល់

[203] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត លេខយោងជើងទំព័រ ២៦៧-៨។

[204] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦២ *ដែលសំអាងលើ*ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៦៣, ៥៧៣។ *សូមមើលផងដែរ* កថាខណ្ឌ ១៥៧, ៣២៤-៧។ ការជំទាស់តវ៉ារបស់ មាស មុត ថា ការចាត់តាំងឱ្យគាត់បញ្ជាប្រតិបត្តិការយោធាជាក់លាក់មួយចំនួន និងធ្វើការបោសសម្អាត មិនមែនជាជាការធ្វើប្រតិភូកម្មអំណាចនោះ គឺជាចម្លើយតបដែលគ្មានតម្លៃអ្វីឡើយ។ *សូមមើល ផងដែរ* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៦៣ ជើងទំព័រយោងលេខ ៣៣៤ *ដែលសំអាងលើ* ឯកសារ **D54/29** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន (ដែលពន្យល់ប្រាប់ថា តួនាទីរបស់ មាស មុត ជា "ជំនួយការ" គឺជួយខាងចាត់ចែងកម្លាំងបង្កើតយុទ្ធសាស្ត្រប្រយុទ្ធ ជួយខាងភ័ស្តុភារ ការផ្គត់ផ្គង់ស្បៀង និងគ្រាប់រំសេវ)។*ផ្ទុយពី*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត ជើងទំព័រយោងលេខ ២៨៥។

[205] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨៖ [សន្និដ្ឋានថា មាស មុត មិនស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ពីព្រោះការចូលរួមរបស់គាត់ "មិនសកម្ម មិនជុំកំភួន និងមិនបានក្បៀកកិតនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទេ" និងដោយសារចំនួនជនរងគ្រោះនៃ "អំពើផ្ទាល់" របស់ មាស មុត តិចជាងករណីរបស់ ឌុច]។

ឬទៅលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ខណៈដែល មាស មុត ស្ថិតនៅកៀកកិត[206]។ នេះគឺជាកំហុសអង្គច្បាប់[207]។ ផ្ទុយទៅនឹងការអះអាងរបស់ មាស មុត ដោយហេតុថា សំអាងច្បាប់ទាក់ទិននឹងទម្រង់នៃការទទួលខុសត្រូវ ពាក់ព័ន្ធទាំងក្នុងការសម្រេចថា ឧក្រិដ្ឋកម្មណាដែល មាស មុត "ទទួលខុសត្រូវ" ផ្នែកព្រហ្មទណ្ឌ និងទាំងក្នុងការវាយតម្លៃពីកម្រិតនៃការចូលរួមរបស់គាត់[208] ស.ព.អ មិនបាន "ដកស្រង់នាំឲ្យយល់ខុសពីយុត្តិសាស្ត្រមិនពាក់ព័ន្ធ"[209] អំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដើម្បីបង្ហាញថា ដីកាសម្រេចលើកលែងចោទប្រកាន់ មានកំហុសដោយមិនយកចិត្តទុក ដាក់ទាល់តែសោះ លើកលែងតែការចូលរួមដោយផ្ទាល់ ឬភាពកៀកកិត[210]។ ប្រសិនបើទម្រង់នៃ ការទទួលខុសត្រូវ ក្រៅពីការចូលរួមដោយផ្ទាល់ រារាំងការសម្រេចថា ជនសង្ស័យ "ទទួលខុសត្រូវខ្ពស់បំផុត" នោះវារារាំងការចោទប្រកាន់ស្ទើរគ្រប់គ្នាទាំងអស់ លើកលែងតែឧបករណ៍ ថ្នាក់ទាបបំផុតនៃរបបឧក្រិដ្ឋកម្ម ដូចជា កម្ពុជាប្រជាធិបតេយ្យនេះ។

46. មាស មុត ព្យាយាមបដិសេធកំហុសរបស់ដីកាលើកលែងចោទប្រកាន់ដោយប្រៀបធៀបលក្ខខណ្ឌតម្រូវមិនស្របច្បាប់របស់ខ្លួនសម្រាប់ការចូលរួមដោយផ្ទាល់ និង/ឬភាពកៀកកិតទៅនឹងឧក្រិដ្ឋកម្ម ជាមួយនឹងការវិភាគលើ "ការចូលរួមដោយផ្ទាល់" របស់ មាស មុត នៅក្នុងក្រិដ្ឋកម្ម[211]។ គាត់កំណត់ "ការចូលរួមដោយផ្ទាល់" ថាជា "អំពើ ឬការប្រព្រឹត្តិជាមូលដ្ឋានរបស់ខ្លួន" ដែលគាត់បញ្ជាក់ដោយត្រឹមត្រូវថា មានលក្ខណៈពាក់ព័ន្ធក្នុងការសម្រេចលើយុត្តាធិការបុគ្គល[212]។ តាមរយៈការធ្វើដូច្នេះ មាស មុត ព្យាយាមផ្តល់ភាពស្របច្បាប់លើសេចក្តីសន្និដ្ឋានរបស់ដីកាដំណោះស្រាយ ដោយសន្មតតាមការវិភាគដែលខ្លួនមិនដែលអនុវត្ត និងដើម្បីសម្រួលដល់ភាពផ្ទុយគ្នា

206 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ២៩៧, ៣០៥, ៣១១, ៣៦៨, ៣៧៣, ៣៩៦-៧, ៤០៥, ៤២៨។

207 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១១៤-៩។

208 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ២៣, ១១៦។

209 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៤ ដែលយោងលើឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១១៣-៦។

210 តាមពិតទៅ មាស មុត ទទួលស្គាល់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់ការចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម មិនតម្រូវឲ្យមានការនៅកៀកកិតដោយផ្ទាល់នោះឡើយ៖ ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៥-៦។

211 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៥, ៦៧, ៦៩, ៧១។

212 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៥, ៦៩។

រវាងការប្រព្រឹត្តិរបស់ ស.ច.ស.ជ លើយុត្តាធិការបុគ្គលក្នុងសំណុំរឿង០០២ និង សំណុំរឿង ០០៣។ ដូចដែលគាត់អះអាង ស.ច.ស បានសម្រេចថា ជនត្រូវចោទក្នុងសំណុំរឿង០០២ ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដោយសារតែការចូលរួមរបស់ពួកគេនៅក្នុង សហឧក្រិដ្ឋកម្មរួម មិនមែនដោយសារការប្រព្រឹត្តិបទល្មើសដោយផ្ទាល់ ឬវត្តមាន នៅទីតាំងឧក្រិដ្ឋកម្មណាមួយនោះទេ[213]។

47. វិធីសាស្ត្រជាក់ស្តែងរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ បានបង្កើត "ការវៀចកមិនសមស្រប"[214] ពីព្រោះក្រោមចំណងជើងសំខាន់ មានតែ "មេដឹកនាំជាន់ខ្ពស់" និង ចារីផ្ទាល់ទេ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ចំណែកអ្នកនៅចន្លោះនោះ ដែលរួមចំណែកយ៉ាងច្រើនដល់ឧក្រិដ្ឋកម្មតាមរយៈទម្រង់នៃការចូលរួមផ្សេងៗទៀត ដូចជា ដើរតួនាទីមិនអាចខ្វះបានក្នុង សហឧក្រិដ្ឋកម្មរួម ដោយរួមចំណែករៀបចំ និងអនុវត្តគោលនយោបាយដោយស្វ័យភាពនៅមូលដ្ឋានដ៏សំខាន់ ឬដោយរៀបចំផែនការ ឬជំរុញឲ្យមានឧក្រិដ្ឋកម្មពីទីបញ្ជាការដ្ឋានមជ្ឈិម ឬ តំបន់ មិនត្រូវបានរាប់បញ្ចូល[215]។ ជាលទ្ធផលនៃកំហុសទាំងនេះ ដីកាសម្រេចលើកលែងចោទប្រកាន់ ផ្តោតត្រឹមតែលើការជ្រើសរើសដ៏ចង្អៀតនូវអំពើ និងការប្រព្រឹត្តិ[216]របស់ មាស មុត និង មើលរំលងថា មាស មុត គឺជាចារីប្រភេទនេះ ដែលកាន់អំណាចដ៏ធំសម្បើមនៅថ្នាក់មជ្ឈិម និង ថ្នាក់មូលដ្ឋាន ដែលគាត់ប្រើដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។

[213] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៨។ *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១១៨។

[214] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៧ *ដែលសំអាងលើ* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១១៧។ មាស មុត ដកស្រង់ខុសពីសម្តីរបស់របស់ ស.ព.អ។ ស.ព.អ លើកឡើងថា ដីកាសម្រេចលើកលែងចោទប្រកាន់ បានបង្កើត *"ភាពដាច់ដោយឡែកពីគ្នាមិនសមហេតុផល"* មិនមែនបង្កើត *"ភាពដាច់ដោយឡែកពីគ្នាដោយខុសច្បាប់"* រវាង "មេដឹកនាំជាន់ខ្ពស់" ជាមួយនឹង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។

[215] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤០៥ ["បុគ្គលដែលនឹងស្ថិតចូលក្នុងយុត្តាធិការរបស់ អ.វ.ត.ក ពិតជាមានចំនួនតិចតួចបំផុត ដោយសំដៅតែទៅលើមេដឹកនាំជាន់ខ្ពស់ដែលមានអំណាច និងជនដែលទទួលខុសត្រូវខ្ពស់បំផុត ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ឬកៀកជិតនឹងទង្វើប្រព្រឹត្តតាមរយៈអំណាច និង ឥទ្ធិពលជាក់ស្តែង"]។ *សូមមើលផងដែរ* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១១៥-៨។

[216] *ផ្ទុយពី*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៦, ៧០។

48. មិនត្រឹមតែមិនបានវាយតម្លៃពេញលេញលើ "ការចូលរួមដោយផ្ទាល់"របស់ មាស មុត ប៉ុណ្ណោះទេ ប៉ុន្តែ ដីកាសម្រេចលើកលែងចោទប្រកាន់ថែមទាំងខកខានមិនបានពិចារណាលើភស្តុតាងដែលថា មាស មុត ចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងអនុវត្តសហឧក្រិដ្ឋកម្មរួមក្នុងការបោសសម្អាត ឃុំឃាំង និងសម្លាប់ខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ និង បង្កើត និងប្រតិបត្តិការសហករណ៍ និង ការដ្ឋានពលកម្មដោយបង្ខំ ដែលនៅទីនោះ យោធា និងជនស៊ីវិលត្រូវបានធ្វើឱ្យទៅជាទាសករ[217]។ គាត់មានអំណាចពេញលេញក្នុងការចាប់ និងកម្ទេចជនបរទេស ដែលចាប់បាននៅសមុទ្រ ទាហាន ក្នុងកងពល១៦៤ និងអ្នកដែលត្រូវបានសន្មតថាជាខ្មាំងនៅតំបន់ស្វយ័តកំពង់សោម។ មាស មុត គឺជាអ្នកបង្កើត និងចូលរួមក្នុងយន្តការកំណត់អត្តសញ្ញាណខ្មាំងតាមការសន្មត ដែលក្រោយមក គាត់បញ្ជាឱ្យចាប់ខ្លួន និងបញ្ជូនមួយចំនួនទៅមន្ទីរស២១[218]។ ពេញមួយរបបនោះ មាស មុត បាន ទៅទស្សនកិច្ច និងដើរតួនាទីដោយផ្ទាល់ និងយ៉ាងសកម្មនៅក្នុងប្រតិបត្តិការមន្ទីរសន្តិសុខ និងការ ដ្ឋានតំបន់កំពង់សោម និងបានត្រួតពិនិត្យការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងគោល នយោបាយផ្សំដំណោកដោយបង្ខំ[219]។ ក្រោយពេលតម្លើងតួនាទីជាអនុលេខានៃសេនាធិការ គាត់ បានអនុវត្តការបោសសម្អាតកម្មាភិបាលតំបន់ ៥០៥ និងកងពលមជ្ឈិមនៃកងទ័ពបដិវត្តកម្ពុជា ១១៧ មុនពេលគ្រប់គ្រងតំបន់ និងកងពលនោះ និងចាត់តាំងកម្លាំងកងពល ១៦៤[220]។

49. សម្រាប់ហេតុផលទាំងនេះ និងហេតុផលផ្សេងទៀតដែលបានរៀបរាប់ខាងក្រោម[221] សំអាងហេតុ ដែលថា តួនាទីរបស់គាត់ជាលេខាកងពល ១៦៤ កម្រិតត្រឹមតែ "កិច្ចការនយោបាយ" និង "ផ្សព្វផ្សាយគោលនយោបាយ ប.ក.ក" មានកំហុសជាក់ស្តែង ហើយការពឹងផ្អែករបស់ មាស មុត លើចំណុចនេះក៏ជាការមិនត្រឹមត្រូវដែរ[222]។ លើសពីនេះទៀត ទោះបីជា មាស មុត ព្យាយាម ពិព័ណ៌នាសំអាងហេតុរបស់ ស.ច.ស.អ ក្នុងផ្លូវអវិជ្ជមាន ដើម្បីឱ្យស្របតាមការសន្និដ្ឋានរបស់

217 ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ២៦៤-៣, ៩៦, ៩៨-១០៧, ១២១-៣៤។

218 ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៩៦, ៩៨-១០៧។

219 ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១២២-៣៣។

220 ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៧៩, ១០០, ១០៤, ១៣២-៣, ១៤៦, ១៦៩។

221 *សូមមើល ខាងក្រោម* កថាខណ្ឌ ៥១។

222 *ផ្ទុយពី*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៦ *ដែលសំអាងលើ*ឯកសារ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៦, ៤២២។

ដីកាសម្រេចលើកលែងចោទប្រកាន់[223] ស.ច.ស.អ មានហេតុជាច្រើនទាក់ទិននឹងតួនាទីផ្ទាល់ និងសកម្មរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្ម និងវត្តមានរបស់គាត់នៅទីតាំងឧក្រិដ្ឋកម្ម និង ហេតុការណ៍ឧក្រិដ្ឋកម្ម[224] និងការចូលរួមរបស់គាត់ក្នុងការរៀបចំ និងអនុវត្តគោលនយោបាយសហឧក្រិដ្ឋកម្មរួម[225]។

## *ច. ដីកាលើកលែងចោទប្រកាន់មានសំអាងហេតុដែលមានកំហុស ដែលជាកត្តាកំណត់លើយុត្តាធិការបុគ្គល*

### លេខាកងពល១៦៤ និងតំបន់ស្វយ័តកំពង់សោម

50. មាស មុត ទទួលស្គាល់ថា ដីកាសម្រេចលើកលែងចោទប្រកាន់បានរកឃើញថា គាត់គឺជាមេបញ្ជាការកងពល ១៦៤ "យ៉ាងហោចណាស់រវាងខែមករា ឆ្នាំ១៩៧៦ និងខែមេសា ឆ្នាំ១៩៧៨ និងជាប្រធានក្រុងកំពង់សោម"[226] និងថា ដីកានោះមិនបានបញ្ជាក់ពីកាលបរិច្ឆេទចុងក្រោយនៃតួនាទីរបស់ មាស មុត ឡើយ[227]។ គាត់ទទួលថា ដីកាសម្រេចលើកលែងចោទប្រកាន់ពុំបានមានសំអាងហេតុដែលថា មាស មុត មិនទទួលបន្ទុកវរសេនាធំ ចំណុះកងពល ១៦៤ ក្រោយខែមេសា ឆ្នាំ១៩៧៨[228] និង "មិនបានសន្និដ្ឋានដោយប្រាកដប្រជា" អំពីរយៈកាលនៃការគ្រប់គ្រងរបស់ មាស មុត ក្នុងកំពង់សោម[229]។ មាស មុត បានយល់ស្របថា ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានផ្ដល់ទស្សនៈដែលមានភាពស្របគ្នា និងមានសំអាងហេតុ ហើយ *មិនមានសំអាងហេតុ* ដែលថា រយៈកាលគ្រប់គ្រងរបស់ មាស មុត ក្នុងកំពង់សោម ចាប់ផ្ដើមមុនខែមករា ឆ្នាំ១៩៧៦ ឬបន្តក្រោយពីខែមេសាឆ្នាំ១៩៧៨។ ភស្តុតាងដែលលើកមកសំអាងនៅក្នុងដីកាសម្រេច

[223] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៧០។

[224] *សូមមើល ឧទា.* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥៦-៦៣, ១៧១, ១៨៨, ១៩២, ១៩៥, ២០៥, ២១៨-២១, ២៣០, ២៣៨-៩, ២៥០, ២៦៨, ២៧៣-៥, ២៨៦, ៣២៤-៧, ៣៣៦, ៣៥៤, ៣៦១-៣, ៣៦៥, ៤០២, ៤៦៣-៨, ៤៧៧, ៥៦២-៧៧។

[225] *សូមមើល ឧទា.* ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៧៨, ១៨០, ១៨៦, ១៨៨, ១៩៥, ២០១។

[226] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ១៣៧-៨ *ដែលសំអាងលើ*ឯកសារ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៨៨ [ពុំមានលើកពីតួនាទីរបស់គាត់ជាប្រធានក្រុងកំពង់សោមនោះទេ]។

[227] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៧៦។

[228] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៧៦។

[229] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៧៤។

លើកលែងចោទប្រកាន់ រួមជាមួយនឹងចំណុចនោះ បានបន្ថែមទៅលើសំណុំរឿងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ធ្វើឱ្យគ្មានមន្ទិលឡើយថា មាស មុត គឺជាលេខាកងពលលេខ៣ កងពល១៦៤ លេខាតំបន់ស្វយ័តកំពង់សោមពេញរបបកម្ពុជាប្រជាធិបតេយ្យ[230] ហើយដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុ។

51. ក្នុងចម្លើយតបរបស់ខ្លួន មាស មុត ព្យាយាមបន្ថយតួនាទីរបស់គាត់តាមរយៈសំអាងហេតុនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ថា គាត់ "ទទួលបន្ទុកកិច្ចការនយោបាយ" និង ថា សកម្មភាពរបស់គាត់មានដូចជា ផ្សព្វផ្សាយគោលនយោបាយ ប.ក.ក"[231]។ ប៉ុន្តែ គាត់មើលរំលងថា ចំណុចនេះក៏ជាកំហុសផងដែរ[232]។ ពាក្យថា "មេបញ្ជាការកងពល" "លេខា" ឬ "ប្រធាន" និង "ស្នងការនយោបាយ" "លេខានយោបាយ" ឬ "អ្នកទទួលបន្ទុកកិច្ចការនយោបាយ" ត្រូវបានប្រើជំនួសគ្នាទៅវិញទៅមក ដោយសាក្សី ក្នុងការចាត់តាំង មាស មុត ជាកម្មាភិបាលដែលមានសិទ្ធិអំណាចផ្លូវការខ្ពស់បំផុត និងមានប្រសិទ្ធភាព នៅក្នុងជួរកងពល ១៦៤ នៃកងពលមជ្ឈិមនៃកងទ័ពបដិវត្តន៍[233]។ មាស មុត គ្រប់គ្រងកងពលទាំងអស់ដែលប៉ះពាល់ដល់តំបន់ប្រតិបត្តិការរបស់កងពល១៦៤[234] និងការពឹងផ្អែករបស់ ដីកាសម្រេចលើកលែងចោទប្រកាន់លើភស្តុតាងដែលថា

[230] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣៨-៤០។

[231] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៦ *ដែលសំអាងលើ*ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១៦, ៤២២។ ពុំមានលើកឡើងពីប្រភពនានានៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដើម្បីគាំទ្រដល់កថាខណ្ឌ ៤២២ នោះទេ។

[232] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣៧, ១៤១។

[233] *យោង*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៦។ *សូមមើល ឧទា.* ឯកសារ **D2/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ឆ.២៧, ៣២, ៣៥-៦ [ជាពិសេស ឆ.៣៦៖ ក្នុងគណៈដឹកនាំអ្នកដែលខ្ពស់ជាងគេ គេហៅថា ស្នងការ/ប្រធាន ដែលគេហៅថា លេខារបស់បក្ស ដែលជាអ្នកគ្រប់គ្រងអង្គភាពទាំងមូល]។ ឯកសារ **D54/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.១, ១៩ [និយាយយ៉ាងច្បាស់ថា មាស មុត គឺជាស្នងការនយោបាយ និងជាមេបញ្ជាការកងពល]។ ឯកសារ **D2/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញូង ជ្រោង ឆ.១០។ ឯកសារ **D114/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង ស៊ុំ ឆ.១៣៥។ ឯកសារ **D54/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៤៥។

[234] ឯកសារ **D54/43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ឆ.៤ ["ក្នុងនាមជាស្នងការនយោបាយ មាស មុត ទទួលខុសត្រូវទាំងអស់របស់កងពលលេខ៣ រួមមាន ការអប់រំនយោបាយចំពោះយោធា ចាត់តាំង និងបញ្ជាមេបញ្ជាការកងវរៈសេនាធំទៅតាមសមរភូមិ ទទួលខុសត្រូវស្បៀងអាហារ និងភ័ស្តុភាររបស់កងពល]។ ឯកសារ **D54/24**

មុនពេលចាប់ខ្លួន ហ៊ឹង ឌឿន ហៅ ឌឹម គឺជាអនុរបស់ មាស មុត ទទួលបន្ទុកយោធាកងពល ១៦៤[235] មិនត្រឹមត្រូវឡើយ។ សាក្សីក្នុងសំណុំរឿង ០០៣ សុទ្ធតែរម្លឹកថា ឌឹម តែងតែអនុវត្ត តាមការបង្គាប់ និងសិទ្ធិអំណាចរបស់ មាស មុត[236]។

52. ក្នុងការវាយតម្លៃទាំង "ភាពធ្ងន់ធ្ងរ" និង "កម្រិតទទួលខុសត្រូវ"របស់ មាស មុត ចំពោះឧក្រិដ្ឋកម្ម ទាំងនោះ ដែលរួមមាន អំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និង ការដាក់ពន្ធនាគារ ដែលប្រព្រឹត្តិលើបុគ្គលិកយោធា និងប្រជាជនស៊ីវិលរាប់ពាន់នាក់ក្នុងកំពង់សោម និង ដែនទឹក និងបណ្តាកោះរបស់របស់កម្ពុជាប្រជាធិបតេយ្យ ឥទ្ធិពលនៃការកាត់បន្ថយវិសាលភាពពេលវេលានៃការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មនៅត្រឹម ១៨ ខែ[237]មិនអាចប្រកែកបានឡើយ[238]។ លើសពីនេះទៀត ការលុបចោលរយៈពេលមុនខែមករា ឆ្នាំ១៩៧៦ គឺមើលរំលងការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមរបស់ មាស មុត តាមរយៈការបង្កើតការដ្ឋាន និងមន្ទីរសន្តិសុខក្នុងកំពង់សោម និងប្រព័ន្ធត្រួតពិនិត្យដទៃទៀត ក្នុងការកំណត់អត្តសញ្ញាណខ្មាំង ជាពិសេសក្នុងចំណោម កងកម្លាំងកងពល ១៦៤ របស់គាត់ផ្ទាល់។

កំណត់ហេតុ នៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.២០។ ឯកសារ **D54/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ើ រ៉េត ឆ.១២។ ឯកសារ **D114/89** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.១៥, ៦៦។

235 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៩០។ ប្រភពចម្បងៗដែលបានយោងនៅក្នុងជើងទំព័រយោងលេខ ៥៨៦ លើកឡើងថា ឌឹម មកពីភូមិភាគបូព៌ា ជាអនុប្រធានកងពល ទទួលបន្ទុកខាងយោធា។ គួរកត់សម្គាល់ថា កថាខណ្ឌ ៤១៦ នៃដីកាសម្រេចលើកលែងចោទប្រកាន់ (ដែលត្រូវបានបង្ហាញក្នុងឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦៦) យោងផ្ទាល់ទៅលើកថាខណ្ឌ ១៩០ នេះ។

236 *សូមមើលផងដែរ* ឯកសារ **D114/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ឆ.៦៦ ["សុទ្ធជាអ្នកនៅក្រោម មាស មុត [...] ឌឹម នៅក្រោម មាស មុត នៅថ្នាក់កងពល"]។ ឯកសារ **D54/97** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ឆ.១៤ ["ពួកគេទាំងពីរធ្វើការជាមួយគ្នា តែ មាស មុត ជាមេបញ្ជាការកងពល ហើយ ឌឹម ជាអនុរបស់ មាស មុត"]។ ឯកសារ **D54/87** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ឆ.៨៦ ["មេបញ្ជាការកងពល១៦៤ ឈ្មោះ មាស មុត ទទួលបន្ទុកកិច្ចការនយោបាយ។ ឌឹម មេបញ្ជាការរងកងពលទទួលបន្ទុកកិច្ចការយោធា។ ឆាន ទទួលបន្ទុកខាងមេបញ្ជាការរង"]។ ឯកសារ **D114/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡន (ណាំ ឡន) ឆ.៤៤។ ឯកសារ **D114/79** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង ស៊ុំ ឆ.៣៣។ ឯកសារ **D114/230.1.1** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស រៀងទី ១៦២៤ [អនុលេខាកងពល ១៦៤]។

237 ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៥ មានរយៈពេល ៨ ខែកន្លះ។ ពីខែមេសា ឆ្នាំ១៩៧៨ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩ មានរយៈពេល ៩ ខែ។ របបកម្ពុជាប្រជាធិបតេយ្យមានអាយុ ៤៤ ខែកន្លះ។

238 *ផ្ទុយពី*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៧៧។

53. វាក៏មានឥទ្ធិពលទៅលើការវាយតម្លៃរបស់ដីកាសម្រេចលើកលែងចោទប្រកាន់លើមុខតំណែង មាស មុត នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ជាលេខានៃកងពលកងទ័ពបដិវត្តធំជាងគេបង្អស់ និងតំបន់ស្វយ័តក្នុងពេលដំណាលគ្នាពេញមួយរបបនោះ។ នេះគឺជាមុខតំណែងដែលមិនធ្លាប់មានពីមុនមកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ នៅពេលដែលមេដឹកនាំ ប.ក.ក បោសសម្អាតក្នុងជួររបស់ខ្លួន មានតែវរជនមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានតម្លើងតួនាទី និងផ្តល់ការទទួលខុសត្រូវកាន់តែច្រើនឡើងលើផ្នែកផ្សេងៗនៃទឹកដីកម្ពុជាប្រជាធិបតេយ្យ។ ការដែលថា មាស មុត រក្សាបានការគ្រប់គ្រងកំពង់សោម ខណៈដែលត្រូវតែងតាំងឲ្យដឹកនាំបញ្ជាតំបន់ ៥០៥ និងកងពល ១១៧ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨[239] បង្ហាញថា គាត់គឺជាកម្មាភិបាលដែលទទួលបានការទុកចិត្តម្នាក់។

## តំណែង និងតួនាទីរបស់ មាស មុត នៅសេនាធិការ

54. មាស មុត ខកខានមិនបានផ្តល់ភស្តុតាងគាំទ្រដល់ការអះអាងរបស់គាត់[240]ថា ដីកាសម្រេចលើកលែងចោទប្រកាន់មិនមានកំហុសពាក់ព័ន្ធនឹងតួនាទីរបស់គាត់នៅសេនាធិការនៅពេលដែល (i) សម្រេចថា មាស មុត មិនមែនជាសមាជិកនៃសេនាធិការចាប់តាំងពីការបង្កើតកងពលមជ្ឈិមរបស់កងទ័ពបដិវត្តកម្ពុជាក្នុងខែ កក្កដា-សីហា ឆ្នាំ១៩៧៥[241] និង (ii) ខកខានមិនបានមានសំអាងហេតុពាក់ព័ន្ធនឹងតួនាទីរបស់គាត់ជាអនុលេខានៃសេនាធិការចាប់ពីចុងឆ្នាំ១៩៧៨[242]។

55. ការយោងរបស់ មាស មុត ទៅលើចម្លើយប៉ាន់ស្មានមួយនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា មាស មុត *អាច* ត្រូវបានតែងតាំងជាជំនួយការនយោបាយនៃសេនាធិការ[243] ដែលនៅក្នុងករណីណាក៏ដោយ បានផ្ទុយគ្នានៅកន្លែងផ្សេងទៀតក្នុងដីកាសម្រេចលើកលែងចោទ

239 *សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣៣។

240 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៧៩-៨១។

241 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៣, ៤១៨។ ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤២-៥។

242 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៣, ៤១៨។ ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤៦-៧។

243 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៨០ *ដែលសំអាងលើ*ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦២។ សម្រាប់ការពិភាក្សាអំពីការលើកឡើងនេះ*សូមមើល* ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤៥។

ប្រកាន់[244] មិនអើពើ[245] ដូចដីកាសម្រេចលើកលែងចោទប្រកាន់ដែរ ទៅលើភស្តុតាងលើសលប់ ដែលថា ក្នុងនាមជាមេបញ្ជាការកងពលមជ្ឈិម និងប្រធានកងទ័ពជើងទឹក មាស មុត គឺជាសមាជិកនៃសេនាធិការ ដោយគ្មានការសង្ស័យ ចាប់ពីខែកក្កដា ឬសីហាឆ្នាំ១៩៧៥[246]។ ការដែលថា មាស មុត ត្រូវបានលុបចេញពីកំណត់ត្រារបស់មហាសន្និបាតបក្សឆ្នាំ១៩៧៨[247] មិនមែនជាការសម្រេចឡើយ។ លើសពីនេះទៀត មាស មុត បង្ហាញប្រភេទឯកសារខុស គឺ វាមិនមែនជា "ឯកសារកម្ពុជាប្រជាធិបតេយ្យ" ផ្លូវការ "ដែលចេញ" ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ឡើយ។ វាគឺជាប្រតិចារឹកនៃ "ឯកសារសរសេរដោយដៃនៅក្នុងសៀវភៅសរសេររបស់បុគ្គលម្នាក់ដែលគេសង្ស័យថាជា អៀង សារី"[248] ហើយទំនងជាមានការលុបដោយចេតនាផង។

56. ភស្តុតាងពាក់ព័ន្ធនឹងការតែងតាំង មាស មុត ជាអនុប្រធានសេនាធិការ មិនអាចត្រូវបានកម្រិតត្រឹម ដូចដែល មាស មុត[249] ធ្វើនោះទេ កំណត់ហេតុស្តាប់ចម្លើយមួយរបស់ ឌុច ឡើយ ដែល ឌុច ពិភាក្សាតែអំពីតួនាទីរបស់គាត់ជាសមាជិកសេនាធិការប៉ុណ្ណោះ។ ផ្ទុយទៅនឹងការអះអាងរបស់ មាស មុត[250] ស.ច.ស.អ មិនអះអាងដូច្នេះឡើយ។ ដូច ស.ព.អ ដែរ[251] គាត់លើកភស្តុតាងក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ មួយចំនួន ដែលបញ្ជាក់ពីការតម្លើងមុខតំណែង មាស មុត

[244] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៥៧ ["កម្មាភិបាលដែលអាចក្លាយជាជំនួយការរបស់សេនាធិការ គឺកម្មាភិបាល 'ត្រឹមវរៈសេនាតូច និងវរៈសេនាធំ' ហើយ សុន សេន និង*លេខាកងពល*អាចជួយអប់រំពួកគេបាន] (មានសេចក្តីបញ្ជាក់បន្ថែម)។

[245] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៨០ ["ការគ្មានភ័ស្តុតាងផ្ទុយដែលគួរឲ្យជឿជាក់បាន"]។

[246] ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ជើងទំព័រយោងលេខ ១៥៨, ១៦៦-៧។ ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤២-៥ ជើងទំព័រយោងលេខ ៥៨១, ៥៨៣-៥, ៥៨៧, ៥៩០, ៥៩៦។

[247] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៨០ *ដែលសំអាងលើ*ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១៦៣ និងការសំអាងរបស់ឯកសារនេះទៅលើ ឯកសារ **D4.1.649** ស្តីពីសមាជលើកទី៥របស់ ប៉ុល ពត-អៀង សារី ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨។

[248] ឯកសារ **D4.1.649** ស្តីពីសមាជលើកទី៥របស់ ប៉ុល ពត-អៀង សារី ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ KH ERN 00800744-00800745។

[249] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៨១។

[250] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៨១។

[251] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ជើងទំព័រយោងលេខ ៥៨៨, ៥៩៧ *ដែលសំអាងលើ*ឯកសារ **D256/7** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ កថាខណ្ឌ ៥២-៣, ៥៦-៨ (ពិសេស ជើងទំព័រយោងលេខ ១៦០-១, ១៦៨, ១៧២-៧)។

ជាអនុលេខាសេនាធិការ[252]។ សពអ (និង ស.ច.ស.អ) សុទ្ធតែបានអះអាងថា មាស មុត គឺជាអនុសេនាធិការ បានតែរយៈពេល ៥០ ថ្ងៃប៉ុណ្ណោះ[253]។ មាស មុត មើលរំលងភស្តុតាងជាច្រើនដែលបញ្ជាក់ថា មាស មុត ត្រូវបានតែងតាំងជាអនុសេនាធិការ មិនក្រោយខែកញ្ញា ឬតែតុលាទេ ពោលគឺ ចុងឆ្នាំ ១៩៧៨[254]។

57. តួនាទីរបស់ មាស មុត ជាសមាជិក និងជាអនុប្រធាន គ្មានអ្វីគួរឱ្យសង្ស័យទេថា មានឥទ្ធិពលជាកត្តាកំណត់លើកម្រិតនៃការទទួលខុសត្រូវរបស់គាត់[255]។ នៅក្នុងសេនាធិការ សមាជិកទាំងអស់រួមទាំង មាស មុត ផង បានចូលរួមក្នុងការរៀបចំសហឧក្រិដ្ឋកម្មរួម ក្នុងការបោសសម្អាត ខ្មាំង និងធ្វើឱ្យបុគ្គលិកយោធា និងប្រជាជនស៊ីវិល ក្លាយទៅជាទាសករ[256]។ ដោយមានការតែងតាំងមុខតំណែងជាអនុលេខានៅចុងឆ្នាំ១៩៧៨ ឥទ្ធិពលរបស់ មាស មុត នៅក្នុងជួរកងទ័ពបដិវត្តកម្ពុជា ឡើងដល់កម្រិតកំពូល ដែលជាសញ្ញាមួយទៀតអំពីការពង្រីកអំណាច និងឥទ្ធិពលរបស់គាត់ ក្នុង ប.ក.ក។ ក្នុងតួនាទីនេះ គេផ្ដល់ឱ្យគាត់នូវការគ្រប់គ្រងកម្លាំងទាំងបីប្រភេទនៃកងទ័ពបដិវត្តកម្ពុជា[257] និងប្រគល់តួនាទីសេចក្តីសម្រេចចិត្តជាយុទ្ធសាស្ត្រមួយលើព្រំដែនគោកជាមួយប្រទេសវៀតណាម[258]។ យោងតាមសេចក្ដីណែនាំរបស់គណៈកម្មាធិការមជ្ឈិមចុះថ្ងៃទី៣០ ខែ មីនា ឆ្នាំ

[252] ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៦៣ ជើងទំព័រយោងលេខ ៣៣៣។

[253] *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៨១ និងឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ កថាខណ្ឌ ១៦៣, ៤១៨។

[254] ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤៦។ (ឯកសារ **D266/5** អាចជាឯកសារ **D266/2** ព្រោះមានតែ ៩៨ កថាខណ្ឌ។ មិនមានដល់កថាខណ្ឌ ១៤៦ នោះទេ)។

[255] *ផ្ទុយពី* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៨១។

[256] ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ២៩-៣០។

[257] ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤៦-៧។

[258] ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤៦។ *សូមមើលផងដែរ* ឯកសារ **D54/54** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មាស វឿន នៅថ្ងៃទី ឆ.២៦ ["នៅក្នុងពេលនោះ ក្នុងឆ្នាំ១៩៨៦ [...] នៅព្រំដែនខាងកើតមានជម្លោះកាន់តែខ្លាំងឡើង" អគ្គសេនាធិការបានប្រជុំណែនាំតាមរយៈ តា មុត និង តា សឿង"]។ ឯកសារ **D54/63** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១៩ ["មាស មុត ចាប់ផ្ដើមចូលរួមទទួលខុសត្រូវលើបញ្ហានៅតាមព្រំដែនខាងកើត នៅក្នុងឆ្នាំ១៩៧៨ ពេលដែលយួនវ៉ៃបុកខ្លាំង"]។ ឯកសារ **D54/62** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២២, ២៥។ ឯកសារ **D54/60.2** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត KH ERN 00975727-00975730។

១៩៧៦[259] គាត់អាចធ្វើសេចក្ដីសម្រេច "កម្ទេច" ក្នុង និងក្រៅជួរកងទ័ពបដិវត្តកម្ពុជាទាំងមូល និង នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ គាត់ពិតជាបានប្រើអំណាចនេះ ដើម្បីបោសសម្អាត កងពល១១៧ និង តំបន់៥០៥[260]។

## សមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិម

58. មាស មុត បង្ហាញខុសអំពីច្បាប់ដែលយកមកអនុវត្តនៅក្នុងសំណើរបស់គាត់ស្នើសុំការបដិសេធ ដោយគ្មានការពិចារណាទៅលើមូលដ្ឋានរងនៃបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ[261]។ ក្នុងបណ្ដឹង ឧទ្ធរណ៍ ស.ព.អ ពន្យល់ថា ការសន្មតថា ស.ច.អ.ជ បានពិចារណាលើភស្តុតាងពាក់ព័ន្ធទាំងអស់ អាច*ជំទាស់បាន*។ ទោះជាអ្នកវិនិច្ឆ័យមានឆន្ទានុសិទ្ធិក្នុងការយល់ឃើញថា ភស្តុតាងមួយចំនួន មានភាពគួរឱ្យជឿជាងភស្តុតាងផ្សេង ក៏គេត្រូវតែច្បាស់ថាតើសំអាងហេតុនីមួយៗ ត្រូវបានបង្កើត ឡើងដោយវិធីណា។ គ្មានឆន្ទានុសិទ្ធិក្នុងការមិនគិតពីភស្តុតាងផ្ទុយ ដោយគ្មានការពន្យល់អំពី មូលហេតុនៃការជ្រើសរើសយកភស្តុតាងដែលចង់បានឡើយ[262]។

59. ក្នុងការយល់ឃើញថា មាស មុត មិនមែនជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក ចាប់ ពីខែមករា ឆ្នាំ១៩៧៦ ប៉ុន្តែ ជាជំនួយការរបស់គណៈកម្មាធិការមជ្ឈិមដោយពុំមានសិទ្ធិបោះឆ្នោត ឬ សិទ្ធិចូលរួម[263] ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានពន្យល់ពីមូលហេតុដែលខ្លួន ចង់បានភស្តុតាងប្រយោលរបស់ ឌុច ឡើយ[264] ដែលមួយចំនួនគឺជាចម្លើយសារភាពមន្ទីរស២១[265]

259 ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១០០, ១៥៣ [*សូមមើល ផងដែរ* កថាខណ្ឌ ៨៣, ៩៨]។

260 ឯកសារ**D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ។

261 បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦, ៨២។

262 ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៣៦។ វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង។ សំណុំរឿង ០០២ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៣០៤។ សាលដីកា *Muvunyi I* កថាខណ្ឌ ១៤៤, ១៤៧។ សាលដីកា *Bemba* កថាខណ្ឌ ៥២។ សាលដីកា *Kordić & Čerkez* កថាខណ្ឌ ៣៨៥។ សាលដីកា *Kunarac* កថាខណ្ឌ ៤១។

263 ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១០៨-១៥, ១១៧-២២។

264 ដូចដីកាសម្រេចលើកលែងចោទប្រកាន់បានលើកឡើង (ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១១) ហើយ មាស មុត ក៏យល់ស្របផងដែរ (បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៨៤)។

265 *សូមមើល* ឯកសារ **D1.3.33.10** កំណត់ហេតុនៃការសួរចម្លើយ ឌុច KH ERN 00195568-00195569 [នៅចុងឆ្នាំ ១៩៧៥ "ណាត បាននិយាយថា គាត់ខកចិត្តដោយសារគាត់មិនត្រូវបានគេតម្លើងឋានៈ។ ខ្ញុំមិនសូវជឿ ណាត ទេ។

ជាងភស្តុតាងគ្មានមន្ទិល និងផ្ទាល់របស់ ខៀវ សំផន[266] ដែលជាសមាជិកគណៈកម្មាធិការមជ្ឈិម ផ្ទាល់[267]។ ការពឹងផ្អែករបស់ដីកាសម្រេចលើកលែងចោទប្រកាន់ទៅលើចម្លើយរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងសមាជិកដទៃទៀតនៃគណៈកម្មាធិការមជ្ឈិម មាន ដូចជា ឌឿន, កុយ ធួន, កែ ពក និង ប៉ង់ គឺជាការបង្ហាញពីកំហុសនោះ[268]។

60. ខៀវ សំផន មិន "ថ្លែងដោយស្ទាក់ស្ទើរថា មេបញ្ជាការកងពល រួមមាន មាស មុត គឺជាសមាជិកគណៈកម្មាធិការមជ្ឈិម"ឡើយ[269]។ គាត់ហៅឈ្មោះ មាស មុត មុនគេ ដោយមិនហៅឈ្មោះ មេបញ្ជាការដទៃទៀតឡើយ[270] ហើយបញ្ជាក់ពីអំណាចដែល មាស មុត មាននៅក្នុងតួនាទីនេះ[271]។ ទោះបីជា ខៀវ សំផន មិននិយាយច្បាស់អំពីកាលបរិច្ឆេទ ឬរយៈកាលនៃសមាជិកភាពរបស់ មាស មុត ក៏ដោយ ក៏ប៉ុន្តែ គាត់បានយោងដល់រយៈកាលដែលខ្លួនគាត់ផ្ទាល់ជាសមាជិក

ហេតុដូច្នេះហើយ ខ្ញុំបានសួរចម្លើយ កុយ ធួន ពីបញ្ហានេះ *នៅពេលដែលគាត់ជាប់ឃុំនៅ ស-២១* ហើយគាត់ (កុយ ធួន) បានបញ្ជាក់អះអាងពីចំណុចនេះ។ ប៉ង់ ក៏បានបញ្ជាក់អះអាងពីព័ត៌មានដែរ នៅថ្ងៃមួយដែលគាត់បានមកស-២១" (មានបញ្ជាក់បន្ថែម)]។ ឯកសារ **D12** Duch កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច KH ERN 00680801-00680803។

[266] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១១៥ ជើងទំព័រយោងលេខ ៤០៣។

[267] ឯកសារ **D1.3.33.15** កំណត់ហេតុសួរចម្លើយ ខៀវ សំផន KH ERN 00156620 ["ខ្ញុំខ្លួនឯងក៏ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ជាដំបូង ជាសមាជិកត្រៀមនៅឆ្នាំ ១៩៧១ និងក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ ១៩៧៦"]។*សូមមើលផងដែរ ឧទា.* ឯកសារ **D98/1.2.27** កាំង ហ្គេកអ៊ាវ ប្រតិចារឹកសវនាការលើអង្គសេចក្តី ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ម៉ោង ១៤:៣១:២៧-១៤:៣៤:២៥ ["ខៀវ សំផន [...] ជាសមាជិកមជ្ឈិមបក្ស សមាជិកមជ្ឈិមពេញសិទ្ធិ"]។

[268] ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៤៩។

[269] បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៨៣។

[270] ឯកសារ **D1.3.33.15** កំណត់ហេតុសួរចម្លើយ ខៀវ សំផន KH ERN 00156619 ["គណៈកម្មាធិការមជ្ឈិមមានសមាជិក ប្រមាណជា ៣០ នាក់ ប៉ុន្តែ ខ្ញុំមិនចាំឈ្មោះអស់នោះទេ។ ខ្ញុំចាំដូចជា មាស មុត (កូនប្រសាររបស់ តា ម៉ុក ដែលជាលេខានៃកងពលមួយដែលឈរជើងនៅកំពត ហើយក្រោយឆ្នាំ១៩៧៥ ក៏ត្រូវបានប្តូរទៅជាកងទ័ពជើងទឹក) [...] និង សឿ វ៉ាស៊ី *ហៅ* ឌឿន (ប្រធានមន្ទីរ ៨៧០) ឬ កុយ ធួន និង កែ ពក ផងដែរ"]។

[271] ឯកសារ **D1.3.33.15** កំណត់ហេតុសួរចម្លើយ ខៀវ សំផន KH ERN 00156619 ["នៅក្នុងគណៈកម្មាធិការមជ្ឈិម អ្នកដែលមានអំណាចពិតប្រាកដគឺ លេខាភូមិភាគ និងលេខាតំបន់ និងអ្នកទទួលខុសត្រូវអង្គភាពយោធា"]។ *ផ្ទុយពី*បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៨៣។

ពេញសិទ្ធិ (ខែមករា ឆ្នាំ១៩៧៦ រហូតដល់ចុងបញ្ចប់នៃរបបនោះ)[272]។ មិនតែប៉ុណ្ណោះ ផ្ទុយទៅនឹងសេចក្តីអះអាងរបស់ មាស មុត[273] ភស្តុតាងរបស់ ខៀវ សំផន ត្រូវបានគាំទ្រដោយប្រភពផ្សេងៗទៀតដែលបញ្ជាក់ថា លេខាភូមិភាគ និងលេខាតំបន់ គឺជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម[274]។ មាស មុត ខ្លួនឯងទទួលស្គាល់ថា គាត់ជួប សុន សេន "ដើម្បីបំពេញការងាររបស់គណៈមជ្ឈិម"[275]។ ផ្ទុយទៅវិញ ដីកាសម្រេចលើកលែងចោទប្រកាន់ខកខានមិនបានយល់ថា ភស្តុតាងរបស់ ឌុច មិនមានការបញ្ជាក់ និងផ្ទុយទៅនឹងខ្លឹមសារនៃលក្ខន្តិកៈ ប.ក.ក[276]។

272 ចំណុចនេះត្រូវបានបញ្ជាក់ដោយអង្គហេតុដែលថា សមាជិកពីរនាក់ទៀត ដែលគាត់លើកឡើង (កុយ ធួន និង សឿ វ៉ាស៊ី ហៅ ឌឿន) ត្រូវបានបោសសម្អាត និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ បន្ទាប់ពីខែមករា ឆ្នាំ១៩៧៦ ប៉ុន្តែ នៅមុនមហាសន្និបាតបក្សលើកទី៥ នៅចុងឆ្នាំ១៩៧៨។ *សូមមើល* ឯកសារ **D4.1.950** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ព ដែលបានកែប្រែ (កុយ ធួន លេខរៀងទី ៤១១៤ ចូលថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧។ ឌឿន លេខរៀងទី ៩៥៤៦ ចូលថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៧៧)។ ឯកសារ **D114/230.1.1** បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស (កុយ ធួន លេខរៀងទី ១៤០២៧, ឌឿន លេខរៀងទី ២១៨៣, ១៤៥៩៦ ចូលថ្ងៃទី១៦-៧ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ប៉ង់ លេខរៀងទី ១៤១៥៧)។

273 បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៦(ខ), ៨៥។

274 ឯកសារ **D1.3.30.29** *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ* ដោយ M. Matsushita និង S. Heder KH ERN 00324765។ ឯកសារ **D4.1.4** អត្ថបទនិពន្ធដោយ T. Carney មានចំណងជើងថា៖ *The Organization of Power* KH ERN 00332368-00332370។ ឯកសារ **D1.3.17.6** សៀវភៅរៀបរៀងដោយ S. Heder និង B. Tittemore មានចំណងជើងថា៖ *បេក្ខជនចំនួនប្រាំពីរនាក់ដែលត្រូវកាត់ទោស* KH ERN 00742615- 00742617។ *សូមមើលផងដែរ* ឯកសារ **D4.1.405** កំណត់ហេតុនៃការស្តាប់ចម្លើយឌុច KH ERN 00244235 [" មាស មុត និង សំ ប៊ិត ត្រូវបាតែងតាំងជាសមាជិកគណៈកម្មាធិការមជ្ឈិមនៅឆ្នាំ១៩៧៥"]។ ឯកសារ **D10.1.64** សេចក្តីសន្និដ្ឋានដែលសរសេរ ចុងក្រោយរបស់ ឌុច KH ERN 00404803 ជើងទំព័រយោងលេខ ៣៣។

275 ឯកសារ **D1.3.7.8** កាសែតឌីឃែមបូឌាដេលី *អ្វីដែលកន្លងផុតទៅហើយ ឲ្យវាផុតទៅចុះ* ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៨ EN ERN 00165821["មាស មុត បានទទួលស្គាល់ថា គាត់បានជួបជាមួយ សុន សេន 'ពីរបីដង' ដើម្បីអនុវត្តការងាររបស់គណៈកម្មាធិការមជ្ឈិម"]។

276 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ *ដែលសំអាងលើ*ឯកសារ **D1.3.22.1** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ចុះខែមករា ឆ្នាំ១៩៧៦ មាត្រា ២៤៖ [ចែងពី "សមាជិកពេញសិទ្ធិ និងសមាជិកតរៀម"]។ *សូមមើល* ឯកសារ **D12** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច KH ERN 00680802 [ឌុច អះអាងថា លក្ខន្តិកៈត្រូវបានប្រឌិតបន្ថែមតាមរយៈការបង្កើតក្រុមជំនួយការមជ្ឈិមនេះឯង]។ *សូមមើលបន្ថែម* ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ១១៦។

61. ផ្អែកលើសំអាងហេតុរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា (i) សមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សមានភាពគ្រប់គ្រាន់ក្នុងការកំណត់ថា មាស មុត គឺជា "មេដឹកនាំជាន់ខ្ពស់" ម្នាក់នៃកម្ពុជាប្រជាធិបតេយ្យ[277] (ii) "ក្នុងចំណោមស្ថាប័នកំពូលៗ [គឺមាន] គណៈកម្មាធិការមជ្ឈិមបក្សដែលមានសមាជិកជាង ៣០ នាក់ គឺជាអង្គ [ប.ក.ក] ខ្ពស់ជាងគេបង្អស់សម្រាប់អនុវត្តកិច្ចការសំខាន់ៗរបស់ប្រទេស"[278] (iii) មុខតំណែងរបស់ មាស មុត ជាជំនួយគណៈកម្មាធិការមជ្ឈិម ដោយគ្មានអំណាចចូលរួមក្នុងការសម្រេចចិត្តនៅក្នុងគណៈកម្មាធិការ ធ្វើឲ្យគាត់ "ស្ថិតនៅក្រោមកម្មាភិបាលប្រហែល ៥០ នាក់ និងកាន់តំណែងដូចកម្មាភិបាលដទៃទៀតដែរ ក្នុងនោះរួមមាន លេខាភូមិភាគ និងលេខាកងពល"[279] ឥទ្ធិពលជាកត្តាកំណត់នៃសំអាងហេតុនេះលើសេចក្ដីសន្និដ្ឋានរបស់ដីកាសម្រេចលើកលែងចោទប្រកាន់ដែលថា មាស មុត មិនស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ពីព្រោះ គាត់ "មិនអនុវត្តអំណាចជាច្រើន"[280]ត្រូវបានបង្ហាញយ៉ាងច្បាស់។

***ឆ. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុក្នុងការប្រព្រឹត្តិលើជនរងគ្រោះមួយចំនួន***

62. មាស មុត យល់ស្របថា ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុក្នុងការប៉ាន់ប្រមាណទាបទៅលើចំនួនជនរងគ្រោះដែលគាត់ទទួលខុសត្រូវ[281]។ ក៏ប៉ុន្តែ គាត់អះអាងទាំងខុសថា ស.ព.អ មិនអាចបង្ហាញភស្តុតាងអំពីកម្រិតនៃកំហុស ដោយឈរលើមូលដ្ឋានថា ស.ព.អ ត្រូវកាតព្វកិច្ចផ្អែកគតិយុត្តិ ទៅតាមសំអាងហេតុនៃដីកាសម្រេចចោទប្រកាន់របស់ ស.ច.ស.អ។ សំអាងហេតុរបស់ ស.ច.ស.អ អំពីចំនួនជនរងគ្រោះ ពុំពាក់ព័ន្ធថាតើ ស.ច.ស.ជ មានកំហុសក្នុងការមិនបញ្ចូលចំនួនជនរងគ្រោះដ៏ច្រើននៅក្នុងការវាយតម្លៃរបស់គាត់លើភាពធ្ងន់ធ្ងរ ឬមិនធ្វើឲ្យប៉ះពាល់ដល់ភស្តុតាងដែលបង្ហាញដោយ ស.ព.អ ក្នុងការរកភស្តុតាងបញ្ជាក់កំហុសនោះ[282]។ ស.ព.អ មិនជាប់កាតព្វកិច្ចទៅតាមសំអាងហេតុនៅក្នុងដីកាសម្រេចចោទប្រកាន់ឡើយ

[277] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៥។

[278] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤១០។

[279] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត កថាខណ្ឌ ៤១៩។

[280] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[281] បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៨៩។

[282] មានការបង្ហាញយ៉ាងច្បាស់ថា ចំនួនជនរងគ្រោះពិតប្រាកដ និងច្បាស់លាស់ មិនតម្រូវឲ្យមានទេចំពោះសំណុំរឿងឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ "ជាពិសេស ចំពោះបទដ្ឋានស្ដីពីភស្តុតាង ដែលអាចអនុវត្តនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី

ដោយសារជម្រើសមិនប្តឹងឧទ្ធរណ៍។ ដោយហេតុថា ស.ច.ស.អ រកឃើញពីភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីបង្កើតបានជាយុត្តាធិការបុគ្គល[283] រាល់ការប៉ាន់ស្មានទាបនៅក្នុងការគណនាចំនួនជនរងគ្រោះមិនបានចាត់ទុកថាឥតការដល់សេចក្តីសម្រេចរបស់ ស.ច.ស.អ ក្នុងចោទប្រកាន់ឡើយ។ ប្រសិនបើ អ.ប.ជ ចុងក្រោយរកឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គហេតុ អ.ប.ជ អាចជំនួសសាលដីការបស់ខ្លួនបាន[284] ក្នុងការវាយតម្លៃថាតើចំនួនជនរងគ្រោះ ឆ្លើយតបទៅនឹងលក្ខខណ្ឌស្តីពីភាពធ្ងន់ធ្ងរឬទេ។

63. ទោះជាក្នុងករណីណាក៏ដោយ ការប្រើប្រាស់សេចក្តីដកស្រង់មិនពេញលេញរបស់ ស.ច.ស.អ អំពីចំនួនប៉ាន់ស្មានជនរងគ្រោះ ដើម្បីបង្ហាញថា ពុំមានលទ្ធភាពរកអង្គហេតុមានហេតុផលនោះ គឺជាការធ្វើឲ្យខូចដល់សំអាងហេតុរបស់ ស.ច.ស.អ ដែលថា រាប់ពាន់នាក់គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មរបស់ មាស មុត[285]។ លើសពីនេះទៀត ចំនួនជនរងគ្រោះរបស់ ស.ច.ស.អ គឺជា

មុនការជំនុំជម្រះ"។ *សូមមើល* សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ២១៤ (ចៅក្រម Beauvallet និងចៅក្រម Baik) និងរឿងក្តីនានាដែលបានយោងនៅក្នុងជើងទំព័រយោងលេខ ៥០៦៧ នៃសេចក្តីពិចារណានេះ។

283 ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៤៦២-៩។

284 ឯកសារ **D266/2** បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៧។ *សូមមើល ផងដែរ* សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ១៧។

285 មាស មុត ផ្តល់ការយល់ឃើញមួយជ្រុងអំពីការប៉ាន់ប្រមាណរបស់ ស.ច.ស.អ ដោយទុកចោលការលើកឡើងទាំងអស់អំពីភស្តុតាងដែល ស.ច.ស.អ បានរកឃើញថាអាចឲ្យជឿទុកជាក់បានគ្រប់គ្រាន់ដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការសម្រេចនានារបស់គាត់ (*យោង*ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត សេចក្តីដកស្រង់ពីកថាខណ្ឌ ៩១(ក-ជ) ជាមួយនឹងឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ២៤៩-៥៧, ២៦៤-៨, ៣២៩ (*សូមមើល ផងដែរ* កថាខណ្ឌ ២៨៣, ២៨៩, ៣០១-២, ៣១៣, ៣២៣), ៣៤១, ៣៦៧-៧០, ៤១៦-៧, ៤២១-៤, ៤៣៧-៤២, ៤៤៤-៥០។

ការប៉ាន់ប្រមាណទាបដែលគេទទួលស្គាល់ដោយឯករាជ្យ[286] ដែលផ្អែកយ៉ាងជាក់ស្តែងតែទៅលើភស្តុតាងដែលប្រមូលបានពី ក.ស.ច.ស[287]។

64. ដោយសារតែកំហុស[288] និងឥទ្ធិពលរបស់វាច្បាស់លាស់[289] ទឡ្ហីករណ៍របស់ មាស មុត ក្រៅពីនោះ ព្យាយាមធ្វើឱ្យមិនច្បាស់ និងកាត់បន្ថយកំហុស ដោយភាគច្រើនផ្តោតលើទិដ្ឋភាពផ្សេងៗទៀតនៃការវាយតម្លៃលើភាពធ្ងន់ធ្ងរ[290]។

## *ជ. ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសអង្គច្បាប់ ដោយកំណត់ថា ឌុច គឺជាជនដែលទទួលខុសត្រូវខ្ពស់បំផុតតែម្នាក់*

65. មាស មុត លើកឡើងផ្ទុយគ្នាខ្លួនឯង ដោយដំបូងបដិសេធថា ដីកាសម្រេចលើកលែងចោទប្រកាន់រកឃើញថា ឌុច គឺជាជន "ដែលទទួលខុសត្រូវខ្ពស់បំផុត" តែម្នាក់គត់[291] ក្រោយមក ទទួលថា ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសក្នុងការសម្រេចយ៉ាងដូច្នេះ[292] រួចហើយ ជំទាស់ថា ការសម្រេចដោយខុសឆ្គងនេះពុំមានឥទ្ធិពលលើសំអាងហេតុដែលថា មាស មុត មិនមែនជា ជន

[286] ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៣៣ ["ការប៉ាន់ស្មានចំនួនជនរងគ្រោះនៅតែស្ថិតនៅក្នុងចំនួនអប្បបរមា [...] ចំនួនជនរងគ្រោះជាក់ស្តែងអាចមានខ្ពស់ មានចំនួនច្រើនជាងឆ្ងាយពីចំនួនប៉ាន់ស្មាន"]។*សូមមើល ផងដែរ* កថាខណ្ឌ ១៣២-៤៥ ទាក់ទងនឹងវិធីសាស្រ្តយកកម្រិតអប្បបរមាដែល ស.ច.ស.អ បានប្រើ ដើម្បីប៉ាន់ប្រមាណចំនួនជនរងគ្រោះ។

[287] ឯកសារ **D267** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១១៨-២៣, ១៣០-១។ សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) កថាខណ្ឌ ៥៦ (សេចក្តីសម្រេចជាឯកច្ឆន្ទ)។ *សូមមើល ផងដែរ* កថាខណ្ឌ ៤៨-៥៥។

[288] ស្របជាមួយយុត្តិសាស្រ្តមុនរបស់ ស.ច.ស ទាំងពីររូប និង អ.ជ.ស.ដ (ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ កថាខណ្ឌ ៣១៧។ សំណុំរឿង ០០១ ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ២២) និងតុលាការ ICTY (*សូមមើល ឧទា.* សេចក្តីសម្រេចបញ្ជូនរឿងក្តីរបស់ *Janković* កថាខណ្ឌ ១៩។ សេចក្តីសម្រេចបញ្ជូនរឿងក្តីរបស់ *Lukić & Lukić* កថាខណ្ឌ ២៧, ២៩), ដីកាសម្រេចលើកលែងចោទប្រកាន់ទទួលស្គាល់ថា ចំនួនជនរងគ្រោះជាកត្តាចម្បងសម្រាប់ការពិចារណាអំពីឧក្រិដ្ឋកម្មនានា (ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៦៥-៦)។

[289] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៨។

[290] ស.ព.អ បានសំអាងលើចំណុចទាំងនេះថាជាប់ពាក់ព័ន្ធនឹងកន្លែងផ្សេងទៀត។ *សូមមើល ខាងលើ* កថាខណ្ឌ ១២-៨។

[291] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៩៣។

[292] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦(ឃ), ៩៥។

ដែលទទួលខុសត្រូវខ្ពស់បំផុតឡើយ[293]។ តាមការពិត មាស មុត យល់ស្របជាមួយ ស.ព.អ [294] ដែលថា ប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត" មិនមែន និងមិនធ្លាប់មានបំណងកម្រិតចំពោះ ឌុច ឬ មានន័យ "ថា ឌុច គួរតែត្រូវបានប្រើជាខ្នាតសម្រាប់កំណត់ថាតើអ្នកផ្សេងគឺជាជនទទួលខុសត្រូវខ្ពស់បំផុតដែរឬយ៉ាងណា"[295]។ គាត់យល់ស្របដោយឯករាជ្យថា ដីកាសម្រេចលើកលែងចោទប្រកាន់មានកំហុសក្នុងការសម្រេចថា (i) ពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងច្បាប់បង្កើត អ.វ.ត.ក សំដៅជាក់លាក់ទៅលើ ឌុច និង (ii) គ្មាននរណា ក្រៅពីមេដឹកនាំជាន់ខ្ពស់ និង ឌុច ដែលអាចនឹងត្រូវចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក[296]។

66. ដោយទទួលស្គាល់អំពីកំហុសអង្គច្បាប់ទាំងនេះ មាស មុត គ្រាន់តែអះអាង ដោយគ្មានដកស្រង់ ឬ ទឡ្ហីករណ៍ ថា ការកំណត់ប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត" របស់ដីកាសម្រេចលើកលែងចោទប្រកាន់ទៅ ឌុច ពុំមានឥទ្ធិពលលើការសម្រេចលើកក្រោយរបស់ខ្លួនថា មាស មុត មិនមែនជាបុគ្គល "ដែលទទួលខុសត្រូវខ្ពស់បំផុត"[297]ឡើយ។ ចំណុចនេះផ្ទុយទៅនឹងពាក្យពេចន៍ដើមរបស់ដីកាសម្រេចលើកលែងចោទប្រកាន់។ ថាតើកំហុសអង្គច្បាប់នេះកំណត់លទ្ធផលនៃយុត្តាធិការបុគ្គល ឬការវិភាគដែលមានកំហុសដែលរងការជំទាស់នៅក្នុងមូលដ្ឋាន ង (រង)[298] ឥទ្ធិពលនេះងាយយល់[299] ហើយកំហុសនោះមោឃភាពសេចក្ដីសម្រេច។

## ការឆ្លើយតបទៅនឹងចម្លើយតបទៅលើផលវិបាកនៃដីកាដំណោះស្រាយដែលផ្ទុយគ្នា

67. មាស មុត អនុវត្តខុសលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងប្រកាន់យកការបកស្រាយចង្អៀតទៅលើច្បាប់គោល និងយុត្តិសាស្ត្រ ក្នុងគោលបំណងព្យាយាមបន្ថយអាណត្តិច្បាស់លាស់របស់កិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់បង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង

[293] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៩៣, ៩៥-៦។

[294] ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៧១-១៩០។

[295] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៩៥។

[296] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៩៥ *ដែលសំអាងលើ*ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៣៩៦, ៤០១។

[297] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៦(ឃ), ៩៣, ៩៥-៦។

[298] *សូមមើល* ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១១២-៣ (មូលដ្ឋានសំអាងហេតុ ចំណុច ង)។

[299] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ កថាខណ្ឌ ៤២៧-៨។ ហេតុដូច្នេះ លើសពីនេះទៀត ប្រសិនបើមិនបានកែតម្រូវទេ កំហុសនេះនឹងបន្តធ្វើឲ្យបរាជ័យដល់បណ្ដឹងឧទ្ធរណ៍ដែលជោគជ័យទៅវិញនោះ។

ជាពិសេស វិធាន៧៧ (១៣)(ខ)[300] ដែលថា លើកលែងតែដីកាសម្រេចចោទប្រកាន់របស់ ស.ច.ស.អ ត្រូវបានបដិសេធដោយសម្លេងភាគច្រើនលើសលប់របស់ អ.ប.ជ សំណុំរឿង០០៣ ត្រូវតែបញ្ជូនទៅជំនុំជម្រះ[301]។

68. ជាការពិត ចេតនាច្បាស់លាស់របស់ភាគីនៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលថា នៅពេល ស.ច.ស ជំទាស់មិនឱ្យរឿងក្ដីមួយដំណើរការទៅមុខ ហើយ អ.ប.ជ ខកខានមិនទទួលបានសម្លេងគាំទ្រ ភាគច្រើនលើសលប់ ដើម្បីដោះស្រាយការខ្វែងគំនិតគ្នា ការចោទប្រកាន់នឹងបន្តទៅមុខ មានន័យ ថា សំណុំរឿងត្រូវបញ្ជូនទៅ អ.ជ.ស.ដ[302]។ ការព្យាយាមរបស់ មាស មុត ក្នុងការបន្ថយទម្ងន់នៃ ភស្តុតាងរបស់ David Scheffer អំពីចេតនារបស់ភាគី មិនមានប្រសិទ្ធភាពឡើយ[303]។ ក្នុងនាមជា ឯកអគ្គរដ្ឋទូតគោចរសហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាម គាត់ចូលរួមយ៉ាង ច្រើននៅក្នុងការចរចាពីដំបូងដល់ទីបញ្ចប់[304] ហើយរបាយការណ៍របស់គាត់ត្រូវបានប្រើប្រាស់

[300] ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៩២-៣, ១៩៧-៨។ ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ២២-៨, ៣៨។

[301] ឯកសារ **D266/2** បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៩១-៨។ ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត។ ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត ត្រង់កថាខណ្ឌ ២០, ៩៨ មាស មុត បានលើកទឡ្ហីករណ៍បណ្ដឹងឧទ្ធរណ៍របស់គាត់ឡើងវិញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែសម្រេចតម្កល់ដោយ សម្លេងភាគច្រើនលើសលប់របស់ អ.ប.ជ ទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានច្រានចោលក្ដី។ ដូចបាន លើកឡើងនៅក្នុង ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ២០ វិធានផ្ទៃក្នុង ៧៧(១៣) និង ៧៩(១) សុទ្ធតែបញ្ជាក់ថា ដីកាសម្រេចចោទប្រកាន់ដែលចេញដោយ ក.ស.ច.ស ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ អ.ជ.ស.ដ បើគ្មានការអនុម័តដោយសម្លេងភាគច្រើនលើសលប់ពី អ.ប.ជ ទេ។ ចំណុចនេះគឺជាសេចក្ដីសន្និដ្ឋានប្រកបដោយហេតុផលតែមួយគត់ ពីព្រោះថា បញ្ហានេះនឹងមិនត្រឡប់មកចំពោះមុខ អ.ប.ជ ទេ (១) ប្រសិនបើពុំមានភាគីណាប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ហើយ មាស មុត ខ្លួន ពុំបានប្ដឹងឧទ្ធរណ៍ឡើយ (២) ក្នុងករណីដែល អ.ប.ជ ពុំអាចរកសម្លេងភាគច្រើនលើសលប់បាន សេចក្ដីសម្រេចនេះ ចុងក្រោយនេះគឺថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងចាត់ទុកជាបានការ។

[302] ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ២៣, ២៦, ២៩-៣២។

[303] ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ១៩។

[304] ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣២។ សំណុំរឿង ០០១ ឯកសារ **C5/13** សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីរបស់លោក David Scheffer ដែលជាអ្នកជំនាញច្បាប់ អន្តរជាតិ ក្នុងការគាំទ្រដល់សហចៅក្រមស៊ើបអង្កេត ទំព័រ ១-៣។

ដោយ អ.ប.ជ អ.ជ.ត.ក និង ស.ច.ស[305] និងមេធាវីការពារក្តី មាស មុត ផងដែរ[306] រួមទាំងនៅក្នុងចម្លើយតបនេះផង[307]។ យ៉ាងណាក៏ដោយ ការចងចាំរបស់គាត់ មានភាពស្របទាំងស្រុងទៅនឹងលិខិតឆ្លើយឆ្លងរវាងលោក Hans Corell និង លោក សុខ អាន ដែលជាអ្នកចរចាសំខាន់របស់ភាគីទាំងពីរ[308]។

69. លើសពីនេះទៀត ការអះអាងរបស់ មាស មុត[309] ដែលថា មាត្រា៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងយុត្តិសាស្ត្ររបស់ អ.ជ.ត.ក[310] មិនអាចអនុវត្តបានចំពោះស្ថានការណ៍បច្ចុប្បន្នដែល អ.ប.ជ បានទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍របស់ភាគី មិនមែនតាមរយៈនីតិវិធីដោះស្រាយវិវាទផ្លូវការ មើលរំលងចំណុចដែលថា លទ្ធផលជាសំខាន់មានលក្ខណៈដូចគ្នា។ របៀបដែល អ.ប.ជ ទទួលដោះស្រាយបញ្ហាដូចគ្នា ដែលថាតើ ស.ច.ស មានកំហុសក្នុងការចេញដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនពាក់ព័ន្ធឡើយ។ លើសពីនេះទៀត អ.ប.ជ បានបញ្ជាក់លទ្ធផលដូចគ្នាក្នុងបរិបទនៃការខ្វែងយោបល់គ្នារវាង ស.ច.ស ពាក់ព័ន្ធនឹងខ្លឹមសារនៃ

305 សំណុំរឿង ០០៤/១ ឯកសារ **D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជើងទំព័រយោងលេខ ១៥១។ សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* ជើងទំព័រយោងលេខ ១០៩។ ឯកសារ **D261** ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ជើងទំព័រយោងលេខ ១៥-១៦។ ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ ជើងទំព័រយោងលេខ ១១៦១។

306 ឯកសារ **D170** សំណើរបស់ មាស មុត សុំឲ្យយក និងដាក់ទៅក្នុងសំណុំរឿង នូវសម្ភារៈ ឯកសាររបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចាបង្កើត អ.វ.ត.ក ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ជើងទំព័រយោងលេខ ៨៤។

307 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ លេខយោងជើងទំព័រ ៤១, ៤១៥។

308 ឯកសារ **D267/4.1.5** លិខិតពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិផ្ញើជូនឯកឧត្តមនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២000 កំណត់ត្រាដែលបានភ្ជាប់ជាឧបសម្ព័ន្ធមកពីលោក Hans Corell ផ្ញើជូនលោកអគ្គលេខាធិការ <u>កម្មវត្ថុ</u>៖ សេចក្តីអំពាវនាវបន្ទាន់មកពីប្រទេសកម្ពុជា_គំនិតយោបល់ដើម្បីដោះស្រាយភាពខុសគ្នារវាងថៅក្រមស៊ើបអង្កេត/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២000 EN ERN 01614369។ *សូមមើលផងដែរ* ឯកសារ **D181/2.36** សេចក្តីថ្លែងការណ៍របស់លោកអគ្គលេខាធិការរង Hans Corell ក្រោយចាកចេញពីរាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២00៣ EN ERN 01326112។

309 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ១៨-១៩។

310 សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ៦៥ *ដែលសំអាងលើ*មាត្រា ២៣*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ មាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក។ វិធាន ៧២(៤)(ឃ) នៃវិធានផ្ទៃក្នុង។

ដីកាដំណោះស្រាយរបស់ខ្លួនថា ស.ច.ស ដូចក្នុងសំណុំរឿង ០០៣ ដែរ សម្រេចមិនបញ្ជូនទៅ អ.ប.ជ នៅក្នុងយន្តការដោះស្រាយទំនាស់ទេ[311]។

70. លទ្ធផលដែលសំណុំរឿង ០០៣ បន្តទៅជំនុំជម្រះ មិនបានរងការប៉ះពាល់ ដូចដែល មាស មុត លើកទឡ្ហីករណ៍ម្តងហើយម្តងទៀត[312] ដោយគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ឡើយ[313]។ វិធាន៧៧(១៣)(ខ) ដែលផ្តល់អាណត្តិឲ្យ អ.ជ.ស.ដ ទទួលដោះស្រាយដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅពេលមិនទទួលបានសម្លេងគាំទ្រភាគច្រើនលើសលប់ពី អ.ប.ជ ក្នុងការបដិសេធ វាគឺជា ច្បាប់ពិសេស ដែលទាក់ទិននឹងការសម្រេចចោទប្រកាន់ និង មានអានុភាពលប់លើលក្ខខណ្ឌទូទៅនៃវិធាន ៧៧(១៣)(ក)។ ច្បាប់ពិសេសគឺជាយន្តការបកស្រាយដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ[314] ដែលត្រូវបានប្រើប្រាស់ដោយសាលាក្តីអន្តរជាតិ និង សាលាក្តីតំបន់ផ្សេងៗ[315] រួមទាំង អ.វ.ត.ក ផងដែរ។ *គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ប្រសិនបើអនុវត្ត ត្រូវកម្រិតចំពោះវិមតិសង្ស័យដែលនៅតែមាននៅក្រោយពីការបកស្រាយ និងមិនផ្តល់ផលប្រយោជន៍ច្បាស់លាស់ដល់ជនត្រូវចោទគ្រប់ស្ថានការណ៍នោះទេ[316]។ នៅក្នុងករណីនេះ ពុំមានវិមតិសង្ស័យឡើយ។ វិធាន ៧៧(១៣) (ខ) បង្ហាញអំពីចេតនាក្នុងការអនុវត្តអាណត្តិច្បាស់លាស់នៃកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់បង្កើត

311 សំណុំរឿង ០០២ ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៧២-៤។ *សូមមើល* ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ៣៦-៧។

312 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ១៥, ១៧, ២០។ ឯកសារ **D267/4** បណ្តឹងឧទ្ធរណ៍របស់ មាស មុត ទំព័រ ១-២ កថាខណ្ឌ ២, ៤៥, ៤៩, ៦២-៦។

313 មហាសន្និបាត អ.ស.ប របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិ សម័យប្រជុំលើកទី៥៨ ឆ្នាំ២០០៦ កថាខណ្ឌ ៦១។ មហាសន្និបាត អ.ស.ប របាយការណ៍របស់គណៈកម្មាធិការច្បាប់អន្តរជាតិ សម័យប្រជុំលើកទី៥៦ ឆ្នាំ២០០៤ កថាខណ្ឌ ៣០៥។

314 *សូមមើល ឧទា.* រឿងក្តី *Beagle Channel Arbitration (ប្រទេសអាហ្សង់ទីន ទល់នឹង ប្រទេសឈីលី)* របាយការណ៍ និងសេចក្តីសម្រេចរបស់តុលាការអាជ្ញាកណ្តាល ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ កថាខណ្ឌ ៣៨-៩។ រឿងក្តី *Brannigan និង McBride ទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ៧៦។ រឿងក្តី *Nikolova ទល់នឹង ប្រទេសប៊ុលហ្គារី* កថាខណ្ឌ ៦៩។ Rudolf Gabriel ទំព័រ ៦៣៩៨-៩៩ កថាខណ្ឌ ៣៥-៦ និងទំព័រ ៦៤០៤ កថាខណ្ឌ ៥៩។

315 សំណុំរឿង ០០១ ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ២៩៨, ៣៤៨។

316 ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤៣-៤។

អ.វ.ត.ក ដោយកំណត់ថា នៅពេល សចស ខ្វែងយោបល់គ្នាលើរឿងក្ដីមួយដែលកំពុងដំណើរការនីតិវិធី ដោយពុំមានសម្លេងភាគច្រើនលើសលប់របស់ អ.ប.ជ រឿងក្ដីនឹងបន្តទៅជំនុំជម្រះ។

71. មាស មុត ចំអកតាមរយៈអ្វីដែលគាត់ហៅថា "ភាសិតកំណាចតុលាការ ដែលថា *នៅពេលមានវិមតិសង្ស័យ ត្រូវធ្វើការចោទប្រកាន់*" ដែលផ្ទុយទៅនឹងគោលការណ៍ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ*[317]។ ប៉ុន្តែ *គោលការណ៍វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ* អនុវត្តចំពោះបញ្ហាអង្គហេតុ និងច្បាប់សារធាតុ ដែលកំណត់ពិរុទ្ធភាពរបស់ជនជាប់ចោទនៅពេលជំនុំជម្រះ[318]។ ដោយនៅឆ្ងាយពី "ភាពកំណាច" យន្តការ អ.វ.ត.ក គោរពសិទ្ធិរបស់ភាគីទាំងអស់នៃដំណើរការនីតិវិធី រួមទាំងមេធាវីការពារក្ដី និងជនសង្ស័យ[319]។ ដូចគ្នាដែរ ច្បាប់ និងយុត្តិសាស្ត្របារាំង និង អ.វ.ត.ក លើកឡើងថា កិច្ចដំណើរការនីតិវិធីអាចបញ្ចប់បានតែចំពោះហេតុផលកំណត់ជាក់លាក់ ដែលមិនទាក់ទិននឹងភាពមិនច្បាស់លាស់ផ្នែកនីតិវិធី[320]។ លើសពីនេះទៀត ចំណុចនេះស្របទៅនឹងគោលការណ៍ *ក្នុងករណីមានវិមតិសង្ស័យ ត្រូវចាប់ផ្ដើមស៊ើបអង្កេត* បានអនុវត្តប្រកបដោយសង្គតិភាព នៅក្នុងយុត្តាធិការច្បាប់ស៊ីវិលជាច្រើនដែលបញ្ជាក់ថា ក្នុងករណីមានវិមតិសង្ស័យថាតើនីតិវិធីត្រូវវិវត្តដល់ការជំនុំជម្រះក្ដី ឬយ៉ាងណា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអាចអនុវត្តបានឡើយ ហើយត្រូវបានសន្មតថា ពិរុទ្ធភាពរបស់ជនជាប់ចោទនឹងត្រូវកំណត់នៅពេលជំនុំជម្រះក្ដី[321]។

317 ឯកសារ **D266/5** ចម្លើយតបរបស់ មាស មុត កថាខណ្ឌ ២, ១៥, ២០។

318 ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤១-២។

319 ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៤៣-៨។

320 ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៥០។

321 *សូមមើល ឧទា.* **ប្រទេសស្វីស:** (តុលាការកំពូលប្រទេសស្វីស សាលដីកា ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ សំណុំរឿងលេខ ១៣៨ IV ៨៦ កថាខណ្ឌ ៤.១.១ [(បកប្រែក្រៅផ្លូវការ)] "*គោលការណ៍សន្មតថាគ្មានទោសទុកជាមុន ដរាបណាតុលាការមិនទាន់សម្រេចសេចក្ដី*" តម្រូវថា ក្នុងករណីមានវិមតិសង្ស័យ នោះកិច្ចដំណើរការនីតិវិធីត្រូវបន្តទៅមុខ។ [...] តាមពិតទៅ ក្នុងករណីមានវិមតិសង្ស័យ មិនមែនអាជ្ញាធរស៊ើបអង្កេត ឬអាជ្ញាធរចោទប្រកាន់ ជាអ្នកសម្រេចទេ ប៉ុន្តែ ចៅក្រមដែលមានសមត្ថកិច្ចទៅវិញទេដែលជាអ្នកសម្រេច។ នៅក្នុងដំណាក់កាលសម្រេចចោទប្រកាន់ គោលការណ៍ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" ដែលជាប់ទាក់ទងនឹងការវាយតម្លៃភ័ស្តុតាងដោយអាជ្ញាធរកាត់សេចក្ដី មិនអនុវត្តនោះឡើយ។ ផ្ទុយទៅវិញ គោលការណ៍ "*សន្មតថាគ្មានទោសទុកជាមុន ដរាបណាតុលាការមិនទាន់សម្រេចសេចក្ដី*" ត្រូវយកមកអនុវត្តចំពោះការសម្រេចចោទប្រកាន់ ក្នុងករណីមានវិមតិសង្ស័យ"]។ តុលាការកំពូលប្រទេសស្វីស សាលដីកា ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨ សំណុំរឿងលេខ 6B_1456/2017 កថាខណ្ឌ

## IV. ដំណោះស្រាយដែលស្នើឡើង

72. ដូចបានរៀបរាប់នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះច្រានចោលការសន្និដ្ឋានដែលមានកំហុសនៅក្នុងដីកាលើកលែងចោទប្រកាន់ថា មាស មុត មិនមែនជាកម្មវត្ថុនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក សន្និដ្ឋានថា មាស មុត គឺជាបុគ្គលម្នាក់ក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យ

៤.១ & តុលាការកំពូលប្រទេសស្វីស សាលដីកា ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ សំណុំរឿងលេខ 6B_193/2018 កថាខណ្ឌ ២.១ [(បកប្រែក្រៅផ្លូវការណ៍)] ["*គោលការណ៍សន្មតថាគ្មានទោសទុកជាមុន ដរាបណាតុលាការមិនទាន់សម្រេចសេចក្ដី*" កើតចេញពីគោលការណ៍នីត្យានុកូលភាព ហើយមានន័យថា ជាគោលការណ៍ ដីកាសម្រេចបញ្ចប់ ឬមិនបន្តការស៊ើបអង្កេត មិនអាចចេញដោយអយ្យការបានទេ លើកលែងតែច្បាស់លាស់ថា អំពើទាំងនោះមិននាំឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ឬថាមិនអាចបំពេញលក្ខខណ្ឌដើម្បីចោទប្រកាន់បានតែប៉ុណ្ណោះ។ ដំណើរការនីតិវិធីត្រូវតែបន្ត ក្នុងករណីទំនងជាមានការផ្ដន្ទាទោសច្រើនជាងការសម្រេចឱ្យរួចខ្លួន ឬប្រសិនបើភវនីយភាពនៃការផ្ដន្ទាទោស និងការសម្រេចឱ្យរួចផុតពីបទចោទ ហាក់សមាមាត្រគ្នា ជាពិសេស នៅពេលដែលបទល្មើសនោះមានភាពធ្ងន់ធ្ងរ"]។ **<u>ប្រទេសអាល្លឺម៉ង់៖</u>** (ក្រមនីតិវិធីព្រហ្មទណ្ឌអាល្លឺម៉ង់ ប្រការ ២០៣ [(បកប្រែក្រៅផ្លូវការ)] "តុលាការត្រូវតែសម្រេចបើកកិច្ចសំណើរការនីតិវិធីសំខាន់ៗ ក្នុងករណីដែលត្រូវពិចារណាទៅលើលទ្ធផលនៃកិច្ចដំណើរការនីតិវិធីរៀបចំ ដែលទំនងជាមានមូលដ្ឋានគ្រប់គ្រាន់ដែលនាំឱ្យសង្ស័យថា ជនជាប់ចោទដែលត្រូវនាំខ្លួនមកជំនុំជម្រះ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមែន"]។ ករណី OLG Saarbrücken, NStZ-RR 2009, 88 [OLG Saarbrücken 17.07.2008 - 1 Ws 131/08] [(បកប្រែក្រៅផ្លូវការ)] "ក្នុងការវាយតម្លៃជាបឋមពីអំពើព្រហ្មទណ្ឌ [...] ត្រូវតែផ្ដល់មូលដ្ឋានសំអាងហេតុឱ្យបានគ្រប់គ្រាន់ ប្រសិនបើការផ្ដន្ទាទោសជនសង្ស័យត្រូវបានរំពឹងថាមានភវនីយភាពមែននោះ [...]។ គោលការណ៍ "*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*" មិនអនុវត្តនៅដំណាក់កាលនេះទេ តែគោលការណ៍នេះអាចដើរតួនាទីដោយប្រយោលបាន [...]។ ហេតុដូច្នេះ ការបញ្ជាក់អំពីចន្លោះប្រហោងនានារវាងចម្លើយរបស់ជនជាប់ចោទ និងលទ្ធផលនៃភ័ស្តុតាងកំពុងតែមាន អាចទុកសម្រាប់ការជំនុំជម្រះលើអង្គសេចក្ដីទាំងមូល"]។ **<u>ប្រទេសអេស្តូនី:</u>** (ក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសអេស្តូនី មាត្រា ៦។ រឿងក្ដី *Rõigas ទល់នឹង ប្រទេសអេស្តូនី* សំណុំរឿងលេខ ៤៩០៤៥/១៣ សាលក្រមចុះ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ៣០, ៥១, ៨៧ *ដែលសំអាងលើ*សាលដីកាសាលដីកាតុលាការកំពូលប្រទេសអេស្តូនី (*Riigikohus*) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ (សំណុំរឿងលេខ ៣-១-៣-៦០-១០) ដែល "លើកឡើងវិញអំពីគោលការណ៍នីតិវិធីព្រហ្មទណ្ឌដាច់ខាត ដែលមានចែងក្នុងមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ។ គោលការណ៍នេះបានលើកឡើងថា គោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* បានកំណត់ថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ នៅពេលចេញសាលក្រម ឯគោលការណ៍*សន្មតថាគ្មានទោសទុកជាមុន ដរាបណាតុលាការមិនទាន់សម្រេចសេចក្ដី* អាចអនុវត្តបានទាក់ទងនឹងការផ្ដួចផ្ដើមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ហើយនៅដំណាក់កាលនេះ ភាពមន្ទិលសង្ស័យណាមួយចំពោះឧក្រិដ្ឋកម្ម ត្រូវតែបកស្រាយជាប្រយោជន៍ដល់កិច្ចដំណើរការនីតិវិធី"]។

កម្ពុជាប្រជាធិបតេយ្យ ហើយបញ្ជូន មាស មុត ទៅជំនុំជម្រះ ដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ។

សូមចៅក្រមអង្គបុរេជំនុំជម្រះពិនិត្យពិចារណាដោយក្ដីអនុគ្រោះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ | លោក William SMITH<br>សហព្រះរាជអាជ្ញាអន្តរជាតិរង<br><br>ជួស<br>លោកស្រី Brenda J. HOLLIS<br>សហព្រះរាជអាជ្ញាអន្តរជាតិបម្រុង | ភ្នំពេញ | |